Funded by:

Australian AID

One Vision, One Identity, One Community

www.asean.org

AANZFTA

asean

# A Guide for ASEAN Business

ASEAN – AUSTRALIA – NEW ZEALAND
Free Trade Area

CD-ROM Included

# មគ្គុទ្ទេសក៍សម្រាប់ធុរកិច្ចអាស៊ាន

## តំបន់ពាណិជ្ជកម្មសេរី
## អាស៊ាន - អូស្ត្រាលី - ណូវែ៉លហ្សេឡង់

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧។ រដ្ឋសមាជិកនៃសមាគមមាន ប្រ៊ូណេដារ៉ូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី ឡាវភីឌីអ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សឹង្ហបុរី ថៃ និងវៀតណាម។ លេខាធិការដ្ឋានអាស៊ានមានមូលដ្ឋាននៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។

**សម្រាប់តម្រូវការផ្សេងៗ សូមទាក់ទង :**
លេខាធិការដ្ឋានអាស៊ាន
ផ្នែកផ្សព្វផ្សាយសាធារណៈ និងសង្គមស៊ីវិល
និង/ឬ ទំនាក់ទំនងសេដ្ឋកិច្ចខាងក្រៅ
អគារ ៧0A ផ្លូវស៊ីស៊ីងហ្គាម៉ាន់ហ្គារ៉ាចា
ហ្សាកាតា ១២១១០
ឥណ្ឌូនេស៊ី
ទូរស័ព្ទ : (62 21) 724-3372, 726-2991
ទូរសា : (62 21) 739-8234, 724-3504
អ៊ីម៉ែល : public.div@asean.org

ព័ត៌មានទូទៅស្តីពីអាស៊ានមាននៅលើគេហទំព័រអាស៊ាន
www.asean.org

កាតាឡុកក្នុងការបោះពុម្ពឯកសារ
ឯកសារមគ្គុទ្ទេសក៍សម្រាប់ធុរកិច្ចអាស៊ាន - តំបន់ពាណិជ្ជកម្មសេរីអាស៊ាន - អូស្ត្រាលី - ណូវែលហ្សេឡង់
ហ្សាកាតា: លេខាធិការដ្ឋានអាស៊ាន ខែឧសភា ឆ្នាំ២០១០

382.71
១. -សហប្រតិបត្តិការសេដ្ឋកិច្ច - ពាណិជ្ជកម្ម -ពាណិជ្ជកម្មសេរី
២. អាស៊ាន - អូស្ត្រាលី - ណូវែលហ្សេឡង់

ISBN 978-602-8411-25-7
បោះពុម្ពលើកទី១ : ខែតុលា ឆ្នាំ២០០៩
ព្រីនឡើងវិញលើកទី១: ឧសភា ២០១០

អត្ថបទនៅក្នុងការផ្សព្វផ្សាយនេះបានដកស្រង់ដោយសេរី និងបានព្រីនឡើងវិញទៅតាមការជូនដំណឹងយ៉ាងត្រឹមត្រូវ។

កម្មសិទ្ធិរបស់លេខាធិការដ្ឋានអាស៊ាន ២០១០
រក្សាសិទ្ធិគ្រប់បែបយ៉ាង

## ការបដិសេធ

ការបោះពុម្ពនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងសម្រួលដល់ការយល់ដឹងពីការព្រមព្រៀង បង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ (AANZFTA)។ ក្នុងលក្ខណៈជាសៀវភៅណែនាំ វាមិនមែនជាផ្នែកមួយនៃកិច្ចព្រមព្រៀង និងមិនបានផ្តល់ ឬក្នុងគោលបំណងផ្តល់ការបកស្រាយស្របច្បាប់ណាមួយនៃកិច្ចព្រមព្រៀងឡើយ។

ជាជំនួយក្នុងការស្វែងយល់ ឧទាហរណ៍ខ្លះត្រូវបានបញ្ចូល ប៉ុន្តែគ្រាន់តែជាការបញ្ជាក់សើរៗ និងមិនបានផ្តល់ការវិនិច្ឆ័យ និងមិនចាត់ទុកជាការផ្តល់យោបល់ពាណិជ្ជកម្មឡើយ។ គំនិត និងសេចក្តីសន្និដ្ឋាន អាចត្រូវបានបញ្ជាក់ ប៉ុន្តែទាំងនេះមិនត្រូវបានចាត់ទុកថាជាការណែនាំស្របច្បាប់ ឬពាណិជ្ជកម្មឡើយ។

ការប្រើប្រាស់ផែនទី ក្នុងការបោះពុម្ពនេះត្រូវបានធ្វើឡើងដោយគូសបញ្ជាក់សើរៗ អំពីប្រទេសចូលរួមទៅនឹងកិច្ចព្រមព្រៀង។ វាមិនមែនជា ការអះអាងក្នុងការផ្តល់ការវិនិច្ឆ័យស្របច្បាប់/បកស្រាយអំពីព្រំប្រទល់ភូមិសាស្ត្រ។

លេខាធិការដ្ឋានអាស៊ានបានយកចិត្តទុកដាក់ក្នុងការរៀបចំការបោះពុម្ពនេះ។ យ៉ាងណាក៏ដោយ លេខាធិការដ្ឋានអាស៊ានមិនទទួលខុសត្រូវក្នុងការលុប ឬភាពមិនច្បាស់លាស់នៅក្នុងអត្ថបទបោះពុម្ព។ ទាំងលេខាធិការដ្ឋានអាស៊ាន និង AusAID មិនមានលទ្ធភាពទទួលយកការ ជំទាស់ បាត់បង់ ឬចំណាយដែលអាចកើតឡើង ឬកើតឡើងពីការប្រើព័ត៌មាននៅក្នុងការបោះពុម្ពនេះ។ ការជឿជាក់លើព័ត៌មាន គឺជាហានិភ័យ/ការទទួលខុសត្រូវរបស់អ្នកប្រើប្រាស់។

ការបោះពុម្ពនេះមិនបានឆ្លុះបញ្ចាំងពីគំនិតរបស់បណ្តាភាគីនៃកិច្ចព្រមព្រៀង លេខាធិការដ្ឋានអាស៊ាន ឬ AusAID ឡើយ។

## អារម្ភកថា

កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់ គឺជាកិច្ចការប្រវត្តិសាស្ត្រមួយសម្រាប់អាស៊ាន។ វាជាកិច្ចការទោលដំបូង និងកិច្ចព្រមព្រៀងសេដ្ឋកិច្ចទូលំទូលាយបំផុតនាពេលបច្ចុប្បន្នសម្រេចដោយអាស៊ាន ជាមួយដៃគូចរចាររបស់ខ្លួន។

AANZFTA ឈានទៅហួសសមាសភាពធម្មតានៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានដែលតាមទម្លាប់កំណត់ត្រឹមពាណិជ្ជកម្មទំនិញ និងសេវាកម្ម និងវិនិយោគ។ ផ្នែកថ្មីដែលត្រូវបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងរួមមាន បទដ្ឋាន វិធានការអនាម័យ និងភូតគាមអនាម័យ ពាណិជ្ជកម្មដោយប្រព័ន្ធអេឡិចត្រូនិច កម្មសិទ្ធិបញ្ញា គោលនយោបាយប្រកួតប្រជែង និងការបំលាស់ទីរបស់ធុរជន ក៏ដូចជាសហប្រតិបត្តិការសេដ្ឋកិច្ច។

សៀវភៅមគ្គុទ្ទេសក៍សម្រាប់ធុរកិច្ចអាស៊ានមានបំណងណែនាំឲ្យស្គាល់ AANZFTA និងចង្អុលបង្ហាញសហគមន៍ធុរកិច្ច និងអ្នកចូលរួមផ្សេងទៀតរបស់អាស៊ាន អំពីការអនុវត្ត និងការប្រើប្រាស់នូវកិច្ចព្រមព្រៀង AANZFTA។ វាក៏បានចម្រិចយកនូវផ្នែកជាក់ច្បាស់នៃកិច្ចព្រមព្រៀង រួមទាំងកាលានុវត្តភាពទីផ្សារដែលបាន ត្រូវបានបង្កើតឡើងសម្រាប់ផលិតករ ពាណិជ្ជករ វិនិយោគិន និងអ្នកប្រកបវិជ្ជាជីវៈរបស់អាស៊ាន។ មគ្គុទ្ទេសក៍នេះត្រូវបានរៀបចំបង្កើតឡើងបំពេញបន្ថែមនូវអត្ថបទច្បាប់របស់ AANZFTA ប៉ុន្តែមិនមានគោលបំណងធ្វើការបកស្រាយនូវអត្ថបទច្បាប់ក្នុងកិច្ចព្រមព្រៀងនេះឡើយ ទោះក្នុងទម្រង់ណាក៏ដោយ។

ដើម្បីបន្តចូលរួមក្នុងការផ្តល់នូវសុខមាលភាព និងវិបុលភាពសេដ្ឋកិច្ចនៃប្រជាជនអាស៊ាន ខ្ញុំសូមផ្តែផ្តាំដល់អស់លោកប្រើប្រាស់នូវឱកាសដែល AANZFTA ផ្តល់ជូនឲ្យអស់លទ្ធភាព។ ចែករំលែកព័ត៌មានជាមួយ ដៃគូអាជីវកម្មរបស់អ្នក និងជួយយើងខ្ញុំបង្កើតការយល់ដឹង និងជួយសម្រួលជំរុញការយល់ដឹងឲ្យកាន់តែប្រសើរនូវកិច្ចព្រមព្រៀង ដែលជាព្រឹត្តការណ៍សំខាន់នៅក្នុងប្រវត្តិសាស្ត្រអាស៊ាន។

**បណ្ឌិត សូរិន ពិនស៊ូវ៉ាន់**

អគ្គលេខាធិការអាស៊ាន

## សេចក្តីថ្លែងអំណរគុណ

យើងសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួម និងគាំទ្រ ក្នុងការស្ថាបនាសៀវភៅណែនាំនេះ បើគ្មានការចូលរួម និងគាំទ្រទេ សៀវភៅនេះមិនអាច...

... ចំពោះ អេនឌ្រូ ស្តូលី ក្នុងការចែករំលែកចំណេះដឹង និងជំនាញ ក្នុងការបង្កើតសម្រាប់ការបោះពុម្ពសៀវភៅនេះ

... ចំពោះអ្នកជំនាញពីលេខាធិការដ្ឋានអាស៊ាន ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី សេវាគយអូស្ត្រាលី ក្រសួងការបរទេស និងពាណិជ្ជកម្មណូវ៉ែលហ្សេឡង់ សម្រាប់ពេលវេលាមានតម្លៃក្នុងការពិនិត្យមុនការបោះពុម្ពនេះ

... ចំពោះក្រុមការងារលេខាធិការដ្ឋានអាស៊ាន ដែលបានសម្របសម្រួលក្នុងការបង្កើតសៀវភៅណែនាំនេះ សម្រាប់រួមចំណែកក្នុងការអនុវត្តឲ្យរលូនគម្រោងនេះ

... ចំពោះបុគ្គលិកដទៃទៀតរបស់លេខាធិការដ្ឋានអាស៊ាន ក្នុងជំនួយបច្ចេកទេស

... ចំពោះ AusAID ក្នុងការគាំទ្រគំនិតផ្តួចផ្តើមរបស់យើង និង

... ចុងក្រោយ ចំពោះមនុស្សទាំងអស់ដែលបានចូលរួមក្នុងការចរចា AANZFTA សម្រាប់ការខិតខំប្រឹងប្រែងពុះពារឥតឈប់ឈរក្នុងការបញ្ចប់កិច្ចព្រមព្រៀង។

**លេខាធិការដ្ឋានអាស៊ាន**

## មាតិកា


អារម្ភកថា

សេចក្តីថ្លែងអំណរគុណ

បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

ផ្នែកទី ១ - ទិដ្ឋភាពទូទៅនៃ AANZFTA

ផ្នែកទី ២ - ធាតុសំខាន់នៅក្នុង AANZFTA

- ពាណិជ្ជកម្មទំនិញ
  - ពន្ធនាំចូល
  - វិធានការមិនមែនពន្ធ
  - ការលើកកម្ពស់តម្លាភាព
- ស្តង់ដារ និងវិធានការអនាម័យ និងភូតគាមអនាម័យ
  - ស្តង់ដារ
  - វិធានការអនាម័យ និងភូតគាមអនាម័យ
- ពាណិជ្ជកម្មសេវា
  - បទប្បញ្ញត្តិក្នុងស្រុក
  - ការផ្តល់សិទ្ធិផ្តាច់ផ្តង់
  - តម្លាភាព

ការទទួលស្គាល់

ប្រព្រឹត្តិកម្មផ្តាច់មុខ និងបណ្តាការអនុវត្តជាក់លាក់របស់អាជីវកម្ម

ការបដិសេធផលប្រយោជន៍

បទប្បញ្ញត្តិស្ថាប័នសំខាន់ៗ

សេវាហិរញ្ញវត្ថុ និងទូរគមនាគមន៍

- ការវិនិយោគ
  - កម្មវិធីការងារ
  - តម្លាភាព
  - ប្រព្រឹត្តិកម្មយុត្តិធម៌ក្នុងដំណើរការតាមផ្លូវរដ្ឋបាល
  - វិនិយោគិន - ដំណោះស្រាយវិវាទរដ្ឋ
- កម្មសិទ្ធិបញ្ញា
  - ការធ្វើបច្ចុប្បន្នភាព TRIPS
  - តម្លាភាព
- ពាណិជ្ជកម្មអេឡិចត្រូនិក

គោលនយោបាយប្រកួតប្រជែង
ការបំលាស់ទីបណ្តោះអាសន្ននៃធុរជន
ផ្នែកទី ៣ - លក្ខណៈសម្របសម្រួលពាណិជ្ជកម្មសំខាន់ៗនៃ AANZFTA
វិធានដើមកំណើត
ការសម្រួលពាណិជ្ជកម្មនៅក្នុង AANZFTA
ផ្នែកទី ៤ - ឱកាសឈានទៅរកទីផ្សារថ្មី
ឱកាសពាណិជ្ជកម្មទំនិញ
ឱកាសពាណិជ្ជកម្មសេវា

**បញ្ជីប្រអប់**

ប្រអប់ ១: ការយល់ដឹងអំពី បញ្ជីវិជ្ជមាន នៃការសន្យាពាណិជ្ជកម្មសេវា
ប្រអប់ ២: និយមន័យ នៃវិនិយោគរបស់ AANZFTA
ប្រអប់ ៣: ការបញ្ជាក់លិខិតយថាភូតតាមប្រព័ន្ធអេឡិចត្រូនិក និងវិញ្ញាបនបត្រឌីជីថល
ប្រអប់ ៤: ការបំលាស់ទីបណ្តោះអាសន្ននៃធុរជន នរណាត្រូវរាប់បញ្ចូល?

**បញ្ជីតារាង**

តារាង ១: ព័ត៌មានសង្ខេបអំពីលទ្ធផលលុបពន្ធរបស់ប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់
តារាង ២: ភាគរយបន្ទាត់ពន្ធដែលមានអត្រាពន្ធក្នុងចន្លោះរវាង 0 ទៅ ៥%

## តារាងអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| AANZFTA | កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CTC | ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ |
| EIF | ចូលជាធរមាន |
| FTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី |
| GATS | កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវា |
| HS | ប្រព័ន្ធបរិយាយ និងលេខកូដសុខដុម |
| ICSID | មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ដោះស្រាយវិវាទវិនិយោគ |
| MFN | ប្រជាជាតិអនុគ្រោះបំផុត |
| ROO | វិធានដើមកំណើត |
| RVC | សមាសភាគតម្លៃតំបន់ |
| STRACAP | ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា |
| SPS | អនាម័យ និងភូតគាមអនាម័យ |
| TRIPS | កិច្ចព្រមព្រៀងទូទៅស្តីពីទិដ្ឋភាពនៃកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្មនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក |
| UNCITRAL | គណៈកម្មការរបស់អង្គការសហប្រជាជាតិផ្នែកច្បាប់ពាណិជ្ជកម្មអន្តរជាតិ |
| WCO | អង្គការគយពិភពលោក |
| WIPO | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# មគ្គុទ្ទេសក៍សម្រាប់ធុរកិច្ចអាស៊ានចំពោះកិច្ចព្រមព្រៀងបង្កើតតំបន់
# ពាណិជ្ជកម្មសេរីអាស៊ាន - អូស្ត្រាលី - ណូវែ៉លហ្សេឡង់ (AANZFTA)



## ផ្នែកទី១

## និដ្ឋភាពទូទៅនៃ AANZFTA

កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ត្រូវបានចុះហត្ថលេខាដោយបណ្តារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ជាមួយនឹងដៃគូចរចារបស់ខ្លួនមកពីប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់ នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងត្រូវបានរំពឹងថាចូលជាធរមាននៅថ្ងៃ ទី ០១ ខែ មករា ឆ្នាំ ២០១០។ តំបន់ពាណិជ្ជកម្មសេរី គ្របដណ្តប់លើផ្ទៃដីដែលមានប្រជាជនសរុបចំនួន ៦០០លាននាក់ និងផលិតផលក្នុងស្រុកសរុបប្រចាំតំបន់ប្រមាណ ២,៧ពាន់ពាន់ដុល្លារ។ កិច្ចព្រមព្រៀងថ្មីនេះបង្កើតឡើងផ្អែកតាមកិច្ចព្រមព្រៀងដែលមានស្រាប់ ដែលធ្វើការចរចារវាងបណ្តាប្រទេសអាស៊ានមួយចំនួនជាមួយប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់ និងមានគោលបំណងជំរុញបន្ថែមទៀតនូវឱកាសពាណិជ្ជកម្ម នៅក្នុងតំបន់មួយដែលការដោះដូរពាណិជ្ជកម្មមានការរីកដុះដាលយ៉ាងខ្លាំងនាប៉ុន្មានឆ្នាំចុងក្រោយនេះ។

តាំងពីចាប់ផ្តើមកិច្ចចរចា AANZFTA ក្នុងឆ្នាំ ២០០៥ មកពាណិជ្ជកម្មក្នុងតំបន់រវាងបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងមានការកើនឡើងជាមធ្យមប្រចាំឆ្នាំប្រហែល ១៦%។ ប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់ ទាំងពីររួមគ្នាក្លាយជាដៃគូពាណិជ្ជកម្មធំទី ៦ របស់អាស៊ាន។ អាស៊ានទាំងមូល គឺជាដៃគូពាណិជ្ជកម្មធំទីពីរជាមួយអូស្ត្រាលី និងធំទីបីជាមួយណូវែលហ្សេឡង់។ AANZFTA គឺជាតំបន់ពាណិជ្ជកម្មសេរី (FTA) រវាងតំបន់ និងតំបន់ដំបូងបង្អស់ដែលអាស៊ាន និងអូស្ត្រាលី និងណូវែលហ្សេឡង់សម្រេចបាន។

កិច្ចព្រមព្រៀងថ្មីនេះមានលក្ខណៈទំនើប និងជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមានលក្ខណៈទូលំទូលាយដែលផ្តល់ឱកាសថ្មីៗយ៉ាងទូលំទូលាយសម្រាប់អាជីវកម្មអាស៊ាន។ ការធ្វើឲ្យប្រសើរឡើងនូវការឈានចូលទីផ្សារត្រូវបានគាំទ្រដោយបទប្បញ្ញត្តិនៃការសម្រួលពាណិជ្ជកម្ម និងវិធានការដែលបង្កើតឡើងដើម្បីផ្តល់តម្លាភាព និងសុក្រឹតភាពបន្ថែមទៀតដល់ក្រុមហ៊ុនទាំងអស់ដែលធ្វើអាជីវកម្មនៅក្នុងតំបន់។ AANZFTA ក៏ជាកិច្ចព្រមព្រៀងរស់រវើកដែលនឹងវិវត្តនាពេលអនាគតតាមរយៈយន្តការកំណត់ស្រាប់ដែលអនុញ្ញាតឲ្យមានសេរីភាវូបនីយកម្មកាន់តែស៊ីជម្រៅ និងការដោះស្រាយបញ្ហាជាក់ស្តែង។ តាមរយៈ FTA នេះ សហប្រតិបត្តិការ និងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នឹងកាន់តែរីកដុះដាល និងស៊ីជម្រៅនៅប៉ុន្មានឆ្នាំខាងមុខនេះ។

ក៏ប៉ុន្តែកិច្ចព្រមព្រៀងដែលបានចរចារវាងបណ្តារដ្ឋាភិបាល កិច្ចព្រមព្រៀងខ្លួនវាមិនបានបង្កើតឲ្យមានពាណិជ្ជកម្មឡើយ។ ពាណិជ្ជកម្មអន្តរជាតិ គឺជាកិច្ចការនៃធុរកិច្ច ហើយវាមានសារៈសំខាន់ដែលប្រតិបត្តិករជំនួញត្រូវយល់ច្បាស់អំពីលក្ខណៈពិសេសរបស់ AANZFTA ដែលអនុញ្ញាតឲ្យពួកគេទទួលបានអត្ថប្រយោជន៍ក្នុងការអនុវត្តជាក់ស្តែងពីឱកាសដែលបង្កើតឡើងដោយ FTA។ គោលបំណងរបស់សៀវភៅមគ្គុទ្ទេសក៍នេះ គឺបកស្រាយដោយប្រើពាក្យពេចន៍សាមញ្ញ នូវសំណួរថាតើបរិយាកាសពាណិជ្ជកម្មក្នុងតំបន់នឹងត្រូវផ្លាស់ប្តូរយ៉ាងដូចម្តេច បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន (EIF) នៅដើមឆ្នាំ ២០១០។ ចំណេះដឹងពាក់ព័ន្ធធាតុសំខាន់ៗរបស់ FTA និងភាពបត់បែនបានដែលមាននៅក្នុងការអនុវត្ត FTA នឹងធ្វើឲ្យអ្នកនាំចូល អ្នកនាំចេញ វិនិយោគិន និងអ្នកប្រើប្រាស់មានលទ្ធភាពទាញយកនូវផលប្រយោជន៍ ដែលបណ្តាប្រមុខរដ្ឋាភិបាលផ្តល់ជូនពេលចុះហត្ថលេខាកិច្ចព្រមព្រៀង AANZFTA ។

## ផ្នែកទី២

## ធាតុសំខាន់នៅក្នុង AANZFTA

AANZFTA គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់មួយដែលមានលក្ខណៈទំនើប និងទូលំទូលាយ។ កិច្ចព្រមព្រៀងនេះនឹងលុបពន្ធលើការនាំចេញរបស់អាស៊ានទៅកាន់អូស្ត្រាលី និងណូវែលហ្សេឡង់ ដែលក្នុងនោះពន្ធនាំចូលអូស្ត្រាលីច្រើនជាង ៩៦% នឹងត្រូវលុបនៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមានក្នុងឆ្នាំ ២០១០ និងពន្ធនាំចូលរបស់ណូវែលហ្សេឡង់ជាង ៩០% លើផលិតផលរបស់អាស៊ានត្រូវលុបក្នុងឆ្នាំ ២០១៣។ រាល់ពន្ធដែលនៅសេសសល់ទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០២០។ ការសន្យាពន្ធទាំងអស់នេះ នឹងត្រូវអនុវត្តលើបណ្តាទំនិញដែលបានបំពេញលក្ខខណ្ឌវិធានដើមកំណើតរបស់ AANZFTA។ កិច្ចព្រមព្រៀងថ្មីនេះក៏បាន ធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាក្នុងតំបន់ផងដែរ។ បទប្បញ្ញត្តិដ៏ទៃទៀតចែងអំពីការវិនិយោគ កម្មសិទ្ធិបញ្ញា នីតិវិធីគយពាណិជ្ជកម្មអេឡិចត្រូនិច នយោបាយប្រកួតប្រជែង ស្តង់ដារ និងការចល័តបណ្តោះអាសន្នរបស់ពាណិជ្ជករក្នុងតំបន់។ ស្ថាប័នថ្មីកម្រិតតំបន់ជាច្រើនដែលត្រូវបង្កើតឡើងក្រោម AANZFTA នឹងធានាឲ្យបាននូវការអនុវត្តកិច្ចព្រមព្រៀងនេះប្រកបដោយប្រសិទ្ធភាព និងអាចធ្វើសេរីភាវូនីយកម្មកិច្ចព្រមព្រៀងនេះក្នុងពេលអនាគត។ បណ្តាធាតុសំខាន់ៗនៅក្នុង FTA ត្រូវបានសង្ខេបដូចខាងក្រោមនេះ។ ឱកាសថ្មីនៃការបើកច្រកទីផ្សារសម្រាប់ពាណិជ្ជកម្មទំនិញ និងសេវាត្រូវបានលើកយកមកដោះស្រាយក្នុងផ្នែកទី៤ នៃសៀវភៅណែនាំនេះ។

**ពាណិជ្ជកម្មទំនិញ** (ជំពូកទី២ ក្នុង AANZFTA)

**ពន្ធនាំចូល** ដូចដែលបានកត់សម្គាល់ខាងលើ AANZFTA នឹងបង្កើតឱកាសថ្មីៗជាច្រើនសម្រាប់អ្នកនាំចេញទំនិញដើមកំណើតក្នុងក្របខ័ណ្ឌ AANZFTA តាមរយៈការកាត់បន្ថយ និងលុបពន្ធលើបណ្តាផលិតផលនៅពេលកិច្ចព្រមព្រៀងចូលជាធរមាន ឬនៅក្នុងឆ្នាំដំបូងនៃការអនុវត្តកិច្ចសន្យា។ កិច្ចព្រមព្រៀងនេះក៏បានផ្តល់នូវលទ្ធភាពក្នុងការពន្លឿនការកាត់បន្ថយ និងលុបពន្ធនាំចូល។ សម្រាប់រាល់ព័ត៌មានពាក់ព័ន្ធពន្ធនាំចូលដែលត្រូវអនុវត្តលើបណ្តាមុខទំនិញ អ្នកនាំចូលទាំងអស់អាចរកព័ត៌មានអំពីកម្មវិធីពន្ធនាំចូលរបស់ភាគីទាំង ១២ នៅលើគេហទំព័ររបស់លេខាធិការដ្ឋានអាស៊ាន www.asean.org ។ សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងឱកាសថ្មីៗដែលមានក្នុងវិស័យនីមួយៗ មាននៅក្នុងផ្នែកទី ៤។

**វិធានការមិនមែនពន្ធ** បន្ថែមលើបទប្បញ្ញត្តិស្តីពីការកាត់បន្ថយ និងលុបពន្ធនាំចូល ជំពូក២ នៃ AANZFTA ក៏មានចែងអំពី ការដាក់កម្រិតបរិមាណ និងវិធានការមិនមែនពន្ធផងដែរ។ ជាវិធីកាត់បន្ថយ និងលុបនូវវិធានការមិនមែនពន្ធនាពេលអនាគត នីតិវិធីមួយត្រូវបានបង្កើតឡើងក្នុង AANZFTA ដែលផ្តល់លទ្ធភាពឲ្យរដ្ឋាភិបាលស្នើសុំគណៈកម្មាធិការពាណិជ្ជកម្មទំនិញ ពិនិត្យឡើងវិញនូវបណ្តាវិធានការមិនមែនពន្ធជាក់លាក់ណាមួយក្នុងទស្សនៈកាត់បន្ថយ និងលុបនូវផលប៉ះពាល់អវិជ្ជមាននៃវិធានការទាំងនោះលើការធ្វើពាណិជ្ជកម្ម។ បទប្បញ្ញត្តិនេះមានសារៈសំខាន់ណាស់សម្រាប់អាជីវកម្ម។ បណ្តាប្រតិបត្តិករពាណិជ្ជកម្មដែលដឹងពីផលប៉ះពាល់នៅក្នុងទីផ្សាររបស់វិធានការមិនមែនពន្ធនៅក្នុង AANZFTA លើអាជីវកម្មរបស់ខ្លួន អាចជូនដំណឹងដល់រដ្ឋាភិបាលរបស់ខ្លួនស្តីពីវិធានការទាំងអស់នេះ ដើម្បីរដ្ឋាភិបាលមានលទ្ធភាពលើកនូវបញ្ហានេះនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្មទំនិញតាមការគួរ។

**ការលើកកម្ពស់តម្លាភាព** អាជីវកម្មនឹងទទួលផលប្រយោជន៍ពីបទប្បញ្ញត្តិទាក់ទងការលើកកម្ពស់តម្លាភាពនៅក្នុង AANZFTA។ FTA តម្រូវឲ្យរដ្ឋាភិបាលដែលចូលរួម បោះពុម្ពផ្សាយ ដែលរួមមានការផ្សាយតាមអ៊ិនធឺណេតនូវច្បាប់នានា បទប្បញ្ញត្តិនានា ការសម្រេចដែលទាក់ទងទៅនឹងពាណិជ្ជកម្ម ។ ប្រទេសភាគច្រើនបានយកកម្រៃ និងបន្ទុកបន្ថែមពីលើពន្ធនាំចូលលើផលិតផលជាក់លាក់ ហើយ AANZFTA ទាមទារឲ្យព័ត៌មានអំពីកម្រៃ និងបន្ទុកទាំងនេះអាចរកបានតាមអ៊ិនធឺណេត។ កាតព្វកិច្ចតម្លាភាពទាំងនេះ បានបង្កើតឡើងដោយពឹងផ្អែកលើកាតព្វកិច្ចតម្រូវដោយអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

## ស្តង់ដារ និងវិធានការអនាម័យ និងភូតគាមអនាម័យ

**ស្តង់ដារ** (ជំពូក ៦ នៃ AANZFTA) ស្តង់ដារ បទបញ្ជាបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា ត្រូវបានបង្កើតដោយរដ្ឋាភិបាល និងវិស័យឯកជន ក្នុងទស្សនៈសម្រេចឲ្យបាននូវគោលដៅគោលនយោបាយសាធារណៈសំខាន់ៗ ដូចជាការធានាថាផលិតផលមិនមានគ្រោះថ្នាក់ដល់សុខភាព ឬសុវត្ថិភាពរបស់អ្នកប្រើប្រាស់។ ទោះជាយ៉ាងណា ប្រសិនបើវិធានការទាំងនេះមានលក្ខណៈខុសគ្នាខ្លាំងនៅក្នុងប្រទេសខុសៗគ្នា ការខុសប្លែកគ្នាអាចចោទជាការបញ្ហាយ៉ាងធំចំពោះអ្នកនាំចេញ។ ជំពូក ៦ នៃ AANZFTA ទទួលស្គាល់បញ្ហានេះ ហើយបញ្ចូលនូវកាតព្វកិច្ចសំខាន់ៗ ដែលទាក់ទងទៅនឹងស្តង់ដារ បទបញ្ជាបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា ដែលបង្កើតដោយផ្អែកលើកាតព្វកិច្ចរបស់រដ្ឋាភិបាលក្រោមកិច្ចព្រមព្រៀង WTO ស្តីពីរបាំងបច្ចេកទេសលើពាណិជ្ជកម្ម។ សម្រាប់ធុរកិច្ច បទប្បញ្ញត្តិនៃ AANZFTA ដែលទាក់ទងទៅនឹងស្តង់ដារគឺមានសារៈសំខាន់ណាស់សម្រាប់ពាណិជ្ជកម្ម ។

ស្របគ្នាជាមួយនឹងបណ្តាបទប្បញ្ញត្តិ WTO AANZFTA បានបញ្ចូលកាតព្វកិច្ចជាមូលដ្ឋានដើម្បីស្តង់ដារអន្តរជាតិធ្វើជាគ្រឹះសម្រាប់បទប្បញ្ញត្តិបច្ចេកទេសជាតិ ។ ក្នុងករណីដែលស្តង់ដារអន្តរជាតិមិនត្រូវបានប្រើប្រាស់ ព្រោះវាមិនមានប្រសិទ្ធភាព និងមិនស័ក្តិសម ហើយប្រសិនបើស្តង់ដារជាតិមានការខុសគ្នារវាងសមាជិក AANZFTA រដ្ឋាភិបាលត្រូវតម្រូវឲ្យធ្វើការពិចារណាទទួលយកនូវបទបញ្ញាបច្ចេកទេសរបស់ភាគីផ្សេងទៀតដែលសមមូលទៅនឹងវិធានការរបស់ខ្លួន។ ទាំងនេះជាការពិតនៃនីតិវិធីវាយតម្លៃភាពស្របគ្នា និងខុសគ្នា ។ បទប្បញ្ញត្តិជំរុញភាពសមមូលទាំងនេះគឺមានសារៈសំខាន់ចំពោះអាជីវកម្ម ពីព្រោះវាមានគោលដៅជៀសវាងនូវការសាកល្បងច្រើនសារចំពោះផលិតផលសម្រាប់ស្តង់ដារខុសគ្នា ។

ជំពូកស្តីពីស្តង់ដារនានានេះបានតម្រូវឲ្យរដ្ឋាភិបាលដែលចូលរួម ខិតខំប្រឹងប្រែងទទួលយកនូវគំនិតផ្តួចផ្តើមសម្រួលពាណិជ្ជកម្ម អំពីស្តង់ដារ បទបញ្ញាបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នារាប់បញ្ចូលទាំងកិច្ចព្រមព្រៀងលើបញ្ហាបទបញ្ញា។ ឧទាហរណ៍ សមាជិកពីរ ឬច្រើនរបស់ AANZFTA បានធ្វើការចុះកិច្ចព្រមព្រៀង ឬកិច្ចសម្រុះសម្រួលដែលបង្កើតឡើងដើម្បីតម្រឹមស្តង់ដារ ឬទទួលស្គាល់នូវភាពសមមូលនៃបទបញ្ញាបច្ចេកទេស ឬនីតិវិធីវាយតម្លៃភាពស្របគ្នា ពួកគេមានកាតព្វកិច្ចបើកចំហការចូលរួមនៅក្នុងកិច្ចព្រមព្រៀងចំពោះដៃគូ AANZFTA ផ្សេងទៀតដែលអាចបំពេញនូវលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះបាន ។

ដើម្បីធានាថា FTA នៅតែជាកិច្ចព្រមព្រៀងរស់រវើកដែលអាចវិវត្តនៅពេលវេលាមួយ ភាគីនានាក៏បានបង្កើតនូវអនុគណៈកម្មាធិការស្តីពីស្តង់ដារ បទបញ្ញាបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា (the STRACAP Sub-Committee) ដែលទទួលខុសត្រូវរៀបចំកិច្ចប្រជុំតាមកាលកំណត់ ដើម្បីជំរុញ និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងស្តង់ដាររបស់ AANZFTA។ បទពិសោធន៍នៅក្នុង FTA ផ្សេងទៀតបានបង្ហាញថា ការបង្កើតនូវអង្គភាពអាចឲ្យភាគីនានាដោះស្រាយនូវបណ្តាបញ្ហាពាណិជ្ជកម្មដែលទាក់ទងនឹងភាពខុសគ្នារវាងស្តង់ដារថ្នាក់ជាតិ និងនីតិវិធីវាយតម្លៃភាពស្របគ្នា ។

**វិធានការអនាម័យ និងភូតគាមអនាម័យ (SPS)** (ជំពូក ៥ នៃ AANZFTA) វិធានការទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីការពារជីវិត និងសុខភាពរបស់ មនុស្ស សត្វ និងរុក្ខជាតិ ទាមទារឲ្យពិចារណាអំពីស្ថានភាពរបស់ប្រទេសនានាហើយជាលទ្ធផលអាចនឹងមានភាពខុសគ្នាច្រើនពីប្រទេសមួយជាមួយប្រទេសមួយទៀត។ ចំពោះស្តង់ដារផលិតផល ភាពខុសគ្នារបស់វិធានការ SPS អាចបង្កឲ្យមានបញ្ហាពាណិជ្ជកម្មយ៉ាងឆាប់រហ័ស ។ ជំពូក ៥ នៃ AANZFTA មានគោលបំណងបន្ធូរបន្ថយលទ្ធភាពនេះតាមមធ្យោបាយជាច្រើនដែលមានផ្តល់លទ្ធផលជាក់ស្តែងសម្រាប់សហគមន៍អាជីវកម្ម ។

ជាជំហានដំបូង បណ្ដារដ្ឋាភិបាលនៃសមាជិក AANZFTA ត្រូវបានលើកទឹកចិត្តឲ្យរៀបចំកិច្ចសម្រុះសម្រួលសមមូល និងធ្វើសេចក្ដីសម្រេចសមមូល ដើម្បីជៀសវាងនូវបញ្ហាដែលទាក់ទងនឹងពាណិជ្ជកម្មនៅក្នុងវិស័យ SPS ។ វាក៏នៅមានកាតព្វកិច្ចដើម្បីការចរចារតាមសំណើរបស់ភាគីផ្សេងទៀត ក្នុងគោលបំណងបង្កើតកិច្ចសម្រុះសម្រួលទទួលស្គាល់ទ្វេភាគីនៃភាពសមមូលនៃវិធានការ SPS ជាក់លាក់នោះ ។

ជំហានបន្ទាប់ AANZFTA បង្កើតនូវយន្តការប្រឹក្សា ដើម្បីដោះស្រាយបញ្ហា SPS ដែលទាក់ទងនឹងពាណិជ្ជកម្ម ។ នៅក្នុងករណីដែលអ្នកនាំចេញគិតថារដ្ឋាភិបាល AANZFTA កំពុងអនុវត្តនូវវិធានការ SPS ដែលពុំចាំបាច់ និងផ្ដល់ផលប៉ះពាល់ជាអវិជ្ជមានលើពាណិជ្ជកម្មរបស់ខ្លួនក្នុងតំបន់ ខ្លួនអាចលើកយកវិធានការនេះ ទៅរដ្ឋាភិបាលរបស់ខ្លួនដែលមានលទ្ធភាពក្នុងការស្នើឲ្យមានយន្តការប្រឹក្សាដើម្បីដោះស្រាយនូវបញ្ហានេះលក្ខណៈទ្វេភាគី។ បញ្ហាដែលមិនត្រូវបានដោះស្រាយតាមរយៈការប្រឹក្សាទ្វេភាគី អាចបញ្ជូនទៅគណៈកម្មាធិការចម្រុះ FTA ដើម្បីដោះស្រាយ ។

ជំហានចុងក្រោយ ជំពូក SPS នៃ AANZFTA បង្កើតអនុគណៈកម្មាធិការលើបញ្ហា SPS ក្នុងគោលបំណងសម្រាប់ត្រួតពិនិត្យឡើងវិញនូវការវិវត្តនៃការអនុវត្តបទប្បញ្ញត្តិ SPS របស់ FTA រួមទាំងការបង្កើតក្រុមការងារដែលអាចជំរុញឲ្យគោលបំណងនៃជំពូកនេះ មានការជឿនលឿននាពេលខាងមុខ។ ចំពោះស្តង់ដារផលិតផល ស្ថាប័នកិច្ចព្រមព្រៀងរស់រវើក ដូចជាអនុគណៈកម្មាធិការ SPS ត្រូវបានបង្កើតដើម្បីជួយសម្រួលដល់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ក្នុងបរិបទកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដទៃទៀត ។

## ពាណិជ្ជកម្មសេវា

តាមរយៈ AANZFTA ភាគីនានាឈានហួសការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវានានាដែលពួកគេបានសន្យានៅក្នុង WTO។ ការសន្យារបស់ពួកគេរួមមាន ការបើកច្រកទីផ្សារ ប្រព្រឹត្តិកម្មជាតិ បទប្បញ្ញត្តិនានាស្ដីពីប្រព្រឹត្តិកម្មប្រជាជាតិអនុគ្រោះបំផុត (MFN) និងការការពារ និងវិន័យបទបញ្ជា និងកាតព្វកិច្ចនានា នឹងបង្កើនភាពទៀងទាត់ និងតម្លាភាពសម្រាប់អ្នកនាំចេញសេវានានារបស់អាស៊ាន។

ទោះបីជាបទប្បញ្ញត្តិពាណិជ្ជកម្មសេវាក្នុង AANZFTA គឺ "WTO-Plus" (ក្នុងន័យថាពួកគេធ្វើលើសពីអ្វីដែលភាគីនានាតម្រូវឲ្យធ្វើនៅក្នុងកិច្ចព្រមព្រៀងទូទៅស្ដីពីពាណិជ្ជកម្មសេវា (GATS) ក្នុង WTO)

ក៏ FTA ត្រូវបានរៀបចំឡើងដូចគ្នាជាមួយនឹង GATS។ ជំពូកពាណិជ្ជកម្មកសេវាលាតត្រដាងនូវបណ្តាសិទ្ធិ និងកាតព្វកិច្ចទូទៅនៃកិច្ចព្រមព្រៀងដោយហេតុថា វាអនុវត្តជាទូទៅ។

**ប្រអប់ ១: យល់ដឹងអំពីបញ្ជីវិជ្ជមាននៃការសន្យាពាណិជ្ជកម្មសេវា**

នៅក្នុងគោលការណ៍បញ្ជីវត្តមានប្រភេទ GATS នៃការសន្យាសេវាដែលបានប្រើនៅក្នុងAANFTA ប្រទេសនានារាប់បញ្ចូលការសន្យាទាំងនេះតាមរយៈ "ម៉ូដផ្គត់ផ្គង់" ហើយតាមរយៈថាតើការសន្យាទាំងនេះមានផលប៉ះពាល់ចំពោះការធ្វើអាជីវកម្មក្នុងប្រទេស (ការបើកច្រកទីផ្សារ) ឬក៏ឆ្លុះបញ្ចាំងវិធានការ ដែលរើសអើងចំពោះអ្នកផ្តល់សេវាបរទេស (ប្រព្រឹត្តិកម្មជាតិ)។ នៅក្នុងករណីខ្លះ ការសន្យាត្រូវបានចាត់ទុកជា "None" (មានន័យថាគ្មានរបាំង ឬការរើសអើងអ្វីទេ ឬ "Unbound" (មានន័យថាអវត្តមានការសន្យារបស់រដ្ឋាភិបាលពាក់ព័ន្ធ)។ "ម៉ូដផ្គត់ផ្គង" ទាំងបួនរួមមាន :

ម៉ូដ ១ : ការផ្គត់ផ្គង់ឆ្លងព្រំដែន ( អ្នកនាំចេញសេវាកម្មនៅក្នុងប្រទេស "ក" លក់សេវាកម្មទៅឲ្យអតិថិជននៅក្នុងប្រទេស "ខ" ហើយអ្នកទាំងពីរនៅក្នុងប្រទេសរៀងៗខ្លួន)។ ឧទាហរណ៍ វិស្វករនៅក្នុងប្រទេសសឹង្ហបុរីលក់គម្រោងសាងសង់អគាររបស់ខ្លួនទៅឲ្យក្រុមហ៊ុនសាងសង់ប្រទេសណូវ៉ែលហ្សេឡង់។

ម៉ូដ ២ : ការប្រើប្រាស់ក្រៅប្រទេស (អ្នកប្រើប្រាស់សេវាកម្មពីប្រទេស "ខ" ធ្វើដំណើរទៅកាន់ប្រទេស "ក" ដើម្បីទិញ និងប្រើប្រាស់សេវាក្នុងប្រទេស "ក") ។ ឧទាហរណ៍ និស្សិតពីប្រទេសម៉ាឡេស៊ីធ្វើដំណើរទៅប្រទេសអូស្ត្រាលីដើម្បីសិក្សានៅសកលវិទ្យាល័យ។

ម៉ូដ ៣ : វត្តមានស្ថាប័នពាណិជ្ជកម្ម (អ្នកផ្គត់ផ្គង់សេវានៅក្នុងប្រទេស "ក" បង្កើតការិយាល័យនៅក្នុងប្រទេស "ខ" ដើម្បីលក់សេវារបស់ខ្លួននៅក្នុងប្រទេស "ខ") - ឧទាហរណ៍ ក្រុមហ៊ុនច្បាប់របស់ប្រទេសអូស្ត្រាលី បើកការិយាល័យមួយនៅក្នុងទីក្រុងហាណូយ។

ម៉ូដ ៤ : ការបំលាស់ទីបណ្តោះអាសន្ននៃរូបវន្តបុគ្គល (អ្នកផ្គត់ផ្គង់សេវាប្រទេស "ក" ជួលបុគ្គលឲ្យធ្វើដំណើរបណ្តោះអាសន្នទៅកាន់ប្រទេស "ខ" ដើម្បីផ្គត់ផ្គង់ និងលក់សេវាទៅឲ្យអ្នកប្រើប្រាស់ក្នុងប្រទេស "ខ"។

លើសពីនេះទៅទៀត ភាគីនីមួយៗ នៅក្នុង AANZFTA មានតារាងនៃការសន្យាជាក់លាក់ ដែលរៀបរាប់ពីការបើកច្រកទីផ្សារ និងការសន្យាប្រព្រឹត្តិកម្មជាតិ ត្រូវបានរៀបចំឡើងដើម្បីអនុវត្តចំពោះវិស័យសេវា និងអនុវិស័យនីមួយៗ តាមម៉ូដផ្គត់ផ្គង់ផ្សេងៗពីគ្នា សម្រាប់សេវានានាដែលបានប្រើប្រាស់នៅក្នុង AANZFTA និង GATS។ ឱកាសថ្មីៗជាច្រើនដែលត្រូវបានបើកចំហសម្រាប់អ្នកនាំចេញ ASEAN ដោយសារការសន្យារបស់អូស្ត្រាលី និងណូវ៉ែលហ្សេឡង់ ដែលលើសពីការសន្យារបស់ខ្លួននៅក្នុង WTO ត្រូវបានលើកយកមកពិភាក្សានៅក្នុងផ្នែកទី៤ នៃមគ្គុទ្ទេសក៍នេះ។

នៅក្នុងវិស័យដែលការសន្យាការបើកច្រកទីផ្សារពេញលេញត្រូវបានអនុវត្ត ភាគីនានានៅក្នុង AANZFTA សន្យាមិនដាក់របាំងដូចជា : ការកំណត់ចំនួនអ្នកផ្គត់ផ្គង់សេវាដែលត្រូវបានអនុញ្ញាតឲ្យចូលទីផ្សារ ការកំណត់តម្លៃប្រតិបត្តិការសេវា ឬបរិមាណនៃការផ្គត់ផ្គង់សេវា ការកំណត់ទៅលើមូលធនបរទេសសម្រាប់ប្រតិបត្តិការ ការកំណត់ចំនួនបុគ្គលិកសម្រាប់ប្រតិបត្តិការសេវា និងវិធានការនានាដែលតម្រូវឲ្យសេវាត្រូវផ្គត់ផ្គង់តាមរយៈអង្គភាពច្បាប់ជាក់លាក់មួយ។ នៅពេលដែលការសន្យាពេញលេញត្រូវបានអនុវត្តចំពោះប្រព្រឹត្តិកម្មជាតិ រដ្ឋាភិបាលនានាយល់ព្រមថាអ្នកផ្គត់ផ្គង់

សេវាបរទេសដូចអ្នកផ្គត់ផ្គង់ សេវាក្នុងស្រុកដោយមិនមានការរើសអើង។ ទោះយ៉ាងណាក៏ដោយ ដូចការបង្ហាញខាងលើ តារាងកម្មវិធីរបស់ភាគីអាចកំណត់ទៅលើការបើកច្រកទីផ្សារ ឬប្រព្រឹត្តិកម្មជាតិ នៅគ្រប់វិស័យទាំងអស់ ឬចំពោះវិស័យជាក់លាក់ណាមួយ។

**បទប្បញ្ញត្តិក្នុងស្រុក** ជំពូក ៨ នៃ AANZFTA ស្តីពីពាណិជ្ជកម្មសេវា ក៏មានរួមបញ្ចូលកាតព្វកិច្ចសំខាន់ៗមួយចំនួនពីរដ្ឋាភិបាលពាក់ព័ន្ធបទប្បញ្ញត្តិក្នុងស្រុក។ កាតព្វកិច្ចទាំងនេះ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព គឺមានផ្តល់ប្រយោជន៍ច្រើនចំពោះធុរកិច្ច។ ឧទាហរណ៍ វិធានការបទបញ្ញាទាំងអស់ ដែលត្រូវអនុវត្តជាទូទៅ ត្រូវតែគ្រប់គ្រងក្នុងលក្ខណៈមួយដែលសមហេតុផល និងមិនលំអៀង។ ដូចគ្នានេះដែរ នៅក្នុងវិស័យដែលការសន្យាជាក់លាក់ត្រូវធ្វើឡើងបានគ្រប់លក្ខខណ្ឌ និងនីតិវិធីនានា ស្តង់ដារបច្ចេកទេស និងនីតិវិធី និងលក្ខខណ្ឌផ្តល់អាជ្ញាប័ណ្ណ និងនីតិវិធីត្រូវតែពឹងផ្អែកទៅលើលក្ខខណ្ឌតម្លាភាព និងមិនលំអៀង ហើយមិនត្រូវមានភាពស្មុគស្មាញជាងការចាំបាច់ និងមិនត្រូវដាក់កម្រិតលើការផ្គត់ផ្គង់សេវា។

ការផ្តល់សិទ្ធិផ្គត់ផ្គង់ នៅក្នុងករណីដែលធុរកិច្ចនៅក្នុងវិស័យសេវាកម្ម តម្រូវឲ្យដាក់ពាក្យស្នើសុំសិទ្ធិផ្គត់ផ្គង់សេវានៅក្នុងទីផ្សារ AANZFTA តម្រូវឲ្យអាជ្ញាធរមានសមត្ថកិច្ច :

- ធានាថាអ្នកដាក់ញ្យស្នើសុំមានពេលវេលា និងព័ត៌មានដែលត្រូវការសម្រាប់បំពេញ និងរៀបចំពាក្យស្នើសុំ
- ជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីការសម្រេចនៅក្នុងកំលុងពេលសមស្របមួយ
- ផ្តល់ព័ត៌មានអំពីស្ថានភាពនៃពាក្យស្នើដែលកំពុងពិនិត្យពិចារណា និង
- ក្នុងករណីពាក្យស្នើសុំត្រូវបានបដិសេធ ផ្តល់ហេតុផលសមស្របទៅអ្នកដាក់ពាក្យស្នើសុំលើការបដិសេធនោះ និងផ្តល់ឱកាសសម្រាប់ដាក់ការស្នើសុំសារជាថ្មី ប្រសិនបើពួកគេមានបំណង ។

**តម្លាភាព** អាជីវកម្មត្រូវបានផ្តល់ឱកាសឲ្យដឹងអំពីវិធានច្បាប់ និងវិធានការផ្សេងទៀត ដែលប៉ះពាល់ដល់ពាណិជ្ជកម្មសេវាតាមរយៈលក្ខខណ្ឌរបស់ AANZFTA ដែលព័ត៌មានអំពីវិធានការទាំងអស់នេះ និងកិច្ចព្រមព្រៀងអន្តរជាតិណាមួយដែលអាចប៉ះពាល់ពាណិជ្ជកម្មសេវា ត្រូវបានបោះផ្សាយ និងអាចរកបានតាមអ៊ិនធឺណេត។ រដ្ឋាភិបាលក៏ត្រូវឲ្យបង្កើតចំណុចទាក់ទង ដែលទទួលបន្ទុកឆ្លើយតបភ្លាមៗ នូវការស្នើសុំព័ត៌មានទទួលបានពីភាគីដទៃនៅក្នុង AANZFTA។

**ការទទួលស្គាល់** មានផ្នែកសំខាន់មួយចំនួនក្នុងជំពូកសេវា AANZFTA ជំរុញឲ្យមានការទទួលស្គាល់អំពីលក្ខខណ្ឌនៃការអប់រំសិក្សា និង/ឬបទពិសោធន៍ដែលទាក់ទងនឹងអាជ្ញាប័ណ្ណ និងសញ្ញាបត្រ

ដើម្បីអនុវត្តនូវប្រភេទសេវាជាក់លាក់មួយចំនួន។ ភាគីនានាត្រូវបានលើកទឹកចិត្តឱ្យចាប់ផ្តើមធ្វើសុខដុម ឬការចរចាដើម្បីបង្កើតនូវកិច្ចព្រមព្រៀងទទួលស្គាល់ ដើម្បីបង្កលក្ខណៈងាយស្រួលឲ្យអ្នកផ្គត់ផ្គង់សេវាវិជ្ជាជីវៈនៅក្នុងប្រទេសសមាជិក AANZFTA មួយអាចអនុវត្តពាណិជ្ជកម្មរបស់ខ្លួននៅក្នុងប្រទេសសមាជិក AANZFTA ផ្សេងទៀត។ ក្នុងករណីដែលប្រទេសសមាជិក AANZFTA ចំនួនពីរ ឬច្រើនចូលរួមក្នុងប្រភេទសកម្មភាពដែលមានការទទួលស្គាល់នេះ ពួកគេមានកាតព្វកិច្ចអនុញ្ញាតឲ្យប្រទេសសមាជិក AANZFTA ដទៃផ្សេងទៀតមានលទ្ធភាពចរចារចូលរួមក្នុងកិច្ចព្រមព្រៀងនេះ។ ក្នុងករណីភាគីធ្វើកិច្ចព្រមព្រៀងទទួលស្គាល់ដោយខ្លួនឯង ពួកគេត្រូវផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់ភាគីផ្សេងទៀត ដើម្បីបង្ហាញថាពួកគេអាចបំពេញលក្ខខណ្ឌដូចគ្នានេះ។

**ប្រព្រឹត្តិកម្មផ្តាច់មុខ និងការអនុវត្តជាក់លាក់របស់អាជីវកម្ម** ក្នុងករណីដែលរដ្ឋាភិបាលនៃ AANZFTA អនុញ្ញាតឲ្យមានបទប្បញ្ញត្តិផ្តាច់មុខរបស់សេវាជាក់លាក់នានានៅលើទីផ្សារ រដ្ឋាភិបាលនោះត្រូវជាប់កាតព្វកិច្ចរបស់ FTA ដោយធានាថាការផ្តាច់មុខនេះមិនបំផ្លាញដល់ការសន្យានានាលើសេវារបស់ខ្លួនឡើយ។ ដូចគ្នានេះដែរ ក្នុងករណីដែលរដ្ឋាភិបាលត្រូវរងការចោទប្រកាន់ថា អនុញ្ញាតឲ្យអ្នកផ្គត់ផ្គង់សេវាធ្វើសកម្មភាពដែលរារាំងដល់ការប្រកួតប្រជែង និងកម្រិតពាណិជ្ជកម្ម មានការតម្រូវឲ្យស្វែងរកការប្រឹក្សាក្នុងទស្សនៈលុបចោលការប្រឆាំងការប្រកួតប្រជែង។

**ការបដិសេធផលប្រយោជន៍** ដូចនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះនានា AANZFTA ត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវអត្ថប្រយោជន៍ចំពោះក្រុមហ៊ុន និងអ្នកផ្គត់ផ្គង់សេវាក្នុងតំបន់ សម្រាប់អ្នកដែលជាភាគីប៉ុណ្ណោះ។ ដើម្បីធានាចំពោះករណីនេះ មាត្រា ២១ នៃជំពូក៨ អនុញ្ញាតឲ្យភាគីបដិសេធនូវអត្ថប្រយោជន៍នានារបស់កិច្ចព្រមព្រៀងដូចខាងក្រោម :

- ចំពោះការផ្គត់ផ្គង់សេវាណាមួយ ប្រសិនបើសេវានោះផ្គត់ផ្គង់ពី ឬនៅក្នុងដែនដីរបស់អ្នកមិនមែនភាគី
- ក្នុងករណីការផ្គត់ផ្គង់សេវាដឹកជញ្ជូនផ្លូវសមុទ្រ ប្រសិនបើសេវាកម្មនោះផ្គត់ផ្គង់ :
    - ដោយនាវាដែលចុះបញ្ជីក្រោមច្បាប់របស់ប្រទេសមិនមែនភាគី
    - ដោយបុគ្គលដែលមិនមែនភាគី ដំណើរការ និង/ឬប្រើប្រាស់នាវាទាំងមូល ឬមួយផ្នែក
- ចំពោះអ្នកផ្គត់ផ្គង់សេវាជានីតិបុគ្គល ប្រសិនបើខ្លួនមិនមែនអ្នកផ្គត់ផ្គង់សេវានៃភាគីដទៃទៀត

**បទប្បញ្ញត្តិស្ថាប័នសំខាន់ៗ** ដូចទិដ្ឋភាពសំខាន់ៗដទៃទៀតរបស់ AANZFTA ជំពូកសេវាក៏បានបង្កើតនូវស្ថាប័ននានាដែលធានាថា AANZFTA គឺជាកិច្ចព្រមព្រៀងរស់រវើក ដែលអាចបន្តវិវត្តទៅ

មុខទៀត។ គណៈកម្មាធិការពាណិជ្ជកម្មសេវាត្រូវបង្កើតឡើង និងមានតួនាទីក្នុងការរៀបចំពិនិត្យមើលឡើងវិញនូវបណ្តាការសន្យាដែលធ្វើឡើងដោយភាគី AANZFTA ក្នុងរយៈពេល ០៣ឆ្នាំ បន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមាន។ គណៈកម្មាធិការនេះក៏នឹងពិចារណាទៅលើការការការពារបន្ទាន់សម្រាប់ពាណិជ្ជកម្មសេវានៅក្នុងករណីការចរចា WTO លើបញ្ហានេះ មិនបានផ្តល់នូវលទ្ធផលអ្វីមួយក្នុងកំលុងពេល ០៣ឆ្នាំ នៃការចូលជាធរមានរបស់ AANZFTA។ ជាទូទៅ គណៈកម្មាធិការនេះក៏មានលទ្ធភាពទទួលយកនូវបណ្តាបញ្ហាដទៃទៀត ដែលទាក់ទងនឹងការអនុវត្ត ផ្នែកនេះនៅក្នុង FTA។

**សេវាហិរញ្ញវត្ថុ និងទូរគមនាគមន៍** ប្រភេទរបស់វិស័យសេវាហិរញ្ញវត្ថុ (ជាមួយនឹងលក្ខខណ្ឌប្រុងប្រយ័ត្ន និងច្បាប់ផ្សេងទៀត) និងវិស័យសេវាទូរគមនាគមន៍ (ដែលបញ្ហាទាក់ទងការបើកច្រកបណ្តាញ និងបញ្ហាប្រកួតប្រជែងមានសារៈសំខាន់) ជាញឹកញាប់ឃើញវិស័យទាំងពីរនេះ ត្រូវទទួលបាននូវប្រព្រឹត្តិកម្មពិសេសនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ AANZFTA គឺមិនខុសប្លែកគ្នាចំពោះចំណុចនេះ ហើយឧបសម្ព័ន្ធតាមវិស័យពិសេសត្រូវបានលើកឡើងសម្រាប់សេវាហិរញ្ញវត្ថុ និងទូរគមនាគមន៍។

**ការវិនិយោគ** (ជំពូក ១១ ក្នុង AANZFTA)

ពាណិជ្ជកម្ម និងការវិនិយោគមានទំនាក់ទំនងផ្សារភ្ជាប់មិនអាចប្រកែកបាននៅក្នុងពាណិជ្ជកម្មពិភពលោក។ មានការកើនឡើងនៅពេលប្រទេសដែលធ្វើការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទំនើប ត្រូវដាក់បញ្ចូលបទប្បញ្ញត្តិទាក់ទងនឹងការវិនិយោគ។ ជំពូក ១១ នៃ AANZFTA ស្តីពីការវិនិយោគ គឺមានលក្ខណៈឆ្លាយសន្លឹម និងមានអត្ថប្រយោជន៍ពាណិជ្ជកម្មជាច្រើនចំពោះការធ្វើធុរកិច្ចក្នុងតំបន់។

និយមន័យការវិនិយោគប្រើប្រាស់ក្នុង AANZFTA គឺមានលក្ខណៈទូលំទូលាយ និងពឹងផ្អែកលើទ្រព្យសកម្មមិនលំអិត។ សម្រាប់វិនិយោគគ្របដណ្តប់ AANZFTA ផ្តល់នូវការការពារចំពោះបណ្តាវិនិយោគិន រាប់បញ្ចូលទាំងលទ្ធភាពដោះស្រាយជម្លោះតាមរយៈសកម្មភាពដោះស្រាយជម្លោះរវាងវិនិយោគិន និងរដ្ឋ។ កាតព្វកិច្ចចម្បងរបស់ភាគីនានានៅក្នុង AANZFTA ទាក់ទងវិនិយោគគ្របណ្តប់រួមមាន :

- លក្ខខណ្ឌតម្រូវផ្តល់ប្រព្រឹត្តិកម្មត្រឹមត្រូវ និងស្មើភាពចំពោះវិនិយោគគ្របដណ្តប់ (មានន័យថាយុត្តិធម៌មិនអាចបដិសេធបាននៅក្នុងដំណើរការច្បាប់ និងរដ្ឋបាល ហើយថាការវិនិយោគនោះត្រូវបានផ្តល់ការការពារ និងសុវត្ថិភាពទាំងស្រុងអនុលោមតាមច្បាប់ទម្លាប់អន្តរជាតិ)។

- លក្ខខណ្ឌតម្រូវឲ្យចាត់ចែងវិនិយោគិនរបស់ភាគី AANZFTA ផ្សេងទៀតមិនឲ្យតិចជាងវិនិយោគិនក្នុងស្រុករបស់ខ្លួន ឬភាគីផ្សេងទៀត ឬមិនមែនភាគី ទាក់ទងនឹងសំណងសម្រាប់ការខាតបង់របស់ការវិនិយោគនានាដែលបណ្តាលមកពីជម្លោះប្រដាប់អាវុធ ការវិវាទស៊ីវិល និងការប្រកាសអាសន្ន។
- កាតព្វកិច្ចអនុញ្ញាតឲ្យមានការផ្ទេរដើមទុន ដោយសេរីទាក់ទងនឹងវិនិយោគគ្របដណ្តប់ដោយគ្មានការពន្យារពេលក្រោមលក្ខខណ្ឌនៃការលើកលែងខ្លះៗទាក់ទងនឹងបញ្ហាដូចជាពន្ធដារ ការការពារសិទ្ធិរបស់ម្ចាស់បំណុល និងការសើរើនូវដំណើរការបទឧក្រិដ្ឋ។ល។
- កាតព្វកិច្ចធានាថាជាតូបនីយកម្ម ឬការដកហូតការវិនិយោគ ត្រូវធ្វើឡើងដើម្បីផលប្រយោជន៍សាធារណៈ និងក្នុងលក្ខណៈមិនរើសអើង និងទូទាត់សំណងភ្លាមៗគ្រប់គ្រាន់ និងមានប្រសិទ្ធភាព ហើយត្រូវធ្វើឡើងតាមនីតិវិធីច្បាប់។

**ប្រអប់ ២: និយមន័យនៃការវិនិយោគរបស់ AANZFTA**

ការវិនិយោគមានន័យថាទ្រព្យសកម្មគ្រប់ប្រភេទដែលកាន់កាប់ ឬគ្រប់គ្រងដោយអ្នកវិនិយោគរួមមាន ប៉ុន្តែមិនកម្រិតកំណត់ទៅលើ :

- ចលនទ្រព្យ និងអចលនទ្រព្យ និងកម្មសិទ្ធិផ្សេងទៀតដូចជា អ៊ីប៉ូតែត(mortgages), liens និង ទ្រព្យបញ្ចាំ
- ភាគហ៊ុន មូលបត្រ bonds and debentures និងទម្រង់ផ្សេងទៀតដែលមានការចូលរួមពីជនដែលមានទោស
- កម្មសិទ្ធិបញ្ញាដែលទទួលស្គាល់ដោយច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីនីមួយៗ និងកេរ្តិ៍ឈ្មោះ
- សិទ្ធិទាមទាររូបិយវត្ថុ ឬការអនុវត្តកិច្ចសន្យាទាក់ទងនឹងអាជីវកម្មដែលមានតម្លៃហិរញ្ញវត្ថុ
- សិទ្ធិនានាក្រោមកិច្ចសន្យាដែលរួមមាន Turnkey ការសាងសង់ ការគ្រប់គ្រង ផលិតកម្ម និងកិច្ចសន្យាចែករំលែកចំណូល
- សម្បទានអាជីវកម្មដែលតម្រូវឲ្យធ្វើសកម្មភាពសេដ្ឋកិច្ច និងមានតម្លៃហិរញ្ញវត្ថុដែលមាន ចែងក្នុងច្បាប់ ឬកិច្ចសន្យា រួមមានសម្បទាននានាដើម្បីស្រាវជ្រាវ ដាំដុះ ចម្រាញ់យក និង យកផលពីធនធានធម្មជាតិ។

ដើម្បីគោលបំណងសម្រាប់និយមន័យនៃការវិនិយោគ (នៅក្នុងអត្ថបទនេះ) កម្រៃដែលត្រូវវិនិយោគ ត្រូវចាត់ទុកជាការវិនិយោគ និងការកែសម្រួលទម្រង់ណាមួយដែលទ្រព្យសកម្មត្រូវបានវិនិយោគ ឬវិនិយោគបន្ត មិនប៉ះពាល់លក្ខណៈនៃការវិនិយោគនោះឡើយ។

សម្គាល់: ពាក្យ "វិនិយោគ" មិនរាប់បញ្ចូលនូវ បញ្ជា ឬការវិនិច្ឆ័យដែលមាននៅក្នុងសកម្មភាព Juridical និងរដ្ឋបាល។ ការវិនិយោគមិនមែនជាការទាមទារនូវប្រាក់ដែលកើតចេញពី (ក) កិច្ច សន្យាពាណិជ្ជកម្មសម្រាប់លក់ទំនិញ និងសេវា ឬ(ខ) កាពង្រីកនូវឥណទានពាក់ព័ន្ធកិច្ចសន្យា ពាណិជ្ជកម្ម។

**កម្មវិធីការងារ** ដូចផ្នែកផ្សេងទៀតនៅក្នុង AANZFTA ដែលបានពិភាក្សាកន្លងមកនៅក្នុងមគ្គុទ្ទេសក៍នេះ ជំពូកវិនិយោគចាប់ផ្តើមឡើងដោយកម្មវិធីការងារដែលនឹងឃើញកិច្ចព្រមព្រៀងវិវត្តនៅពេលខាងមុខ។ មាត្រា ១៦ នៃជំពូកនេះ ចាប់ផ្តើមបង្កើតកម្មវិធីការងារ ដែលនឹងបញ្ចូលការពិភាក្សាលើកម្មវិធីនៃបញ្ហាបម្រុងទុក និងការបើកច្រកទីផ្សារក្នុងចំណោមបញ្ហាផ្សេងទៀត ។

**តម្លាភាព** អាជីវកម្មនឹងទទួលផលប្រយោជន៍ពីកាតព្វកិច្ចរបស់រដ្ឋាភិបាលនៃ AANZFTA ក្នុងការបោះផ្សាយ (រួមបញ្ចូលទាំងតាមអ៊ិនធឺណេត) នូវវិធានការពាក់ព័ន្ធទាំងអស់ដែលទាក់ទងនឹងការវិនិយោគ ក៏ដូចជាព័ត៌មានអំពីកិច្ចព្រមព្រៀងអន្តរជាតិដែលរដ្ឋាភិបាលទាំងនោះបានចូលរួម ហើយទាក់ទងនឹងការវិនិយោគ។ ក្នុងករណីដែលវិធានការថ្មីដែលទាក់ទងនឹងការវិនិយោគកំពុងស្ថិតក្រោមការពិចារណារដ្ឋាភិបាលនៃ AANZFTA ត្រូវបានរំពឹងថានឹងផ្តល់ឱកាសឲ្យភាគីពាក់ព័ន្ធផ្តល់អនុសាសន៍ មុនពេលវិធានការទាំងអស់នោះត្រូវបានអនុម័ត។

**ប្រព្រឹត្តិកម្មយុត្តិធម៌ក្នុងដំណើរការតាមផ្លូវរដ្ឋបាល** សិទ្ធិរបស់អាជីវករ និងក្រុមហ៊ុន ដែលស្ថិតក្រោមបទប្បញ្ញត្តិវិនិយោគរបស់ AANZFTA ត្រូវបានការពារយ៉ាងល្អនៅក្នុងដំណើរការរដ្ឋបាល។ រដ្ឋាភិបាលមានកាតព្វកិច្ចធានាថាវិនិយោគិននានាដែលទទួលរងនូវឥទ្ធិពលដោយផ្ទាល់ពីការអនុវត្តវិធានការ ដែលទាក់ទងនឹងការវិនិយោគ ត្រូវបានជូនដំណឹងអំពីការចាប់ផ្តើមនៃដំណើរការរដ្ឋបាល និងមានឱកាសសមស្របដើម្បីបង្ហាញពីគោលជំហររបស់ពួកគេលើបញ្ហានោះ។ រដ្ឋាភិបាលនៃ AANZFTA ក៏តម្រូវឲ្យរក្សានូវសាលាក្តី ឬនីតិវិធីរដ្ឋបាល ឬយុត្តិធម៌ ក្នុងគោលបំណងធ្វើការពិនិត្យឡើងវិញឆាប់រហ័ស និងការកែតម្រូវប្រសិនបើអាចធ្វើទៅបាន នូវសកម្មភាពរដ្ឋបាលចុងក្រោយដែលទាក់ទងនឹងបញ្ហាវិនិយោគ។ ភាគីនានានៃដំណើរការ ត្រូវបានផ្តល់ឲ្យនូវឱកាសសមស្របដើម្បីគាំទ្រ និងការពារគោលជំហររបស់ខ្លួន មានសិទ្ធិសម្រេចចិត្តអនុលោមតាមច្បាប់របស់ប្រទេស និងត្រូវបានផ្តល់ឱកាសឲ្យដាក់បណ្តឹងឧទ្ធរណ៍នូវលទ្ធផលអវិជ្ជមានទាំងឡាយ។

**វិនិយោគិន -ដំណោះស្រាយវិវាទរដ្ឋ** FTA ទទួលស្គាល់ថាអាចមានករណីមួយចំនួន ដែលវិនិយោគិនម្នាក់យកបញ្ហាទាក់ទងនឹងសកម្មភាពវិនិយោគរបស់ភាគីមួយក្នុងចំណោមភាគីនានា ទៅកាន់ AANZFTA។ បទប្បញ្ញត្តិលំអិត មានបង្ហាញពីរបៀបវិនិយោគិនគួរតែចាប់ផ្តើមកិច្ចការពិគ្រោះយោបល់ជាមួយនឹងរាជរដ្ឋាភិបាល និងពីរបៀបដែលវិនិយោគិនរៀបចំការទាមទារដែលអាចដាក់ស្នើមកដើម្បីផ្សះផ្សា និងមជ្ឈត្តនិច្ឆ័យ។ ក្នុងករណីជម្លោះកើតឡើងរវាងវិនិយោគិន និងរដ្ឋាភិបាលដែលចូលរួមក្នុង AANZFTA វិនិយោគិននោះមានជម្រើសយកនីតិវិធីដើម្បីដោះស្រាយជម្លោះ ដូចខាងក្រោម :

- ក្នុងករណីការប្តឹងតវ៉ាប្រឆាំងនឹងហ្វីលីពីន ឬវៀតណាម សាលាក្តីរបស់ភាគីទាំងនោះ
- ការប្តឹងក្រោម មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ដោះស្រាយនៃអនុសញ្ញាវិវាទវិនិយោគ (ICSID) និងវិធាន ICSID នៃនីតិវិធីដំណើរការក្តីមជ្ឈត្តនិច្ឆ័យ ប្រសិនបើទាំងភាគីមានវិវាទ និងភាគីមិនមានវិវាទជាភាគីនៃអនុសញ្ញា ICSID ឬ
- ការប្តឹងក្រោមវិធានយន្តការបន្ថែមនៃមជ្ឈមណ្ឌលអន្តរជាតិ សម្រាប់ដោះស្រាយវិវាទ (ICSID) ប្រសិនបើភាគីមានវិវាទ ឬភាគីមិនមានវិវាទ ជាភាគីនៃអនុសញ្ញា ICSID

- ការប្តឹងក្រោមគណៈកម្មការសហប្រជាជាតិស្តីពីវិធានមជ្ឈត្តវិនិច្ឆ័យច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL Arbitration Rules)
- ប្រសិនបើភាគីមានវិវាទយល់ព្រមទៅរកស្ថាប័នមជ្ឈត្តវិនិច្ឆ័យ ឬក្រោមវិធានមជ្ឈត្តវិនិច្ឆ័យដទៃទៀត

ជំពូកវិនិយោគក៏មានវិធានលំអិតទាក់ទងនឹងលក្ខខណ្ឌ និងការកម្រិតចំពោះការដាក់ការតវ៉ាទាមទារនៅក្នុងដំណោះស្រាយជម្លោះរវាងរដ្ឋ និងវិនិយោគិន វិធានសម្រាប់ជ្រើសរើសមជ្ឈត្តករ និងការប្រព្រឹត្តិរបស់មជ្ឈត្តវិនិច្ឆ័យ និងនីតិវិធីក្នុងការសម្រេច។

**កម្មសិទ្ធិបញ្ញា** (ជំពូក ១៣ នៃ AANZFTA)

**ការធ្វើបច្ចុប្បន្នភាព TRIPS** សម្រាប់ផ្នែកភាគច្រើន បទប្បញ្ញត្តិរបស់ AANZFTA ទាក់ទងកម្មសិទ្ធិបញ្ញា ដែលមាននៅក្នុងជំពូក ១៣ ជួយពង្រឹងឡើងវិញនូវកាតព្វកិច្ច និងសិទ្ធិនានារបស់បណ្តាភាគីនៅក្រោមកិច្ចព្រមព្រៀង WTO លើទិដ្ឋភាពទាក់ទងពាណិជ្ជកម្មនៃកម្មសិទ្ធិបញ្ញា (TRIPS)។ ទោះជាកិច្ចព្រមព្រៀង TRIPS ត្រូវបានបង្កើតពីឆ្នាំ១៩៩៣ FTA នៅតែខិតខំប្រឹងប្រែងធ្វើបច្ចុប្បន្នភាពការការពារកម្មសិទ្ធិបញ្ញាក្នុងតំបន់ ជាពិសេសតាមរយៈបទប្បញ្ញត្តិ ការសហការក្នុងគោលបំណងគាំទ្រជួយការឈានទៅមុខរបស់រដ្ឋាភិបាល និងការអនុវត្តនូវកិច្ចព្រមព្រៀងអន្តរជាតិស្តីពីកម្មសិទ្ធិបញ្ញាមួយចំនួន។ សារៈសំខាន់ចាំបាច់នានាចំពោះសហគមន៍អាជីវកម្មមានដូចខាងក្រោម :

- សន្ធិសញ្ញាសឹង្ហបុរី ស្តីពីពាណិជ្ជសញ្ញា ឆ្នាំ ២០០៦
- សន្ធិសញ្ញា សិទ្ធិថតចម្លង WIPO ឆ្នាំ ១៩៩៦; និង
- សន្ធិសញ្ញា WIPO ឆ្នាំ ១៩៩៦ ស្តីពីការសម្តែង និងថតចម្លង

**តម្លាភាព** ជំពូកកម្មសិទ្ធិបញ្ញា នៃ AANZFTA ក៏មានកាតព្វកិច្ចជាក់លាក់ជាច្រើនស្តីពីការការពារកម្មសិទ្ធិបញ្ញា និងការប្រើប្រាស់ប្រព័ន្ធទន់ របស់រដ្ឋាភិបាល និងតម្លាភាព។ អត្ថប្រយោជន៍ជាក់លាក់ចំពោះសហគមន៍អាជីវកម្ម គឺជាកាតព្វកិច្ច របស់រដ្ឋាភិបាលដើម្បីធានាថារាល់ច្បាប់ និងបទបញ្ញាទាំងអស់សម្រាប់អនុវត្តទូទៅដែលទាក់ទងនឹងវត្តមាន វិសាលភាព ការទិញយក ការអនុវត្ត និង ការបង្ការនៃការរំលោភកម្មសិទ្ធិបញ្ញា អាចរកបានជាសាធារណៈ យ៉ាងហោចណាស់ជាភាសាជាតិ ឬជាភាសាអង់គ្លេស។

**ប្រអប់៣ : ការបញ្ជាក់លិខិតយថាភូតតាមប្រព័ន្ធអេឡិចត្រូនិក និងវិញ្ញាបនបត្រឌីជីថល**

មាត្រា 5 នៃជំពូក១០ របស់ AANZFTA ផ្តល់ជូននូវ :

១. ភាគីនីមួយៗ ត្រូវរក្សា និងអនុម័តឲ្យបានឆាប់នូវវិធានការនានា ដោយផ្អែកលើបទដ្ឋានអន្តរជាតិនៃការបញ្ជាក់លិខិតយថាភូតតាមប្រព័ន្ធអេឡិចត្រូនិកដែល :

- អនុញ្ញាតឲ្យអ្នកប្រើប្រាស់ ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិច អាចកំណត់នូវបច្ចេកវិទ្យានៃការបញ្ជាក់លិខិតយថាភូត និងការអនុវត្តរូបមន្តដែលសមរម្យ សម្រាប់ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិករបស់ពួកគាត់
- មិនត្រូវកម្រិតនូវការទទួលស្គាល់បច្ចេកវិទ្យានៃការបញ្ជាក់លិខិតយថាភូត និងគំរូអនុវត្តន៍ឡើង និង
- អនុញ្ញាតឲ្យអ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក មានឱកាសដើម្បីបញ្ជាក់ថាទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិករបស់ខ្លួនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ភាគី។

២. ភាគីទាំងអស់ត្រូវព្យាយាមធ្វើការងារឆ្ពោះទៅរកការទទួលស្គាល់ទៅវិញទៅមកនូវវិញ្ញាបនបត្រឌីជីថល និងហត្ថលេខាអេឡិចត្រូនិកដែលចេញ ឬទទួលស្គាល់ដោយរដ្ឋាភិបាលដោយផ្អែកតាមស្តង់ដារអន្តរជាតិ។

៣. ភាគីទាំងអស់ ត្រូវលើកទឹកចិត្តឲ្យពាណិជ្ជករប្រើប្រាស់វិញ្ញាបនបត្រឌីជីថល ឱ្យបានទូលំទូលាយ។

តុលាការ និងរដ្ឋបាលដែលទាក់ទងនឹងការការពារកម្មសិទ្ធិបញ្ញា។ ព័ត៌មាននេះត្រូវផ្សព្វផ្សាយតាមអ៊ីនធឺណេត បើអាចធ្វើទៅបាន។ ភាគីទាំងអស់ក៏ត្រូវមានកាតព្វកិច្ចខិតខំប្រឹងប្រែងបង្កើតរាល់ប្រព័ន្ធទិន្នន័យទាំងអស់នៃពាណិជ្ជសញ្ញាដែលបានចុះបញ្ជី និងម៉ាកដែលបានព្យួរទុកនៅក្នុងយុត្តាធិការរបស់ខ្លួនដាក់តាមអ៊ីនធឺណេត។

**ពាណិជ្ជកម្មអេឡិចត្រូនិក** (ជំពូក ១០ នៃ AANZFTA)

ក្របខណ្ឌសម្រាប់សហប្រតិបត្តិការ និងសម្របសម្រួលស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ត្រូវបង្កើតឡើងក្នុងជំពូក ១០ នៃ AANZFTA ។ រដ្ឋាភិបាលមានកាតព្វកិច្ចរក្សា និងអនុម័តច្បាប់ និងបទបញ្ញាក្នុងស្រុកទាំងឡាយដែលគ្រប់គ្រងការចម្លងអេឡិចត្រូនិក ដោយពិចារណាទៅលើគំរូច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ឆ្នាំ ១៩៩៦ ដែលបង្កើតដោយ UNCITRAL។ ជាផ្នែកមួយនៃក្របខណ្ឌបទបញ្ញានេះ ប្រទេសជាដៃគូ AANZFTA ទាំងអស់នឹងរក្សា ឬរៀបចំវិធានការនានាសម្រាប់ការបញ្ជាក់លិខិតយថាភូតតាមប្រព័ន្ធអេឡិចត្រូនិក ការការពារអ្នកប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិក និងការការពារទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិក។

AANZFTA ក៏តម្រូវឲ្យរដ្ឋាភិបាលជាសមាជិកធ្វើការងារឆ្ពោះទៅរកការអនុវត្តគំនិតផ្តួចផ្តើម ក្នុងការធ្វើពាណិជ្ជកម្មដោយមិនប្រើប្រាស់ក្រដាសស្នាម។ ការធ្វើអាជីវកម្មក្នុងតំបន់នឹងទទួលបានផលប្រយោជន៍ពីកិច្ចព្រមព្រៀងដែលមានគោលបំណងទទួលយកនូវឯកសាររដ្ឋបាលពាណិជ្ជកម្មដោយប្រព័ន្ធអេឡិចត្រូនិក ដោយផ្អែកលើវិធីសាស្ត្រនានា ដែលទទួលស្គាល់នៅក្នុងអង្គការអន្តរជាតិ ដូចជាអង្គការគយពិភពលោក (WCO)។

តម្លាភាពនៅក្នុងពាណិជ្ជកម្មអេឡិចត្រូនិក ត្រូវបានលើកតម្កើងតាមរយៈកាតព្វកិច្ចនានា របស់ភាគីទាំងអស់ក្នុងការផ្សព្វផ្សាយ ឬឲ្យទៅជាសាធារណៈនូវវិធានការសម្រាប់អនុវត្តទូទៅដែលទាក់ទងពាណិជ្ជកម្មអេឡិចត្រូនិក និងធ្វើឲ្យឯកសាររដ្ឋបាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាចរកបានជាសាធារណៈ។

គំនិតផ្តួចផ្តើមទាំងអស់នេះ អាចជួយធានាថាតំបន់ AANZFTA គឺស្ថិតនៅក្នុងចំណោមតំបន់នាំមុខពិភពលោកក្នុងការលើកស្ទួយបរិយាកាសដែលអាជីវកម្មអាចទាញផលប្រយោជន៍ពីប្រសិទ្ធភាព និងការកាត់បន្ថយចំណាយ ពាក់ព័ន្ធនឹងពាណិជ្ជកម្មដែលមិនប្រើក្រដាសស្នាម និងពាណិជ្ជកម្មអេឡិចត្រូនិក។

**គោលនយោបាយប្រកួតប្រជែង** (ជំពូក ១៤ នៃ AANZFTA)

នៅក្នុងតំបន់ AANZFTA មានការខុសប្លែកគ្នាច្រើននៅក្នុងវិធីសាស្ត្ររបស់ប្រទេសនានា ចំពោះគោលនយោបាយប្រកួតប្រជែង ក៏ដូចជាគម្លាតឆ្ងាយរវាងសមត្ថភាព បច្ចេកទេសរបស់រដ្ឋាភិបាលនានាក្នុងការអនុម័ត និងរក្សារបបគោលនយោបាយប្រកួតប្រជែង។ នៅក្នុងលក្ខណៈនេះ AANZFTA មិនមានគោលបំណងបង្កើតនូវកាតព្វកិច្ចថ្មីៗចំពោះគោលនយោបាយប្រកួតប្រជែងក្នុងចំណោមសមាជិករបស់ខ្លួនទេ។ ផ្ទុយមកវិញ FTA បង្កើតក្របខណ្ឌមួយសម្រាប់សហប្រតិបត្តិការនៅពេលប្រទេសអូស្ត្រាលី និងប្រទេសណូវែលហ្សេឡង់អាចព្រមព្រៀងផ្តល់សហប្រតិបត្តិការដែលសមស្របក្នុងការជួយរដ្ឋាភិបាលសមាជិកអាស៊ាន នូវគំនិតផ្តួចផ្តើមទាក់ទងការប្រកួតប្រជែងដែលពួកគេសម្រេចអនុវត្ត។

**ការបំលាស់ទីបណ្តោះអាសន្ននៃធុរជន (ជំពូក ៩ នៃ AANZFTA)**

នៅក្នុងពិភពលោកសកលភាវូបនីយកម្មសព្វថ្ងៃ វាជាការចាំបាច់ក្នុងការបញ្ជូនអ្នកតំណាងអាជីវកម្មដើម្បីបំពេញការងាររយៈពេលខ្លីក្នុងទីផ្សារក្រៅប្រទេស ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មប្រកបដោយ

ប្រសិទ្ធភាពក្នុងទីផ្សារទាំងនេះ (ឧទាហរណ៍ ការចរចាចុះកិច្ចសន្យាលក់ផលិតផល ផ្តល់សេវា ទៅឲ្យអតិថិជន)។ ប្រភេទទូទៅនៃទម្លាប់ធុរកិច្ចនេះ ត្រូវបានទទួលស្គាល់ជាយូរមកហើយក្នុងកិច្ចព្រមព្រៀង WTO GATS និង FTA ថ្មីៗភាគច្រើន។ AANZFTA រួមបញ្ចូលទាំងកាតព្វកិច្ចទូទៅនានាទាក់ទងការបំលាស់ទីជាបណ្តោះអាសន្ននៃធុរជន និងកម្មវិធីនៃការសន្យាធ្វើឡើងដោយរដ្ឋាភិបាលនីមួយៗ ដែលចូលរួមក្នុង FTA ។

**ប្រអប់៨: ការបំលាស់ទីបណ្តោះអាសន្ននៃធុរជន នរណាត្រូវរាប់បញ្ចូល?**

ការសន្យានានាធ្វើឡើងក្រោម AANZFTA ប៉ះពាល់ជាទូទៅលើ :

- ភ្ញៀវជាធុរជន
- អ្នកតម្លើង ឬអ្នកផ្តល់សេវា
- ក្រុមប្រឹក្សាភិបាលនៃការិយាល័យកណ្តាល ដែលស្ថិតនៅក្នុងភាគីមួយ បង្កើតសាខាថ្មី ឬអ្នកតំណាងពាណិជ្ជកម្មផ្សេងទៀត ដែលមានទីតាំងស្ថិតនៅក្នុងភាគីនោះ
- បុគ្គលដែលត្រូវផ្លាស់ប្តូរខាងក្នុងសាជីវកម្មមួយ
- អ្នកផ្គត់ផ្គង់សេវាដែលជាប់កិច្ចសន្យា។

ក្នុងចំណោមកាតព្វកិច្ចទូទៅនានាដែលបង្កើតឡើងនៅក្នុងជំពូក AANZFTA ស្តីពីការបំលាស់ទីនៃធុរជន គឺមាននីតិវិធីពាក់ព័ន្ធការអនុញ្ញាតឱ្យចេញចូលបណ្តោះអាសន្ន ការពិនិត្យការដាក់ពាក្យស្នើសុំ និងតម្លាភាព។ FTA ក៏បានចែងយ៉ាងច្បាស់ថាមិនមានអ្វីក្នុងកិច្ចព្រមព្រៀងរំខានដល់សមត្ថភាពរបស់រដ្ឋាភិបាលមួយ ក្នុងការអនុវត្តគោលនយោបាយអន្តោប្រវេសន៍ក្នុងស្រុករបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

តាមនីតិក្រមរដ្ឋាភិបាល AANZFTA ទាំងអស់មានកាតព្វកិច្ចធានាថា កម្រៃយកលើបែបបទចេញចូលបណ្តោះអាសន្នគឺមានលក្ខណៈសមរម្យ ហើយពាក្យស្នើសុំត្រូវបានពិនិត្យយ៉ាងត្រឹមត្រូវ និងនៅក្នុងពេលសមរម្យមួយ។ ដើម្បីជួយអាជីវកម្មក្នុងការទាញយកអត្ថប្រយោជន៍ពីលទ្ធភាពក្នុងការធ្វើការបំលាស់ទីបណ្តោះអាសន្ននៃបុគ្គល ភាគីទាំងអស់ក្នុង AANZFTA មានកាតព្វកិច្ចផ្សព្វផ្សាយឯកសារពន្យល់ស្តីពីបែបបទអន្តោប្រវេសន៍ពាក់ព័ន្ធ និងលក្ខខណ្ឌសម្រាប់ការចេញចូលបណ្តោះអាសន្នស្របតាមបទប្បញ្ញត្តិរបស់ AANZFTA ។

ការសន្យាជាក់លាក់នានាដែលធ្វើដោយអូស្ត្រាលី និងណូវ៉ែលហ្សេឡង់ចំពោះការបំលាស់ទីបណ្តោះអាសន្ននៃរូបវន្តបុគ្គល ត្រូវបានកំណត់ក្នុងកម្មវិធីដែលមាននៅក្នុងឧបសម្ព័ន្ធ៩ នៃ AANZFTA ដែលអ្នកតំណាងអាជីវកម្មដែលមានចំណាប់អារម្មណ៍អាចពិគ្រោះយោបល់នៅក្នុង www.asean.org ។

## ផ្នែក ៣
## លក្ខណៈសម្រួលពាណិជ្ជកម្មសំខាន់ៗនៃ AANZFTA

ក្រៅពីឱកាសបើកច្រកទីផ្សារថ្មីៗសម្រាប់អ្នកនាំចេញអាស៊ាន ដែលត្រូវបានបង្កើតដោយការលុបនូវរបាំងពាណិជ្ជកម្មទំនិញ និងសេវា AANZFTA រួមបញ្ចូលនូវលក្ខណៈសំខាន់ជាច្រើនដែលត្រូវបានបង្កើតឡើងដើម្បីបង្កលក្ខណៈងាយស្រួល និងចំណាយតិចក្នុងការធ្វើពាណិជ្ជកម្មក្នុងតំបន់។ វិធានដើមកំណើតដែលទន់ភ្លន់ និងទំនើប នីតិវិធីគយដែលសាមញ្ញ និងការពង្រឹងនូវតម្លាភាព គឺជាលក្ខណៈសម្រួលពាណិជ្ជកម្មសំខាន់មួយចំនួននៃ FTA ។

**វិធានដើមកំណើត** (ជំពូក ៣ នៃ AANZFTA)

វិធានដើមកំណើតដែលអនុវត្តនៅក្នុង AANZFTA បានត្រូវរៀបចំឡើងដើម្បីជួយជំរុញលទ្ធភាពរបស់អ្នកនាំចេញក្នុងការឆក់យកបណ្តាឱកាសនៅក្នុង FTA តាមរយៈការផ្តល់អ្នកនាំចេញនូវជម្រើសវិធីសាស្ត្រពីរ សម្រាប់ធ្វើការសាកល្បងលើដើមកំណើតនៃទំនិញភាគច្រើនប្រមាណ ៨៣% នៃបន្ទាត់ពន្ធកម្រិត ៦ខ្ទង់ (sub-heading) ទាំងអស់វិធានដើមកំណើតក្នុង AANZFTA ឈរលើមូលដ្ឋានគោលការណ៍សហសមភាព ដែលអ្នកនាំចេញត្រូវបានផ្តល់ជម្រើសក្នុងការបំពេញវិធាន regional value content (RVC) ឬវិធាន ហៅថា Change in Tariff classification (CTC)។ ចំណែកឯ sub-heading ១០% ទៀតអនុវត្តតែវិធីសាស្ត្រ CTC ប៉ុណ្ណោះ និងប្រហែល ១% នៃ sub-heading (ផ្តោតលើវិស័យយានយន្ត) អនុវត្តតែវិធាន RVC។ កាកសំណល់ និងផលិតផលសំណល់មានប្រហែលជា ១.៤% នៃ sub-heading អនុវត្តវិធានពិសេស។ វិធានដើមកំណើតលើផលិតផលជាក់លាក់ធម្មតា មិនពាក់ព័ន្ធនឹង sub-heading ដែលនៅសល់ ៤.៥% ដោយសារផលិតផលនៅក្នុង sub-heading ទាំងនេះ តម្រូវឲ្យផលិត ឬកកើតទាំងស្រុងនៅក្នុងតំបន់ AANZFTA។ ប្រហែល ២ ភាគ ៣ នៃ sub-heading សារធាតុគីមីនឹងត្រូវប្រើប្រាស់សម្រាប់ធ្វើការសាកល្បងប្រតិកម្មគីមី ដើម្បីបង្ហាញថាវាជាទំនិញដើមកំណើត ប្រសិនបើទំនិញទាំងនោះមិនបានបំពេញទៅតាមវិធានដើមកំណើត RVC ឬ CTC។

ភាពទន់ភ្លន់នៅក្នុងការអនុវត្តវិធានដើមកំណើត AANZFTA ត្រូវបានជំរុញថែមទៀត ដោយសារវិធានដើមកំណើត AANZFTA ផ្តល់នូវការប្រមូលផ្តុំធាតុចូលក្នុងការគិត ដើម្បីកំណត់ភាពទទួលបានប្រព្រឹត្តិកម្មអនុគ្រោះ ត្រូវបានរំពឹងថាមានអត្ថប្រយោជន៍សម្រាប់វិស័យកម្មន្តសាល ព្រោះវានឹងជួយគាំទ្រការធ្វើសមាហរណកម្មកាន់តែខ្លាំងឡើងទៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ក្នុងតំបន់។ នៅក្នុងរបបវិធាន

ដើមកំណើត AANZFTA បណ្តាវត្ថុធាតុដើម និងសមាសភាពមានដើមកំណើតពីប្រទេសសមាជិក AANZFTA ណាមួយដែលត្រូវបានយកទៅប្រើក្នុងការផលិតទំនិញនៅក្នុងប្រទេសសមាជិក AANZFTA មួយទៀត វត្ថុធាតុដើម និងសមាសភាពទាំងនោះ ត្រូវបានចាត់ទុកដូចជាវត្ថុធាតុដើម និងសមាសភាពមកពីប្រទេសផលិតនោះ ក្នុងការកំណត់ដើមកំណើតនៃផលិតផលសម្រេច។ ឧទា-ផលិតករក្នុងប្រទេសវៀតណាមអាចចាត់ទុក សមាសភាពនាំចូលពីសឹង្ហបុរី និងម៉ាឡេស៊ីថាជាសមាសភាពរបស់ប្រទេសខ្លួន នៅក្នុងការគណនាពីភាពអាចទទួលបានពន្ធអនុគ្រោះនៃផលិតផលសម្រេចរបស់ខ្លួន ដើម្បីបំពេញលក្ខខណ្ឌរបស់វិធានដើមកំណើត នៅពេលនាំចេញទៅកាន់ភាគីមួយក្នុង AANZFTA។

ដើម្បីចូលរួមចំណែកក្នុងការជួយអ្នកនាំចេញ និងផលិតករឲ្យយល់ច្បាស់អំពីវិធានដើមកំណើត នៃ AANZFTA លេខាធិការដ្ឋានអាស៊ាន បានផលិតសៀវភៅណែនាំអាជីវកម្មដាច់ដោយឡែក ដែលផ្តោតលើតែវិធានដើមកំណើត។

**ការសម្រួលពាណិជ្ជកម្ម នៅក្នុង AANZFTA** (ជំពូក៤ នៃ AANZFTA)

បរិយាកាសពាណិជ្ជកម្មមួយប្រកបដោយប្រសិទ្ធភាព តម្លាភាព និងអាចព្យាករបាន ផ្អែកលើបទដ្ឋានស្តង់ដារ និងទម្លាប់ល្អដែលទទួលស្គាល់ដោយអន្តរជាតិ ក៏ដូចជាសាមញ្ញកម្មនីតិវិធីគយ និងការកាត់បន្ថយចំណាយលើប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ នឹងចូលរួមចំណែកបង្កើតបរិកាសប្រកួតប្រជែងដល់ការធ្វើអាជីវកម្ម។

AANZFTA មានជំពូកមួយនិយាយអំពីនីតិវិធីគយ ដែលគោលបំណងរបស់វារួមមាន៖ ការធានាឲ្យបាននូវភាពអាចព្យាករណ៍ សង្គតភាព និងតម្លាភាព នៅក្នុងការអនុវត្តច្បាប់ និងបទបញ្ញាគយរបស់ភាគីនីមួយៗ លើកកម្ពស់ប្រសិទ្ធភាព និងសម្ញៃភាពនៃការគ្រប់គ្រងនីតិវិធីគយ និងការបញ្ចេញទំនិញពីគយឆាប់រហ័ស និងការធ្វើឲ្យនីតិវិធីគយមានលក្ខណៈងាយស្រួល។

ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ បណ្តាសកម្មភាពជាច្រើនត្រូវបានភាគីទាំងអស់ សន្យាអនុវត្ត។ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពទាំងអស់នោះ នឹងចូលរួមជួយពាណិជ្ជកម្មអាស៊ានជាមួយអូស្ត្រាលី និងណូវ៉ែលហ្សេឡង់ និងបង្កើតបរិយាកាសអាជីវកម្មមួយដែលមានលក្ខណៈប្រកួតប្រជែង។

- ភាគីនីមួយៗ ត្រូវធានានូវភាពអាចព្យាករណ៍បាន សង្គតភាព និងតម្លាភាព និងសម្រួលពាណិជ្ជកម្ម រួមទាំងការបញ្ចេញទំនិញពីគយឲ្យបានរហ័សទាក់ទងការអនុវត្ត និងនីតិវិធី

គយ។ នីតិវិធីគយរបស់រដ្ឋាភិបាល AANZFTA នឹងត្រូវពឹងផ្អែកលើស្តង់ដារ និងទម្លាប់ជាអនុសាសន៍របស់ WCO ប្រសិនបើអាច និងក្នុងកម្រិតអនុញ្ញាតដោយច្បាប់គយរបស់ខ្លួន។ ការពិនិត្យឡើងវិញនូវនីតិវិធីគយដោយរដ្ឋបាលគយរបស់ភាគីនីមួយៗ ក្នុងគោលបំណងធ្វើឲ្យនីតិវិធីនេះមានលក្ខណៈងាយស្រួល ក៏ជាផ្នែកមួយក្នុងការសន្យាដែលមានចែងនៅក្នុង AANZFTA ដើម្បីសម្រួលពាណិជ្ជកម្ម។

- ចំពោះការកំណត់តម្លៃទំនិញ ភាគីទាំងអស់សន្យាកំណត់តម្លៃគិតពន្ធគយនៃទំនិញស្របតាមបណ្តាបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង WTO ស្តីពីការកំណត់តម្លៃគិតពន្ធគយ។

- ដៃគូ AANZFTA នឹងពិចារណាលើការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តដែលជួយគាំទ្រប្រតិបត្តិការអេឡិចត្រូនិករបស់គយ ស្របតាមស្តង់ដារ និងទម្លាប់ល្អបំផុតណែនាំដោយ WCO និងស្របតាមសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធមានស្រាប់របស់ភាគីនីមួយៗ។

- ការសម្រេចជាមុន អនុលោមតាមបទប្បញ្ញត្តិនេះ ភាគីនីមួយៗ តាមរយៈរដ្ឋបាលគយរបស់ខ្លួន ផ្តល់ការសម្រេចជាលាយលក្ខណ៍អក្សរស្តីពីការចាត់ចំណាត់ថ្នាក់ពន្ធគយ ដើមកំណើត និងការកំណត់តម្លៃគិតពន្ធគយបើអាចទៅបាន។ ការដាក់បញ្ចូលការសម្រេចជាមុននេះ មានសារៈសំខាន់ក្នុងការផ្តល់ភាពទៀងទាត់ដល់ពាណិជ្ជករពាក់ព័ន្ធប្រព្រឹត្តិកម្មមុខទំនិញជាក់លាក់ដោយគយ មុនពេលមុខទំនិញនោះត្រូវនាំចូល។ មួយវិញទៀត វានឹងជួយកាត់បន្ថយការយឺតយ៉ាវ ការត្អូញត្អែរ និងការតវ៉ា។

- បទប្បញ្ញត្តិស្តីពីការគ្រប់គ្រងហានិភ័យក៏ត្រូវបានបញ្ចូលទៅក្នុង AANZFTA ផងដែរ។ មានការឯកភាពគ្នាថា ដើម្បីជំរុញលំហូរទំនិញឆ្លងកាត់ព្រំដែន រដ្ឋបាលគយរបស់ភាគីនីមួយៗត្រូវត្រួតពិនិត្យនីតិវិធីគយរបស់ខ្លួនជាប្រចាំ។ ដូច្នេះ ប្រសិនបើរដ្ឋបាលគយរបស់ភាគីមួយចាត់ទុកថា ការត្រួតពិនិត្យទំនិញនៅតាមប៉ុស្តិ៍រដ្ឋបាលគយមិនចាំបាច់ទេ ក្នុងការបញ្ចេញទំនិញពីគយ ភាគីនេះត្រូវខិតខំប្រឹងប្រែងផ្តល់ចំណុចមួយសម្រាប់ការពិនិត្យឯកសារ ឬការពិនិត្យដោយអេឡិចត្រូនិកនៃទំនិញទាំងអស់នោះ។

- AANZFTA ក៏មានមាត្រានិយាយអំពី ចំណុចផ្តល់ព័ត៌មានដែលត្រូវបានបង្កើតឡើង ដើម្បីសម្រួលការប្រឹក្សា និងការផ្លាស់ប្តូរព័ត៌មាន។ មាត្រានេះចែងថាភាគីនីមួយៗ ត្រូវបង្កើតចំណុចផ្តល់ព័ត៌មានមួយ ឬច្រើនដើម្បីដោះស្រាយនូវរាល់ចម្ងល់របស់បុគ្គលពាក់ព័ន្ធដល់បញ្ហាគយនានា ហើយត្រូវផ្តល់ព័ត៌មានតាមប្រព័ន្ធអ៊ិនធឺណេត និង/ឬប្រព័ន្ធផ្សព្វផ្សាយតាម

ការបោះពុម្ពនានាផ្សេងទៀតនូវព័ត៌មានពាក់ព័ន្ធ និងនីតិវិធីសម្រាប់ធ្វើការសាកសួរ ។ ម្យ៉ាងវិញទៀត មាត្រានេះក៏បានផ្ដល់អំណាចឲ្យភាគីនីមួយៗ ត្រូវធ្វើការផ្សព្វផ្សាយតាមរយៈអ៊ិនធឺណេត និង/ឬប្រព័ន្ធផ្សព្វផ្សាយតាមការបោះពុម្ពនានា នូវបទប្បញ្ញត្តិច្បាប់ និងបទបញ្ជា និងបណ្ដានីតិវិធីរដ្ឋបាលគយដែលអនុវត្តដោយរដ្ឋបាលគយរបស់ខ្លួន។

- បទប្បបញ្ញត្តិស្ដីពីការពិនិត្យឡើងវិញ និងការប្ដឹងតវ៉ាត្រូវបានបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីនេះ។ ឈរលើទស្សនៈពាណិជ្ជកម្ម វាគឺជាបញ្ហាសំខាន់មួយ ព្រោះថាអ្នកនាំចូលនៅក្នុងដែនរបស់ភាគី AANZFTA នឹងត្រូវបានធានាអំពីការស្នើសុំឲ្យមានការត្រួតពិនិត្យឡើងវិញដោយរដ្ឋបាល និង/ឬតុលាការ។ FTA ក៏បានផ្ដល់ជូនទៅបុគ្គលដើមបណ្ដឹងផងដែរ នូវសេចក្ដីសម្រេចបណ្ដឹងឧទ្ធរណ៍ និងហេតុផលនៃសេចក្ដីសម្រេចនោះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

រាល់បណ្ដាសកម្មភាពទាំងឡាយនៅក្នុង AANZFTA ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយសម្រួលពាណិជ្ជកម្ម នឹងចូលរួមចំណែកធ្វើឲ្យមានរបបមួយដែលមានលក្ខណៈសេរីឆាប់រហ័ស និងចំណាយតិចជាង សម្រាប់ការនាំចូល និងនាំចេញនៅក្នុងតំបន់។

## ផ្នែកទី៤
## ឱកាសឈានទៅរកទីផ្សារថ្មី

### ឱកាសពាណិជ្ជកម្មទំនិញ

មុនពេល EIF នៃ AANZFTA ជិត ៩៨ភាគរយ នៃពន្ធ MFN ទាំងអស់របស់ប្រទេសអូស្ត្រាលីដែលត្រូវបានអនុវត្តលើអាស៊ានត្រូវបានលើកលែង និង ៥៩ភាគរយ នៃបន្ទាត់ពន្ធរបស់ណូវែលហ្សេឡង់ទាំងអស់បានត្រូវលើកលែងពន្ធនាំចូល។ ចំណែក ៣៩ភាគរយ នៃពន្ធរបស់ប្រទេសអូស្ត្រាលី និង ៧ ភាគរយ ផ្សេងទៀតនៃពន្ធរបស់ប្រទេសណូវែលហ្សេឡង់មានអត្រាតិចជាង ៥ភាគរយ ផ្អែកលើតម្លៃ។

**តារាងទី១**

**ព័ត៌មានសង្ខេបអំពីលទ្ធផលលុបពន្ធនាំចូលរបស់ប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់**

| ប្រទេស | មូលដ្ឋានពន្ធ ២០០៥ (%) | ២០១០ (%) | ២០១៣ (%) | លុបពន្ធនាំចូលចុងក្រោយ (%) | ឆ្នាំសម្រេចបាន |
|---|---|---|---|---|---|
| អូស្ត្រាលី | ៩៧.៦ | ៩៦.៩ | ៩៦.៥ | ១០០ | ២០២០ |
| ណូវែលហ្សេឡង់ | ៥៦.៦ | ៨៩.៧ | ៩០.៣ | ១០០ | ២០២០ |

ប្រភព: DFAT អូស្ត្រាលី មគ្គុទ្ទេសក៍អូស្ត្រាលីសម្រាប់ AANZFTA

តារាងនេះបានបង្ហាញអំពីចំនួនបន្ទាត់ពន្ធជាមួយនឹងប្រព្រឹត្តិកម្មមិនជាប់ពន្ធ MFN នៅក្នុងឆ្នាំមូលដ្ឋាន(២០០៥) និងជាមួយប្រព្រឹត្តិកម្មមិនជាប់ពន្ធនៅក្នុង AANZFTA ក្នុងឆ្នាំ ២០១០ និង ២០១៣ រួមជាមួយនឹងចុងបញ្ចប់នៃកំលុងពេលអន្តរកាលនៃការលុបពន្ធនាំចូលទាំងស្រុង។

## តារាង២

## ភាគរយបន្ទាត់ពន្ធដែលមានអត្រាពន្ធក្នុងចន្លោះរវាង 0 ទៅ ៥%

| ប្រទេស | មូលដ្ឋានពន្ធ ២០០៥ (%) | ២០១១ (%) | ២០១៣ (%) | ២០១៧ (%) | ២០២០ (%) | ២០២៥ (%) |
|---|---|---|---|---|---|---|
| អូស្ត្រាលី | ៨៦.២ | ៩៦.៧ | ៩៦.៨ | ៩៧.៦ | ១០០ | ១០០ |
| ណូវ៉ែលហ្សេឡង់ | ៦៥.៤ | ៩១.៣ | ៩៤.៦ | ៩៨.៣ | ១០០ | ១០០ |

ប្រភព: DFAT អូស្ត្រាលី មគ្គុទ្ទេសក៍អូស្ត្រាលីសម្រាប់ AANZFTA

តារាងទី២នេះបង្ហាញអំពីបន្ទាត់ពន្ធរបស់ប្រទេសនីមួយៗ ក្នុងចន្លោះរវាង 0% ទៅ ៥% (ឧទាហរណ៍ ពន្ធទាំងឡាយណាដែលស្មើសូន្យ ឬនៅកម្រិតទាប ពន្ធទាំងអស់នោះមិនអាចដាក់កម្រិតកំណត់ពាណិជ្ជកម្មបានឡើយ) នៅក្នុងឆ្នាំមូលដ្ឋាន (២០០៥) ក្នុងឆ្នាំ ២០១១ ២០១៣ ២០១៧ ២០២០ និង ២០២៥។

ក្នុងចំណោមបណ្តាវិស័យដែលនឹងធ្វើសេរីភាវូបនីយកម្មច្រើនបំផុត បន្ទាប់ពី AANZFTA ចូលជាធរមានសម្រាប់អូស្ត្រាលី និងណូវ៉ែលហ្សេឡង់ រួមមាន:

១- ទឹកផ្លែឈើ និងបន្លែ បន្លែ និងផ្លែឈើកែច្នៃ និងរក្សាទុកបានយូរ (HS 20)

២- កប្បាស (HS 52)

៣- រ៉ែ និងប្រេង (HS 25-27)

៤- គ្រឿងម៉ាស៊ីន (HS 84)

៥- គ្រឿងម៉ាស៊ីនដើរដោយអគ្គិសនី (HS 85)

៦- ប្លាស្ទិក និងផលិតផលប្លាស្ទិក (HS 39)

៧- ជ័រកៅស៊ូ (HS 40)

៨- វាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌ (HS 50, 5108-5113, 5207-5212, 53-60,)

៩- សម្លៀកបំពាក់ និងស្បែកជើង (HS 61, 62, 64)

១០- យានយន្តសម្រាប់អ្នកធ្វើដំណើរ (HS 8703)

១១- យានយន្តសម្រាប់ដឹកជញ្ជូនទំនិញ (HS 8704)

១២- គ្រឿងសង្ហារិម (HS 94)

## ការធ្វើសេរីភាវូបនីយកម្មតាមវិស័យ

នៅក្នុងវិស័យខាងក្រោមនៃសៀវភៅណែនាំនេះ កម្មវិធីកាត់បន្ថយ និងលុបពន្ធនាំចូលសម្រាប់ អូស្ត្រាលី និងណូវែលហ្សេឡង់ ត្រូវយកមកពិភាក្សាក្នុងទស្សនៈជួយអាជីវកម្មអាស៊ានក្នុងការ កំណត់យកឱកាសថ្មីដើម្បីនាំចេញទៅកាន់ទីផ្សារទាំងអស់នោះ។

### កសិកម្ម

**១. ទឹកផ្លែឈើ និងបន្លែ បន្លែ និងផ្លែឈើកែច្នៃ និងរក្សាទុកបានយូរ (HS 20)**

អូស្ត្រាលីនាំចូលផលិតផលទាំងអស់មានតម្លៃប្រហែល ៥២.៦លានដុល្លារ ពីអាស៊ាន (គិតជាមធ្យម ចាប់ពីឆ្នាំ ២០០៦ ដល់ ២០០៨)។ វាជាទីផ្សារដ៏ធំមួយ និងមានសក្តានុពលខ្ពស់សម្រាប់អ្នកនាំចេញ របស់អាស៊ាន។ អូស្ត្រាលីនាំចូលផលិតផលទាំងអស់នេះពីទីផ្សារពិភពលោកមានតម្លៃជាមធ្យម ៥៥០.៦ លានដុល្លារជារៀងរាល់ឆ្នាំ។ បន្ទាត់ពន្ធភាគច្រើនរបស់អូស្ត្រាលីមានអត្រាពន្ធ ៥% ដែល នឹងត្រូវលុបនៅពេល EIF ក្នុងឆ្នាំ ២០១០។

ដោយឡែកណូវែលហ្សេឡង់នាំចូលផលិតផលទាំងអស់នេះ ពីអាស៊ានគិតជាមធ្យមចន្លោះឆ្នាំ ២០០៦ ដល់ ២០០៨ មានតម្លៃ ប្រមាណ ១១.៨លានដុល្លារ និងនាំចូលពីទីផ្សារពិភពលោកនូវ ផលិតផលទាំងអស់នេះមានតម្លៃប្រហែល ១៨២លានដុល្លារ ក្នុងមួយឆ្នាំ។ នៅណូវែលហ្សេឡង់ បន្ទាត់ពន្ធក្នុងវិស័យនេះមានអត្រាពន្ធ ៥% និង ៧% ដែលនឹងត្រូវលុបក្នុងឆ្នាំ ២០១០។

### អូស្ត្រាលី

- ទឹកបន្លែ និងផ្លែឈើ: ពន្ធគយកំណត់ជាប់ 0% នៅពេល EIF លើកលែងបន្ទាត់ពន្ធដែល យកពន្ធ ៥% នឹងត្រូវលុបក្នុងឆ្នាំ២០១០ (ទឹកក្រូចច្របាច់បង្កក និងទឹកបន្លែ និងផ្លែឈើដទៃ ទៀត)
- បន្លែ និងផ្លែឈើកែច្នៃ និងរក្សាទុកបានយូរ ពន្ធកំណត់ជាប់ 0% នៅពេល EIF លើកលែង បន្ទាត់ពន្ធដែលជាប់ពន្ធ ៥% នឹង ត្រូវលុបក្នុងឆ្នាំ ២០១០ (បន្លែស្ងើសាច់ និងបន្លែរក្សាទុក យូរ និងបន្លែលាយគ្នាច្រើនមុខ)

**ណូវ៉ែលហ្សេឡង់**

- ទឹកបន្លែ និងផ្លែឈើ: ពន្ធទាំងអស់ត្រូវលុបនៅពេល EIF លើកលែងបន្ទាត់ពន្ធ ( មួយមានអត្រា ៥% និងមួយទៀតមានអត្រា ៧%) ដែលពន្ធទាំងពីរនេះត្រូវលុបនៅឆ្នាំ ២០១០ (HS 2009.90.21 & HS 200.80.21)
- បន្លែ និងផ្លែឈើកែច្នៃ និងរក្សាទុកបានយូរ ពន្ធត្រូវលុបនៅពេល EIF លើកលែង ០៣បន្ទាត់ពន្ធ ក្នុងចំណោមនោះ បន្ទាត់ពន្ធមានអត្រាពន្ធ ៥% (ដែលត្រូវលុបនៅឆ្នាំ ២០១០)។

**២. កប្បាសរួមមាន ចេស អំបោះ និងក្រណាត់ (HS 52)**

អូស្ត្រាលីនាំចូលកប្បាសពីអាស៊ានមានតម្លៃ ១០.៣ លានដុល្លារ ជារៀងរាល់ឆ្នាំ ( គិតជាមធ្យមក្នុងមួយឆ្នាំក្នុងចន្លោះ ឆ្នាំ ២០០៦ ដល់ ២០០៨) និងនាំចូលសរុបទូទាំងពិភពលោកប្រហែល ១១២.៤ លានដុល្លារ។ បន្ទាត់ពន្ធភាគច្រើន នៅអូស្ត្រាលីត្រូវបានអនុវត្តនៅអត្រា ៥% ឬ ១០%។ បន្ទាត់ពន្ធតិចតួចបំផុតដែលមិនជាប់ពន្ធ ( ៥ ក្នុងចំណោម ១៣៩បន្ទាត់ពន្ធ)។ ពន្ធទាំងអស់នៅក្នុងក្រុមផលិតផលនេះនឹងត្រូវលុបចាប់ពីឆ្នាំ ២០១០ លើកលែងបន្ទាត់ពន្ធពីរដែលនៅរក្សា១០%។

| | |
|---|---|
| 5208 | ក្រណាត់ត្បាញពីកប្បាស មានកប្បាស ៨៥% ឬច្រើនជាង ទម្ងន់មិនលើសពី ២០០ ក្រាម/ម២ |
| 5208.52.00 | -- ត្បាញលាត ទម្ងន់មិនលើសពី ១០០ក្រាម/ម២ |

| | |
|---|---|
| 5209 | ក្រណាត់ត្បាញពីកប្បាស មានកប្បាស ៨៥% ឬច្រើនជាង, ទម្ងន់មិនលើសពី ២០០ ក្រាម/ម២ |
| 5209.22.00 | -- ក្រណាត់អំបោះ ៣ ឬ៤ សរសៃរួមបញ្ចូលទាំងអំបោះ cross twill |

ពន្ធនៃបន្ទាត់ពន្ធទាំងពីរខាងលើនេះនឹងត្រូវកាត់មកត្រឹម ៨% ក្នុងឆ្នាំ ២០១១ មក ៥% ក្នុងឆ្នាំ ២០១០ និង 0% ក្នុង ឆ្នាំ ២០១៥។

ការលុបពន្ធនាំចូលក្នុងវិស័យនេះនឹងបង្កើតឲ្យមានឱកាសមួយដ៏ល្អសម្រាប់អ្នកនាំចូលកប្បាសរបស់អាស៊ានដែលមានបំណងស្វែងរកទីផ្សារអូស្ត្រាលី។

ណូវ៉ែលហ្សេឡង់នាំចូលកប្បាសមានតម្លៃស្មើ ២.៩ លានដុល្លារ ជារៀងរាល់ឆ្នាំពីអាស៊ាន និង នាំចូលទូទាំងពិភពលោកសរុបមានតម្លៃប្រមាណ ៣២លានដុល្លារ ក្នុងមួយឆ្នាំ។ រាល់បន្ទាត់ពន្ធទាំងឡាយក្នុងក្រុមផលិតផលនេះនៅណូវ៉ែលហ្សេឡង់ពុំមានជាប់ពន្ធទេ។

## ធនធាន និងទំនិញឧស្សាហកម្ម

### ៣. គ្រឿងម៉ាស៊ីន (HS 84)

អូស្ត្រាលីនាំចូលគ្រឿងម៉ាស៊ីនពីអាស៊ានក្នុងមួយឆ្នាំ (គិតជាមធ្យមក្នុងចន្លោះឆ្នាំ ២០០៦ ដល់ ២០០៨) មានតម្លៃ ៣.៧ ពាន់លានដុល្លារ និងនាំចូលពីបណ្តាប្រទេសនានាលើពិភពលោកសរុបមានចំនួន ២៤ ពាន់លានដុល្លារ។ ពន្ធភាគច្រើនលើគ្រឿងម៉ាស៊ីនចូលមកអូស្ត្រាលីមានកម្រិត 0% និង ៥% និងបន្ទាត់ពន្ធតិចតួចប៉ុណ្ណោះដែលយកពន្ធ ១០%។

### អូស្ត្រាលី

- ពន្ធមូលដ្ឋានឆ្នាំ ២០០៥ (៦១៤ បន្ទាត់ពន្ធ)
  - 0% លើ ២៦៩ បន្ទាត់ពន្ធ
  - ៥% លើ ៣០៨ បន្ទាត់ពន្ធ
  - ១០% លើ ៣៧ បន្ទាត់ពន្ធ

- ពន្ធទាំងអស់នេះនឹងត្រូវលុប លើកលែង ៣បន្ទាត់ ក្នុងឆ្នាំ ២០១០ ដែលនឹងត្រូវលុបទាំងអស់ក្នុងឆ្នាំ ២០២០។
  - ពន្ធ 0% នឹងត្រូវកំណត់នៅពេល EIF
    - រួមទាំង ទូប៊ីនរ៉េអាក់ស្យុង ទូប៊ីនខ្យល់ គ្រឿងម៉ាស៊ីនកសិកម្ម។
  - ពន្ធ ៥% នឹងត្រូវលុបនៅពេល EIF (២៤០ បន្ទាត់) ក្នុងឆ្នាំ ២០១០ (៦៥ បន្ទាត់)
    - លើកលែង ៣បន្ទាត់ពន្ធរក្សា ៥% ដដែលមុននឹងត្រូវបានកាត់បន្ថយមក 0% ក្នុងឆ្នាំ ២០២០។ បន្ទាត់ពន្ធទាំង ៣ នេះគ្របដណ្តប់លើគ្រឿងម៉ាស៊ីនដូចជា ម៉ាស៊ីនស្ទូច និងលើកដាក់ទំនិញ ម៉ាស៊ីនច្របាច់ បំបែក កិន រើស វែង ពង្រាបសម្រាប់វាយបញ្ចូលគ្នា ឬសម្រាប់រឹត និងម៉ាស៊ីនវែង ជ្រើសរើស ឬលាង។
  - ពន្ធ ១០% ដែលនឹងត្រូវលុបនៅពេល EIF
    - រួមមានផលិតផលដូចជា បាដាងប្រើគ្រាប់មូល ដែលជាសមាសធាតុប្រើប្រាស់សម្រាប់យានយន្តអ្នកធ្វើដំណើរ ម៉ាស៊ីនត្រជាក់ឡាន និងសន្ទះបន្ថយសម្ពាធ។

**ណូវ៉ែលហ្សេឡង់**

គ្រឿងម៉ាស៊ីនជាប្រភេទមុខទំនិញមួយក្នុងចំណោមមុខទំនិញទាំង ២០ ដែលណូវ៉ែលហ្សេឡង់នាំចូលច្រើនបំផុតពីអាស៊ាន ដែលមានតម្លៃជាមធ្យម ៩៩២ លានដុល្លារ ក្នុងមួយឆ្នាំ និងនាំចូលពីបណ្តាប្រទេសនានាលើសកលលោកសរុបមាន ចំនួនប្រហែល ៣.៩ ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ។

បន្ទាត់ពន្ធជាងពាក់កណ្តាលក្នុងក្រុមផលិតផលនេះមានអត្រា ៧% (រួមមានផលិតផលដូចជា ឆ្នាំងចំហាយទឹក ម៉ាស៊ីនត្រជាក់ ចង្ក្រានឧស្សាហកម្ម ទូរទឹកកក ឧបករណ៍បង្កក ម៉ាស៊ីនថ្លឹងទម្ងន់ ម៉ាស៊ីនស្ងួច និងលើកទំនិញ)។ រីឯបន្ទាត់ពន្ធគយពាក់កណ្តាលទៀតពុំមានជាប់ពន្ធទេ (មានដូចជា ម៉ាស៊ីនកសិកម្ម ម៉ាស៊ីនព្រៃឈើ ម៉ាស៊ីនសម្រាប់ផលិតស្រា និងទឹកផ្លែឈើ កុំព្យូទ័រ។ល។) ទោះបីជាបន្ទាត់ពន្ធខ្លះៗមានអត្រា ៥% និង ១០%។

- ពន្ធមូលដ្ឋាន ២០០៥ (៦១៨ បន្ទាត់ពន្ធ) :
  - 0% លើ ២៩៤ បន្ទាត់ពន្ធ
  - ៥% លើ ៣៩ បន្ទាត់ពន្ធ
  - ៦.៥% លើ ២៨ បន្ទាត់ពន្ធ
  - ៧% លើ ៣១១ បន្ទាត់ពន្ធ
  - ១0% លើ ១៣ បន្ទាត់ពន្ធ
  - ១០ បន្ទាត់ពន្ធលើគ្រឿងបន្លាស់ដែលអត្រាពន្ធ អាស្រ័យលើការប្រើប្រាស់នៃគ្រឿងបន្លាស់ទាំងនោះ

- ពន្ធកាត់បន្ថយជាបណ្តើរៗមក 0% លើរាល់បន្ទាត់ពន្ធទាំងអស់ក្នុងឆ្នាំ ២០២០:
  - ពន្ធ 0% នៅពេល EIF
  - ពន្ធ ៥% នឹងត្រូវលុបនៅពេល EIF ក្នុងឆ្នាំ ២០១០
  - ពន្ធ ៦.៥% នឹងត្រូវលុបនៅពេល EIF ឬក្នុងឆ្នាំ ២០១០ លើកលែង ១ បន្ទាត់ពន្ធដែលនឹងត្រូវកាត់បន្ថយជាបណ្តើរៗមក 0% នាឆ្នាំ ២០២០ (រ៉ូឡូកិនបង្ហាប់)
  - ពន្ធ ៧% នឹងត្រូវលុបនៅពេល EIF ឬក្នុងឆ្នាំ ២០១០ (២៨៧ បន្ទាត់ពន្ធ) លើកលែង ២១ បន្ទាត់ពន្ធ ដែលត្រូវកាត់បន្ថយជាបណ្តើរៗមក 0% នាឆ្នាំ ២០១២ ជាមួយកម្មវិធីដូចតទៅនេះ ៥% ក្នុងឆ្នាំ ២០១០ ៣% ក្នុងឆ្នាំ ២០១១ និង 0% ក្នុងឆ្នាំ ២០១២។ បន្ទាត់ពន្ធទាំង ២១ នោះរួមមានប្រភេទខ្លះៗនៃម៉ាស៊ីនត្រជាក់ ទូទឹកកក ទូបង្កក និងម៉ាស៊ីនបង្កកផ្សេងទៀតឧបករណ៍សម្ងួតសម្លៀកបំពាក់ និង ឧបករណ៍ច្រោះ និងបន្សុទ្ធទឹក និងភេសជ្ជៈ:
  - ១ បន្ទាត់ពន្ធ នឹងបន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០២០ :

| | |
|---|---|
| 84.81 | ក្បាលម៉ាស៊ីនទឹក ក្បាលមាន់ ស៊្វីប៉ាប់ ឬវ៉ាល់ និងឧបករណ៍ប្រហាក់ប្រហែលសម្រាប់ បំពង់ទុយោ សម្រាប់ឆ្នាំងខ្វះ ធុង ធុងឈើ និងរបស់ស្រដៀងៗ រួមទាំងឧបករណ៍សម្រាប់បន្ថយសម្ពាធ និងត្រួតពិនិត្យកំដៅ។ |
| 8481.80.19 | --ផ្សេងៗ |

- ពន្ធ ១០% នឹងត្រូវលុបនៅពេល EIF ឬ ក្នុងឆ្នាំ ២០២០ (១១ បន្ទាត់ពន្ធ)
    - ទាំងនេះរួមបញ្ចូលផងដែរនូវម៉ាស៊ីនដែលរុញច្រានពិស្តុងដែលមានចំហេះដោយប៊ូស៊ី ឬរ៉ូតារី ដែលរុញច្រានពិស្តុងដែលមានសម្ពាធដោយប៊ូស៊ី (ម៉ាស៊ីនម៉ាស៊្វូត ឬពាក់កណ្តាលម៉ាស៊្វូត) និងបំណែកសម្រាប់ម៉ាស៊ីនទាំងនោះ។
- បន្ទាត់ពន្ធ ២ នឹងបន្ថយជាបណ្តើរៗមក ០% នៅឆ្នាំ ២០២០
    - ទាំងនេះរួមមាន តម្រងប្រេងសម្រាប់ម៉ាស៊ីនចំហេះក្នុង និងម៉ាស៊ីនច្រោះខ្យល់ បឺតចូលសម្រាប់ម៉ាស៊ីនចំហេះអន្តរជាតិ។ អត្រាពន្ធទាំងពីរបន្ទាត់នេះនឹងត្រូវកាត់បន្ថយមកត្រឹម ៨% ក្នុងឆ្នាំ ២០១៤ ៥% ក្នុងឆ្នាំ ២០១៥ និង ០% ក្នុងឆ្នាំ ២០២០។
- អត្រាពន្ធលើបន្ទាត់ពន្ធចំនួន ១០ ដែលអត្រារបស់វាប្រែប្រួលតាមការប្រើប្រាស់ចុងក្រោយនឹងត្រូវលុបក្នុងឆ្នាំ ២០១២

### ៤. គ្រឿងម៉ាស៊ីនអេឡិចត្រិច (HS 85)

### អូស្ត្រាលី

ការនាំចូលនូវគ្រឿងម៉ាស៊ីនអេឡិចត្រិចរបស់អូស្ត្រាលីពីអាស៊ានមានតម្លៃប្រហែល ២.២ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ ហើយការនាំចូលសរុបពីពិភពលោកឈានដល់ប្រមាណ ១៦.៩ពាន់លានដុល្លារក្នុងមួយឆ្នាំ។

- ពន្ធមូលដ្ឋាន ២០០៥ ( ៣៣៨ បន្ទាត់ពន្ធ) :
  - ០% លើ ១៦៦ បន្ទាត់ពន្ធ
  - ៥% លើ ១៤៩ បន្ទាត់ពន្ធ
  - ១០% លើ ២៣ បន្ទាត់ពន្ធ

- ពន្ធនឹងត្រូវលុបលើបន្ទាត់ពន្ធទាំងអស់ក្នុងឆ្នាំ ២០២០ លើកលែងបន្ទាត់ ២ ដែលត្រូវលុបក្នុងឆ្នាំ ២០១០
  - ពន្ធ ០% នឹងត្រូវកំណត់នៅពេល EIF

- ពន្ធ ៥% លើបន្ទាត់ភាគច្រើននឹងត្រូវលុបនៅពេល EIF (១១២ បន្ទាត់ពន្ធ)
    - បន្ទាត់ពន្ធខ្លះ ក្នុងឆ្នាំ ២០១០ (៣៥បន្ទាត់ មានដូចជា ក្បាលម៉ាស៊ីន និងពីស្តុទ្បេ សម្រាប់ផ្សារ ចង្កៀងអគ្គិសនីអាចយួរបាន ប្រដាប់កំដៅទឹក ប្រដាប់កំដៅដោយអគ្គិសនី ប្រដាប់សម្ងួតសក់ ប្រដាប់ឆុងកាហ្វេ ប្រដាប់បំពងសំឡេង ។ល។ )
    - បន្ទាត់ពន្ធមួយចំនួន ក្នុងឆ្នាំ ២០២០ (២បន្ទាត់ពន្ធរួមមាន វិទ្យុ និងកាមេរ៉ាវីដេអូ)។ ពន្ធ ១០% នឹងត្រូវលុបនៅពេល EIF។

**ណូវ៉ែលហ្សេឡង់**

គ្រឿងម៉ាស៊ីនអេឡិចត្រិចគឺជាផលិតផលមួយក្នុងចំណោមផលិតផលសំខាន់ៗ ដែលណូវ៉ែលហ្សេឡង់នាំចូលពីអាស៊ាន មានតម្លៃគិតជាមធ្យមប្រហែល ៣៦១.៧ លានដុល្លារ ក្នុងមួយឆ្នាំ។ ណូវ៉ែលហ្សេឡង់នាំចូលផលិតផលនេះពីពិភពលោកមានតម្លៃសរុបប្រមាណ ២.៦ ពាន់លានដុល្លារ។ ម៉ាស៊ីនអគ្គិសនីទាំងអស់ចូលក្នុងណូវ៉ែលហ្សេឡង់ជាប់ពន្ធក្នុងចន្លោះ ០% និង ១៧.៥%។ ការលុបរាល់ពន្ធទាំងអស់ក្នុងវិស័យនេះក្នុងឆ្នាំ ២០២០ នឹងផ្តល់ឱកាសល្អដល់ផលិតករម៉ាស៊ីនអគ្គិសនីទាំងអស់របស់អាស៊ាន។

- ពន្ធមូលដ្ឋាន ២០០៥: បន្ទាត់ពន្ធចំនួន ៨៣១ ស្ថិតក្នុងចន្លោះ ០% និង ១៧.៥%
  - បន្ទាត់ពន្ធភាគច្រើនជាប់ពន្ធ ៧% ដែលនឹងត្រូវលុបក្នុងឆ្នាំ ២០១០
    - លើកលែងបន្ទាត់ពន្ធមួយចំនួនដែលនឹងត្រូវលុបក្នុងឆ្នាំ ២០១២ និង ២០២០ (គ្របដណ្តប់លើប្រភេទខ្លះនៃអាគុយអគ្គិសនី ប៊ូស៊ីបញ្ឆេះអគ្គសនី ចង្ក្រានហ្គាស និងរង់ហ្គ័ក្នុងស្រុក ប្រដាប់បំពងសំឡេង ប្រភេទខ្លះៗនៃវិទ្យុ ចង្កៀងអគ្គិសនីធ្វើពីសរសៃឆ្មា ខ្សែកាប)
  - ពន្ធ ១៧.៥% នឹងត្រូវលុបក្នុងឆ្នាំ ២០២០
    - រួមមាន ប្រភេទខ្លះនៃ អាគុយអគ្គិសនី, បូប៊ីនបញ្ឆេះសម្រាប់រថយន្តអ្នកធ្វើដំណើរ ខ្សែប៊ូស៊ីសម្រាប់បញ្ឆេះសម្រាប់រថយន្តអ្នកធ្វើដំណើរ។

**៥. កៅស៊ូ (HS 40)**

**អូស្រ្តាលី**

ការនាំចូលប្រចាំឆ្នាំកៅស៊ូពីអាស៊ានរបស់អូស្រ្តាលី មានតម្លៃប្រហែល ៣៨៣.២ លានដុល្លារ និងនាំចូលពីពិភពលោកសរុបមានតម្លៃប្រមាណ ២.៣ ពាន់លានដុល្លារ។ ប្រមាណ ៥៧% នៃបន្ទាត់ពន្ធទាំងអស់សម្រាប់ផលិតផលនេះជាប់ពន្ធ ៥%។

- ពន្ធមូលដ្ឋាន ២០០៥ (៩៩ បន្ទាត់ពន្ធ)

- ០% លើ ១៣ បន្ទាត់ពន្ធ
- ៥% លើ ៥៩ បន្ទាត់ពន្ធ
  - រួមមានបណ្តាផលិតផលដូចជា កៅស៊ូសំយោគ កៅស៊ូល្បាយ កៅស៊ូលាយស្ពាន់ធ័រ
- ៧.៥% លើ ៣ បន្ទាត់ពន្ធ
  - មានដូចជា ស្រោមដៃវះកាត់ ឈុតមុជទឹក និង ប្រភេទសម្លៀកកបំពាក់ធ្វើអំពីកៅស៊ូលាយស្ពាន់ធ័រ
- ១០% លើ ២៣ បន្ទាត់ពន្ធ
  - គ្របដណ្តប់លើបណ្តាផលិតផលដូចជា កម្រាលជើង សំបកកង់ប្រើហើយ សំបកកង់រថយន្តប្រើហើយ
- ១៧.៥% លើ ១ បន្ទាត់ពន្ធ
  - ប្រភេទខ្លះនៃផលិតផលសម្លៀកបំពាក់ និងគ្រឿងផ្សំសម្លៀកបំពាក់ (រួមទាំងស្រោមដៃ) សម្រាប់គ្រប់ទិសដៅ ធ្វើពីកៅស៊ូលាយស្ពាន់ធ័រក្រៅពីកៅស៊ូរឹង

- ពន្ធភាគច្រើននឹងត្រូវលុបក្នុងឆ្នាំ ២០១០
  - លើកលែងបន្ទាត់ពន្ធចំនួន ២ ដែលត្រូវបានកំណត់មិនជាប់ពន្ធក្នុងឆ្នាំ ២០២០ (សម្លៀកបំពាក់មួយចំនួនប្រើប្រាស់សម្រាប់ការពារ X-ray ឬ pilches និងស្រោមដៃវះកាត់ធ្វើពីកៅស៊ូវូលកាណាយ។

## ណូវ៉ែលហ្សេឡង់

ណូវ៉ែលហ្សេឡង់នាំចូលកៅស៊ូមានតម្លៃប្រហែល ២.៣ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ ដែលក្នុងនោះ ៥០.៤ លានដុល្លារ នាំចូលពីអាស៊ាន។ បន្ទាត់ពន្ធជាងពាក់កណ្តាលក្នុងវិស័យនេះជាប់ពន្ធ។

- ពន្ធមូលដ្ឋាន ២០០៥ ( ១៦១ បន្ទាត់ពន្ធ) :
- ០% លើ ៧៩ បន្ទាត់ពន្ធ
  - រួមមាន កៅស៊ូធម្មជាតិ ជ័របាលាតា ជ័រងុតតាផេចហា ជ័រងាយុលេ ជ័រល្មុត ឬជ័រធម្មជាតិស្រដៀងគ្នាក្នុងទម្រង់ដើម ឬជាស្លាក ជាសន្លឹក ឬជាបង់ សន្ទះខាងក្នុងពោះវៀនធ្វើពីកៅស៊ូ ខ្សែពានបញ្ជូន ប្រភេទខ្លះនៃសំបកកង់។
- ៥% លើ ២ បន្ទាត់ពន្ធ
  - មានដូចជា ក្បាលដោះ និង ភាគ និងគ្រឿងបន្ទាប់សន្សំផ្សេងទៀតប្រើសម្រាប់រថយន្តដែលធ្វើកៅស៊ូលាយស្ពាន់ធ័រ និងសមាសធាតុនៃកៅស៊ូលាយស្ពាន់ធ័រប្រើប្រាស់ក្នុងការតម្លើង និងផលិតរថយន្ត។
- ៦% - ៧.៥% លើ ៦៩ បន្ទាត់ពន្ធ

- ○ រួមមាន ប្រភេទខ្លះៗនៃខ្សែពាន ខ្សែពានប្រអប់លេខ ឬខ្សែអូសធ្វើពីកៅស៊ូលាយស្ពាន់ធ័រ ស្លាក សន្លឹក បង់ដ៍ ចង្កឹះ ប្រ៉ូហ្វីឡេ ធ្វើពីកៅស៊ូលាយស្ពាន់ធ័រ ក្រៅពីកៅស៊ូរឹង។

- ១០% - ១១.៥% លើ ១១ បន្ទាត់ពន្ធ
  - ○ មានដូចជា ប្រភេទមួយចំនួននៃសំបកកង់អ៊ុតឡើងវិញ ឬប្រើប្រាស់រួចហើយធ្វើពីកៅស៊ូ ផ្ទៃកទទឹង សំបកកង់ និងសំបកទ្រនាប់ពោះវៀនធ្វើពីកៅស៊ូ ទុយោប្រ៉ាំងឡាន ប្រភេទខ្លះនៃសំបកកង់ថ្មីធ្វើពីកៅស៊ូ។
- ១៧.៥% លើ ២ បន្ទាត់ពន្ធ
  - ○ ដូចជា សំបកកង់ថ្មីធ្វើពីកៅស៊ូប្រើប្រាស់សម្រាប់រថយន្ត និងភាគ និងគ្រឿងបន្ទាប់បន្សំធ្វើពីកៅស៊ូលាយស្ពាន់ធ័រសម្រាប់រថយន្តអ្នកធ្វើដំណើរ។

- ពន្ធទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០១០ លើកលែងពន្ធលើបន្ទាត់ពន្ធចំនួន ១១ ដែលនឹងបន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០២០។
  - ○ បន្ទាត់ពន្ធទាំង ១១ នេះមានដូចជា ប្រភេទជាច្រើននៃសំបកកង់ពីកៅស៊ូ សំបកកង់ប្រើហើយ (0% in ២០១០) ប្រភេទខ្លះនៃសម្លៀកកបំពាក់សម្រាប់គ្រប់ទិសដៅ ធ្វើពីកៅស៊ូវូលកាណាយក្រៅពីកៅស៊ូរឹង និងផលិតផលផ្សេងទៀតធ្វើពីកៅស៊ូវូលកាណាយក្រៅពីកៅស៊ូរឹង។

**៦.ប្លាស្ទិក និងផលិតផលប្លាស្ទិក (HS 39)**

## អូស្ត្រាលី

អូស្ត្រាលីនាំចូលប្លាស្ទិក និងផលិតផលប្លាស្ទិកមានតម្លៃប្រហែល ៧៧១ លានដុល្លារ ជារៀងរាល់ឆ្នាំពីអាស៊ាន និងប្រមាណ ៣.៩ លានដុល្លារ ពីសកលលោក។ នៅអូស្ត្រាលីបន្ទាត់ពន្ធច្រើនជាង ៨០% ក្នុងវិស័យនេះត្រូវបាន កំណត់នៅអត្រា ៥% ទោះបីជាបន្ទាត់ពន្ធមួយចំនួនឃើញថា នៅ 0% ១0% និងបន្ទាត់ពន្ធមួយនៅ ១៧.៥%។ បន្ទាត់ពន្ធទាំងអស់នេះនឹងត្រូវលុបពន្ធនាំចូលនៅឆ្នាំ ២០១០ លើកលែងបន្ទាត់ពន្ធចំនួន ៣ ដែលនឹងត្រូវលុបនៅឆ្នាំ ២០២០។

- ពន្ធមូលដ្ឋាន ២០០៥ (១៥០ បន្ទាត់ពន្ធ) :
  - 0% លើ ១២ បន្ទាត់ពន្ធ

- ○ រួមមាន សៃលុយឡូស និងផលិតផលគីមីចេញពីសេលុយឡូស មានប្លាស្ទិក និងមិនមានប្លាស្ទិក ពោះវៀនសិប្បនិម្មិត (សម្រាប់ខ្ចប់សាច់ក្រក) ស្លាក សន្លឹក បន្ទះស្តើង បង់ផ្សេងទៀតធ្វើពីសៃលុយឡូសបង្កើតឡើងវិញ សរសៃមានស្តាន់ផរ និង អាសេតាត សៃលុយឡូស

- ៥% លើ ១១៧ បន្ទាត់ពន្ធ
  - ○ មានបណ្តាផលិតផលដូចជា ប៉ូលីមែរអេទីឡែន ក្នុងទម្រង់ដើម ស្ទីរ៉ែន ក្លរៀរីនីល ឬ អូឡេហ្វីនអាឡូសែន អាសេតាតវីនីល ឬអីសស្ទ័រវីនីលផ្សេងទៀត ស៊ីលីកូន ប៉ូលីមែរធម្មជាតិ។
- ១០% លើ ១០ បន្ទាត់ពន្ធ
  - ○ រួមមានប្រភេទបំពង់ និងទុយោ និងគ្រឿងបន្ទាប់បន្សំធ្វើពីប្រូពីឡែន និងប្លាស្ទិក ផ្សេងទៀតដែលប្រើប្រាស់ក្នុងរថយន្តអ្នកធ្វើដំណើរ និងបណ្តាផលិតផលប្លាស្ទិក ដែលយកធ្វើជាសមាសធាតុនៅក្នុងរថយន្តអ្នកធ្វើដំណើរ
- ១៧.៥% លើ ១ បន្ទាត់ពន្ធ
  - ○ ប្រភេទខ្លះនៃសម្លៀកបំពាក់ប្លាស្ទិក។

- អត្រាពន្ធទាំងអស់លើបន្ទាត់ពន្ធនឹងត្រូវលុបក្នុងឆ្នាំ ២០២០
  - ពន្ធនឹងត្រូវកំណត់នៅអត្រា 0% នៅពេល EIF ឬនឹងត្រូវលុប ក្នុងឆ្នាំ ២០១០ លើបន្ទាត់ពន្ធ
- ទាំងអស់ លើកលែងបន្ទាត់ពន្ធចំនួន ៣
  - បន្ទាត់ពន្ធដែលនៅសល់ ៣ នេះនឹងកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០២០ (បន្ទាត់ពន្ធមួយមានអត្រាពន្ធ ១៧.៥% ដែលរួមមានសម្លៀកបំពាក់ប្លាស្ទិក) ឬនឹងត្រូវលុប ក្នុងមួយជំហានក្នុងឆ្នាំ ២០២០ (បន្ទាត់ពន្ធ២ មានពន្ធ ៥% ដែលមានប្រភេទ ខ្លះនៃបន្ទះសន្លឹក បន្ទះតូចៗ។ល។)

### ណូវែលហ្សេឡង់

ប្លាស្ទិក និងផលិតផលប្លាស្ទិកគឺជាផលិតផលមួយក្នុងផលិតផលសំខាន់ៗដែលណូវែលហ្សេឡង់នាំចូល។ ផលិតផលប្លាស្ទិកដែលមានតម្លៃគិតជាមធ្យមប្រហែល ១៩៤ លានដុល្លារក្នុងមួយឆ្នាំ (ចន្លោះឆ្នាំ ២០០៦-២០០៨) ត្រូវបានណូវែលហ្សេឡង់នាំចូលពីអាស៊ាន និងប្រមាណសរុប ១.១ ពាន់លានដុល្លារ ពីសកលលោកជារៀងរាល់ឆ្នាំ។ នៅក្នុងផ្នែកនេះ មានបន្ទាត់ពន្ធចំនួន ២៤០ ដែលក្នុងនោះបន្ទាត់ពន្ធជាងពាក់កណ្តាលកំណត់ពន្ធនៅអត្រា ៥%-៧.៥%។ ពន្ធភាគច្រើននឹងត្រូវលុបក្នុងឆ្នាំ

២០១០។ ពន្ធលើបន្ទាត់ពន្ធចំនួនប្រហែល ១៦ នឹងត្រូវលុប ក្នុងឆ្នាំ ២០១២ និងពន្ធលើបន្ទាត់ពន្ធដែលនៅសល់ចំនួន ២១ ទៀតនឹងត្រូវលុបក្នុងឆ្នាំ ២០២០។

- ពន្ធមូលដ្ឋាន ២០០៥ (២៣៦ បន្ទាត់ពន្ធ) ចន្លោះ 0% និង ១៩%
  - 0% លើ ៨៣ បន្ទាត់ពន្ធ
    - រួមមាន ប៉ូលីមែរប្រូពីឡែ ឬអូឡេហ្វីនផ្សេងទៀតក្នុងទម្រង់ដើមនៃស្ទីរ៉ែន ឬប៉ូលីមែរធម្មជាតិ (ឧទាហរណ៍ អាស៊ីដអាល់ហ្សេនិច) និងប៉ូលីមែរធម្មជាតិកែច្នៃ (ឧទាហរណ៍ ប្រូតេអ៊ីនរឹង ផលិតផលគីមីចេញពីកៅស៊ូធម្មជាតិ)
  - ៥%-៧% លើ ១៤៣ បន្ទាត់ពន្ធ
    - ម៉ូណូហ្វីឡាម៉ង់ ដែលមានទំហំមុខកាត់លើសពី ១ ម.ម (ម៉ូណូហ្វីល) ដើមព្រនង់ ដំបង និងទម្រង់ប្រូហ្វីឡែ ទោះមាន ឬគ្មានកែច្នៃលើផ្ទៃពីប្លាស្ទិក ស្លាក សន្លឹក បង់ រ៉ូឡូសន្លឹកស្តើង និងទម្រង់សំប៉ែតផ្សេងទៀតធ្វើពីប្លាស្ទិក។
  - ១៩% លើ ៥ បន្ទាត់ពន្ធ
    - រួមមានផលិតផលប្លាស្ទិកផ្សេងទៀត និងសម្ភារៈដែលមានទីតាំងនៅ 39.01 to 39.14 ( ទូនាប់ស្នា អាវធំ ខោ និងស្បែងជើង)។

- ពន្ធភាគច្រើនត្រូវបានកំណត់នៅអត្រា 0% នៅពេល EIF ឬលុបក្នុងឆ្នាំ ២០១០
  - ពន្ធដែលនៅសេសសល់ទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០២០ (រួមមាន ប្រភេទខ្លះនៃប៉ូលីមែរ អាគ្រីលិច ប៉ូលីអាសេតាល់ ប៉ូលីអេទែផ្សេងទៀត និងជ័រអេប៉ុកស៊ីដ ស្លាក សន្លឹក បង់ រ៉ូឡូសន្លឹកស្តើង និងទម្រង់សំប៉ែតផ្សេងទៀត ស្លាក សន្លឹក បន្ទះស្តើង បង់ផ្សេងទៀតធ្វើពី ប្លាស្ទិក គ្មានរន្ធ គ្មានពង្រឹងដោយស្រទាប់ផ្សេងទៀត គ្មានបញ្ចូលជាមួយ អង្គធាតុផ្សេងទៀត គ្មានទូនាប់ ស្លាក សន្លឹក បន្ទះស្តើង បង់ផ្សេងទៀតធ្វើពីប្លាស្ទិក អាងងូតទឹក ឡាវ៉ាបូ ភាជន៍ពងក្រពើ ចានបង្គន់ ប្រដាប់អង្គុយ គម្រប ធុងទឹក និងផលិតផលប្រហាក់ប្រហែលសម្រាប់ការប្រើប្រាស់សុខភាព និងអនាម័យធ្វើពីប្លាស្ទិក វត្ថុបម្រើការដឹកជញ្ជូន និងការវេចខ្ចប់ធ្វើពី ប្លាស្ទិក ឆ្នុក គម្រប គម្របដប និងប្រដាប់បិទផ្សេងទៀតធ្វើពីប្លាស្ទិក គ្រឿងប្រដាប់សម្រាប់តុ ចង្ក្រានបាយ សម្ភារៈប្រើក្នុងផ្ទះដទៃទៀត និងសម្ភារៈអនាម័យធ្វើពីប្លាស្ទិក វត្ថុនៃបរិក្ខារសម្រាប់សំណង់ធ្វើពីប្លាស្ទិក។

## ៧.គ្រឿងសង្ហារិម (HS 94)

### អូស្ត្រាលី

អូស្ត្រាលីនាំចូលគ្រឿងសង្ហារិមពីអាស៊ានមានតម្លៃជាមធ្យម ២៦៥ លានដុល្លារ ក្នុងមួយឆ្នាំ។ នាំចូលសរុបពីសកលលោកមានតម្លៃប្រហែល ២.៥ ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ។ បន្ទាត់ពន្ធជាងពាក់កណ្តាលក្នុងផ្នែកនេះជាប់ពន្ធ ៥%។

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (៤០ បន្ទាត់ពន្ធ):
  - 0% លើ ៧ បន្ទាត់ពន្ធ
    - រួមមានកៅអីសម្រាប់យន្តហោះ ពេទ្យធ្មេញ ជាងកាត់សក់ ជើងទានធ្វើអំពីកែវ
  - ៥% លើ ២៩ បន្ទាត់ពន្ធ
    - រួមមាន គ្រឿងសង្ហារិមធ្វើពី លោហៈធាតុ ប្លាស្ទិក ឈើ ផ្តៅ ឬស្សី សូល ឬវត្ថុធាតុផ្សេងទៀត សំណាង់គ្រោងរួចជាមុន ចង្កៀងព្យួរ និងបរិធានបំភ្លឺដាក់ជាប់ពិដាន និងជញ្ជាំង
  - ៧.៥% លើ ២ បន្ទាត់ពន្ធ
    - រួមមាន ថង់ដេក និងប្រភេទពូកដេកមួយចំនួន
  - ១០% លើ ២ បន្ទាត់ពន្ធ
    - រួមមានកៅអីសម្រាប់រថយន្ត

- ពន្ធនាំចូលនឹងលុបនៅឆ្នាំ ២០១០ លើកលែង ២បន្ទាត់ពន្ធដែលត្រូវកាត់បន្ថយមក 0% នៅឆ្នាំ ២០២០។
  - បន្ទាត់ពន្ធទាំង ២ នេះគ្របដណ្តប់លើកៅអីដោយមានគ្រោងធ្វើពីឈើ និងគ្រឿងសង្ហារិមធ្វើពីឈើប្រើក្នុងការិយាល័យ ដែលអត្រាពន្ធនៅរក្សា ៥% រហូតដល់ឆ្នាំ ២០១៩។

**ណូវែលហ្សេឡង់**

ណូវែលហ្សេឡង់នាំចូលផលិតផលគ្រឿងសង្ហារិមពីអាស៊ានមានតម្លៃប្រហែល ៥៤ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ក្នុងរយៈកាលបីឆ្នាំចុងក្រោយនេះ។ ការនាំចូលសរុបពីសកលលោកមានតម្លៃប្រមាណ ១.៣ ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ។

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (៦១ បន្ទាត់ពន្ធ)
  - 0% លើ ៧ បន្ទាត់ពន្ធ
    - រួមមានកៅអី និងគ្រឿងបន្លាស់របស់ទេព្យធ្មេញ ជាងកាត់សក់ ចង្កៀងសុវត្ថិភាពសម្រាប់កម្មករអណ្តូងរ៉ែ ចង្កៀងមិនប្រើចរន្តអគ្គិសនី និង គ្រឿងបំពាក់សម្រាប់បំភ្លឺធ្វើអំពីលោហៈ និងកែវ
  - ៥%-៦.៥% លើ ៨ បន្ទាត់ពន្ធ

- ○ រួមមាន ចង្កៀងមិនប្រើចរន្តអគ្គិសនី និង គ្រឿងបំពាក់សម្រាប់បំភ្លឺធ្វើពីប្លាស្ទិក សំណាង់គ្រោងរួមជាមុនធ្វើពីឈើ ភ្លើងស្លាកសញ្ញាតាំងលំអ ស្លាកឈ្មោះមានពន្លឺតាំងលំអ និងវត្ថុប្រហាក់ប្រហែលធ្វើពីប្លាស្ទិក។

- ៧% លើ ៤២ បន្ទាត់ពន្ធ
  - ○ រួមមាន គ្រឿងសង្ហារិមធ្វើពី លោហធាតុ ឈើ ប្លាស្ទិក វត្ថុធាតុផ្សេងៗទៀតដូចជា ផ្តៅ ឫស្សី សូល ឬវត្ថុធាតុ ស្លាកឈ្មោះមានពន្លឺតាំងលំអ និងវត្ថុប្រហាក់ប្រហែលធ្វើពីសេរ៉ាមិក។
- ១០%-១២% លើ ៣ បន្ទាត់ពន្ធ
  - ○ រួមមាន បណ្តាកន្លែងសម្រាប់រថយន្ត
- ១៧.៥% លើ ១ បន្ទាត់ពន្ធ
  - ○ កៅអីដែលប្រើក្នុងការតម្លើងរថយន្ត

• ពន្ធលើបន្ទាត់ពន្ធទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០១០ លើកលែងបន្ទាត់ពន្ធចំនួន ៦ ដែលនឹងត្រូវកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០២០
- ពន្ធ ៧% នឹងកាត់បន្ថយជាបណ្តើរៗមក 0%
  - ○ ឆ្នាំ ២០១២ ចំនួន ៨ បន្ទាត់ពន្ធ (រួមមាន កៅអីវិល ប្រដាប់ទ្រពូក ពូកកៅស៊ូ គ្រឿងសង្ហារិម លោហៈមួយចំនួនសម្រាប់ប្រើប្រាស់ក្នុងការិយាល័យ)
  - ○ ឆ្នាំ ២០១៣ ចំនួន ៣ បន្ទាត់ពន្ធ (រាល់គ្រឿងសង្ហារិមដែលធ្វើពីវត្ថុធាតុដើមរួមមាន ផ្តៅ ឫស្សី ឬវត្ថុធាតុដែលប្រហាក់ប្រហែល)
  - ○ ឆ្នាំ ២០១៩ ចំនួន ៦ បន្ទាត់ពន្ធ (គ្រឿងសង្ហារិមធ្វើពីឈើប្រើប្រាស់ក្នុង ផ្ទះបាយ បន្ទប់ទឹក និងការិយាល័យ)
  - ○ និង ឆ្នាំ ២០២០ ចំនួន ៤ បន្ទាត់ពន្ធ (គ្រឿងសង្ហារិមប្លាស្ទិក គ្រែដេក)
- ពន្ធ ១២% នឹងកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០២០ (សម្រាប់ប្រភេទពូកដេក និងខ្នើយកើយមួយចំនួន)
- ពន្ធ ១៧.៥% នឹងបន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១២ (សម្រាប់កៅអីប្រើក្នុងការតម្លើងរថយន្ត)

**៨.រថយន្តសម្រាប់ដឹកជញ្ជូនទំនិញ (HS 8704)**

**អូស្ត្រាលី**

ក្រុមផលិតផលនេះស្ថិតក្នុងចំណោមប្រភេទផលិតផលដ៏សំខាន់ដែលនាំចូលពីអាស៊ាន សម្រាប់អូស្ត្រាលី ដែលមានតម្លៃជាមធ្យមប្រហែល ១.៦ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ។ តម្លៃនាំចូលសរុបទូទាំងពិភពលោកជារៀងរាល់ឆ្នាំឈានដល់ ៤.៤ ពាន់លានដុល្លារ។ បន្ទាត់ពន្ធជាងពាក់កណ្តាលក្នុងផ្នែកនេះជាប់ពន្ធ ៥-១០%។ ពន្ធទាំងអស់នឹងត្រូវលុបទាំងស្រុងក្នុងឆ្នាំ ២០១០។

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (១០ បន្ទាត់ពន្ធ) ៥% លើបន្ទាត់ពន្ធទាំងអស់
- ពន្ធលើបន្ទាត់ពន្ធទាំងអស់នឹងត្រូវលុបនៅពេល EIF

## ណូវ៉ែលហេប្រ៊ូឡង់

ណូវ៉ែលហេប្រ៊ូឡង់នាំចូលផលិតផលប្រភេទនេះក្នុងមួយឆ្នាំពីអាស៊ាន មានតម្លៃប្រហែល ១៩៥.៦ លានដុល្លារ។ នាំចូលសរុបពីសកលលោកមានតម្លៃប្រហែល ១៩៥.៦ លានដុល្លារ ក្នុងមួយឆ្នាំ។ បន្ទាត់ពន្ធភាគច្រើននៅក្នុងផ្នែកនេះមិនមានជាប់ពន្ធទេ ក្រៅពីនោះបន្ទាត់ពន្ធតិចជាង ១០% ប៉ុណ្ណោះជាប់ពន្ធ ៧%។

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (២០ បន្ទាត់ពន្ធ): ៧% លើ ៦ បន្ទាត់ពន្ធ និង 0% លើបន្ទាត់ពន្ធដែលនៅសល់
    - ពន្ធ ៧% រួមមាន:

| | |
|---|---|
| | -រថយន្តបែនស្តាបនាឡើងសម្រាប់ប្រើប្រាស់ក្រៅពីប្រព័ន្ធផ្លូវថ្នល់ហាយវេ |
| 8704.10.01 | --ដែលមានទម្ងន់រថយន្តសរុបមិនលើសពី ១០,៥០០ គីឡូក្រាម |

| | |
|---|---|
| 8704.21 | --ដែលមានទម្ងន់រថយន្តសរុបមិនលើសពី ៥ តោន |
| 8704.21.80 | ---ផ្សេងៗ |

| | |
|---|---|
| 8704.22 | --ដែលមានទម្ងន់រថយន្តសរុបលើសពី ៥ តោន ប៉ុន្តែ មិនលើសពី ២០ តោន |
| 8704.22.11 | ---ដែលមានទម្ងន់រថយន្តសរុបមិនលើសពី ១០,៥០០ គីឡូក្រាម |

| | |
|---|---|
| 8704.31 | --ដែលមានទម្ងន់រថយន្តសរុបមិនលើសពី ៥ តោន |
| 8704.31.80 | ---ផ្សេងៗ |

| | |
|---|---|
| 8704.32 | --ដែលមានទម្ងន់រថយន្តសរុបមិនលើសពី ៥ តោន |

| | |
|---|---|
| 8704.32.11 | ---ដែលមានទម្ងន់រថយន្តសរុបមិនលើសពី ១០,៥០០ គីឡូក្រាម |

| | |
|---|---|
| 8704.៩០ | --ផ្សេងៗ |
| 8704.៩០.២១ | ---ដែលមានទម្ងន់រថយន្តសរុបមិនលើសពី ១០,៥០០ គីឡូក្រាម |

- ពន្ធលើបន្ទាត់នីមួយៗ នឹងត្រូវលុបនៅពេល EIF

## ៩. រថយន្តដឹកជញ្ជូនអ្នកដំណើរ/រថយន្តអ្នកដំណើរ (PMV) (HS 8703)

### អូស្ត្រាលី

អូស្ត្រាលីនាំចូល PMV ពីអាស៊ានមានតម្លៃប្រមាណ ៨១០.៦ លានដុល្លារ ក្នុងមួយឆ្នាំ និងនាំចូលសរុបទូទាំងពិភពលោកមានតម្លៃប្រហែល ១១.១ ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ។ ពាក់កណ្ដាលនៃបន្ទាត់ពន្ធសរុបក្នុងផ្នែកនេះមានអត្រាពន្ធ ៥% និងបន្ទាត់ពន្ធពាក់កណ្ដាលដែលនៅសល់ជាប់ពន្ធ ១០%។ ពន្ធលើរថយន្តដែលប្រើប្រាស់រួចត្រូវបានកំណត់ ១០% បន្ថែមពីលើពន្ធមួយផ្សេងទៀត។

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (៣២ បន្ទាត់ពន្ធ)
  រថយន្តអ្នកធ្វើដំណើរដែលប្រើប្រាស់រួច (PMV): អត្រាពន្ធ (១០% បូកនឹងទឹកប្រាក់ចំនួន ១២០០០ដុល្លារ ក្នុងរថយន្តមួយគ្រឿង)
  - រថយន្តអ្នកធ្វើដំណើរថ្មី: ពន្ធ ១០%
  - បណ្ដារថយន្តផ្សេងៗទៀត: ពន្ធ ៥%

- ពន្ធនាំចូលទាំងអស់នឹងត្រូវលុបនៅពេល EIF លើកលែងបណ្ដារថយន្តមួយចំនួនដែលផលិតនៅឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង ថៃ ជាប់ពន្ធដែលត្រូវលុបនៅពេលក្រោយ។
  - សម្រាប់ព័ត៌មានលម្អិតទាក់ទងតារាងនៃបណ្ដាផលិតផលដែលទទួលបាននូវប្រព្រឹត្តិកម្មពិសេសនេះ ព្រមជាមួយកម្មវិធីលុបពន្ធនាំចូលទាំងអស់នោះ អាចរកបាននៅក្នុងកម្មវិធីពន្ធរបស់អូស្ត្រាលី ក្នុងគេហទំព័ររបស់លេខាធិការដ្ឋានអាស៊ាន www.asean.org។

- បណ្ដាកិច្ចសន្យាពិសេសកាត់បន្ថយពន្ធសន្សឹមៗត្រូវយកមកអនុវត្តលើរថយន្តទាំងអំដែលផលិតក្នុងឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង ថៃ:
  - ពន្ធលើ PMV ដែលប្រើប្រាស់រួច នឹងត្រូវលុបនៅពេល EIF សម្រាប់ប្រទេសទាំងបីនេះ
  - ពន្ធលើ PMV ថ្មី ត្រូវកាត់បន្ថយជាបណ្ដើរៗមក 0% ក្នុងឆ្នាំ:

- ២០១៣, ២០១៤, ២០១៩, ឬ ២០២០ អាស្រ័យលើ ទំហំម៉ាស៊ីន ឬប្រភេទម៉ាស៊ីន ក្នុង ករណីផលិតនៅឥណ្ឌូណេស៊ី
- ២០១០ ឬ ២០១៧ អាស្រ័យលើ ទំហំម៉ាស៊ីន ប្រសិនបើផលិតនៅម៉ាឡេស៊ី
- ២០២០ ប្រសិនបើផលិតនៅថៃ

- ពន្ធនាំចូលលើបណ្តារថយន្តដទៃទៀត ត្រូវកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ:
  - ២០១៣ ឬ ២០១៥ ក្នុងករណីផលិតនៅឥណ្ឌូណេស៊ី
  - ២០១០ ប្រសិនបើផលិតនៅម៉ាឡេស៊ី
  - ២០២០ ប្រសិនបើផលិតនៅថៃ

- បណ្តាពន្ធនាំចូលទាំងអស់ពីប្រទេសអាស៊ានផ្សេងទៀតលើផលិតផលនេះ នឹងត្រូវលុបនៅពេល EIF

### ណូវ៉ែលហ្សេឡង់

ណូវ៉ែលហ្សេឡង់នាំចូលរថយន្តអ្នកដំណើរពីអាស៊ានក្នុងតម្លៃប្រហែល ១៧.៥ លានដុល្លារ ក្នុងមួយឆ្នាំ និងនាំចូលពីសកលលោកសរុបមានតម្លៃប្រហែល ២.១ ពាន់លានដុល្លារជារៀងរាល់ឆ្នាំ។ បន្ទាត់ពន្ធច្រើនជាងពាក់កណ្តាលជាប់ពន្ធ ១៧.៥% ចំណែកបន្ទាត់ពន្ធដែលនៅសល់ជាប់ពន្ធ 0%។

- អត្រាពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (២៤ បន្ទាត់ពន្ធ)
  - 0% លើ ៨ បន្ទាត់ពន្ធ (រួមមានរថយន្តផ្សេងៗ)
  - ១៧.៥% លើ ១៦ បន្ទាត់ពន្ធ (ឡានពេទ្យ និង motor-homes )

- ពន្ធនាំចូលទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០២០
  ពន្ធ 0% នឹងត្រូវកំណត់នៅពេល EIF ចំណែកឯពន្ធ ១៧.៥% នឹងត្រូវលុបក្នុងឆ្នាំ ២០១០ (ឡានពេទ្យ) ឬកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១២ (motor-homes)

### ១០.សម្លៀកបំពាក់ និងស្បែកជើង (HS 61,62,64)

### អូស្ត្រាលី

អូស្ត្រាលីនាំចូលសម្លៀកបំពាក់ និងស្បែកជើងពីអាស៊ានមានតម្លៃប្រហែល ២២០.៤ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ និងនាំចូលទូទាំងពិភពលោកសរុបប្រមាណ ៩.៤ ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ។ ផលិតផលសម្លៀកបំពាក់ដែលនាំចូលមកអូស្ត្រាលីភាគច្រើនជាប់ពន្ធ ១៧.៥% និងផលិតផលស្បែកជើងភាគច្រើនជាប់ពន្ធ ១០%។

### សម្លៀកបំពាក់

- ពន្ធលើបន្ទាត់ពន្ធទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០២០
  - ពន្ធ 0% (៣១ បន្ទាត់ពន្ធ) និង ៥% (៣ បន្ទាត់ពន្ធ)៖ អត្រាពន្ធទាំងពីរនេះនឹងត្រូវកំណត់ 0% នៅពេល EIF
  - ពន្ធ ៧.៥% លើ ២៨ បន្ទាត់ពន្ធ នឹងត្រូវលុបក្នុងឆ្នាំ ២០១០
  - ពន្ធ ១៧.៥% លើ ២១៦ បន្ទាត់ពន្ធ៖ ៦១ បន្ទាត់ពន្ធនឹងត្រូវលុបនៅពេល EIF ឬកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១២ (៦ បន្ទាត់ពន្ធ) ឬក្នុងឆ្នាំ ២០១៥ (២២ បន្ទាត់ពន្ធ) ឬក្នុងឆ្នាំ ២០២០ (១២៧ បន្ទាត់ពន្ធ)

### ស្បែកជើង

- ពន្ធលើបន្ទាត់ពន្ធទាំងអស់នឹងត្រូវលុបនៅពេល EIF
  - ពន្ធ 0% (១១ បន្ទាត់ពន្ធ) នឹងត្រូវកំណត់ 0% នៅពេល EIF
  - ពន្ធ ៥% (២ បន្ទាត់ពន្ធ) នឹងត្រូវកំណត់ 0% នៅពេល EIF
  - ពន្ធ ៧.៥% (៥ បន្ទាត់ពន្ធ) នឹងត្រូវកំណត់ 0% នៅពេល EIF
  - ពន្ធ ១០% (២២ បន្ទាត់ពន្ធ) នឹងត្រូវកំណត់ 0% នៅពេល EIF

### ណូវ៉ែលហ្សេឡង់

ការនាំចូលសម្លៀកបំពាក់ និងស្បែកជើងរបស់ណូវ៉ែលហ្សេឡង់ពីអាស៊ានមានតម្លៃជាមធ្យមប្រហែល ៣០.៦ លានដុល្លារក្នុងមួយឆ្នាំ និងនាំចូលពីសកលលោកសរុបប្រមាណ ២.៥ ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ។ ផលិតផលសម្លៀកបំពាក់ភាគច្រើនដែលនាំចូលមកណូវ៉ែលហ្សេឡង់ជាប់អត្រា ១៩% និងផលិតផលស្បែកជើងជាប់ពន្ធ ១៧.៥-១៩%។

### សម្លៀកបំពាក់

- ពន្ធនាំចូលលើបន្ទាត់ពន្ធទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០២០
  - ពន្ធ 0-៥% នឹងត្រូវចងមក 0% នៅពេល EIF
  - ពន្ធ ៧%-៧.៥% នឹងកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១៧ រួមមានបណ្តាផលិតផលដូចជា៖ ស្រោមដៃចាក់មានម្រាម និងគ្មានម្រាម គ្របដណ្តប់ដោយប្លាស្ទិក/
- កៅស៊ូ។
  - ពន្ធ ១៩% នឹងកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១៧ (១៧៦ បន្ទាត់ពន្ធ) ឬឆ្នាំ ២០២០ (១០១ បន្ទាត់ពន្ធ) ឬឆ្នាំ ២០១២ (២ បន្ទាត់ពន្ធ)

### ស្បែកជើង

ពន្ធភាគច្រើននៅក្នុងក្រុមផលិតផលនេះមានអត្រា ១៧.៥%-១៩% ដែលនឹងត្រូវកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១៧ ឬ ២០១៨។

- ពន្ធនាំចូលលើបន្ទាត់ពន្ធទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០១៨
  - ពន្ធ 0% កំណត់នៅពេល EIF
  - ពន្ធ ៧%-៧.៥% នឹងត្រូវកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១៧ លើផលិតផលដូចជា: បំណែកស្បែកជើង (រាប់បញ្ចូលទាំងផ្ទាំងស្បែកជើងខាងលើ ទោះជាភ្ជាប់ ឬមិនភ្ជាប់បាតស្បែកជើងជៀសវាងភ្ជាប់នឹងបាតខាងក្រៅ) បាតក្នុងដែលអាចដូរបាន ទ្រនាប់កែង និងវត្ថុប្រហាក់ប្រហែលដែលអាចដោះបាន ស្រោម ស្នងជើង និងវត្ថុប្រហាក់ប្រហែលគ្នា និងបំណែករបស់វា។

### ១១. វាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌ (HS 50, 5108-5113, 5207-5212, 53-60, 63)

### អូស្ត្រាលី

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥
  - 0% លើ ១១៤ បន្ទាត់ពន្ធ
  - ៥% លើ ១១៤ បន្ទាត់ពន្ធ
  - ៧.៥% លើ ៨៦ បន្ទាត់ពន្ធ
  - ១០% លើ ២៧៣ បន្ទាត់ពន្ធ
  - ១៧.៥% លើ ១៨ បន្ទាត់ពន្ធ

- ពន្ធនាំចូលលើបន្ទាត់ពន្ធទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០២០
  - ពន្ធភាគច្រើននឹងត្រូវកំណត់ 0% នៅពេល EIF ឬ នឹងត្រូវលុបក្នុងឆ្នាំ ២០១០ (៥៦៣ បន្ទាត់ពន្ធ)
  - ពន្ធដែលនៅសល់កាត់បន្ថយជាបណ្តើរៗមក 0% នៅឆ្នាំ ២០១៥ (២ បន្ទាត់ពន្ធ) ឬ ឆ្នាំ ២០២០ (៨០ បន្ទាត់ពន្ធ)
  - ព្រំ: អត្រាពន្ធ 0% លើព្រំមួយចំនួន (ធ្វើដោយដៃពីសរសៃសំបកដូច សិសាល ដើមក្រចៅ កប្បាស) នឹងត្រូវកំណត់ 0% នៅពេល EIF ដោយឡែកពន្ធ ១០% នឹងត្រូវកាត់បន្ថយជាបណ្តើរៗមក 0% នៅឆ្នាំ ២០២០។

**ល្វារ៉ែលហ្សេឡង់**

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥
  - ពន្ធ 0% លើ ៤២៨ បន្ទាត់ពន្ធ
  - ពន្ធ ៥%-៧.៥% លើ ១២០ បន្ទាត់ពន្ធ
  - ពន្ធ ១២%-១២.៥% លើ ១២២ បន្ទាត់ពន្ធ
  - ពន្ធ ១៧%-១៧.៥% លើ ៤០ បន្ទាត់ពន្ធ
  - ពន្ធដោយឡែកចំនួន ៣.៥៥ ដុល្លារល្វារ៉ែលហ្សេឡង់ ក្នុងមួយគីឡូក្រាម លើ ២ បន្ទាត់ពន្ធ
- ពន្ធនាំចូលលើបន្ទាត់ពន្ធទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០២០
  - ពន្ធជាច្រើននឹងត្រូវកំណត់ 0% នៅពេល EIF ឬនឹងត្រូវលុបក្នុងឆ្នាំ ២០១០ (៥៦៣ បន្ទាត់ពន្ធ)
  - ពន្ធដែលនៅសល់នឹងកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១២ (៥៩ បន្ទាត់ពន្ធ) ឆ្នាំ ២០១៦ (២ បន្ទាត់ពន្ធ) ឆ្នាំ ២០១៧ (១៧២ បន្ទាត់ពន្ធ) ឬ ឆ្នាំ ២០២០ (២២ បន្ទាត់ពន្ធដែលនៅសល់)
  - ព្រំ: ពន្ធ ១៧% ដែលដាក់លើព្រំមួយចំនួន នឹងត្រូវកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១៧។ ពន្ធ ១៧.៥% លើបណ្តាព្រំដែលត្រូវបានកាត់តម្រូវ និងប្តូរទ្រង់ទ្រាយដើម្បីប្រើប្រាស់ក្នុងការតម្លើងរថយន្ត នឹងត្រូវលុបក្នុងឆ្នាំ ២០១០ រីឯពន្ធ ១២.៥% លើព្រំហ្វឺតនឹងត្រូវកាត់បន្ថយជាបណ្តើរៗមក 0% ក្នុងឆ្នាំ ២០១៧។

**១២. សារធាតុរ៉ែ និងប្រេង (HS 25-27)**

**អូស្ត្រាលី**

អូស្ត្រាលីនាំចូលសារធាតុរ៉ែ និងប្រេងពីអាស៊ានក្នុងមួយឆ្នាំមានតម្លៃប្រហែល ១៥ ពាន់លានដុល្លារ និងនាំចូលពីសកលលោកសរុបមានតម្លៃប្រហែល ២៣.៣ ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ។ បន្ទាត់ពន្ធភាគច្រើនក្នុងផ្នែកនេះ ពុំមានជាប់ពន្ធទេ លើកលែងបន្ទាត់ពន្ធចំនួន ១៤ ដែលជាប់ពន្ធ ៥% (រួមមានដូចជា ឧស្ម័នធ្យូងថ្ម ឧស្ម័នទឹក ជនិតាឧស្ម័ន និងឧស្ម័នប្រហាក់ប្រហែលលើកលែងតែឧស្ម័នតេល:សិលា និងឧស្ម័នអ៊ីដ្រូកាបៀផ្សេងទៀត ហ្វេណុល) ។ ពន្ធលើបន្ទាត់ពន្ធទាំង ១៤ នេះ នឹងត្រូវលុបក្នុងឆ្នាំ ២០១០។

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (២៥១ បន្ទាត់ពន្ធ)
  - ពន្ធ 0% លើ ២៣៧ បន្ទាត់ពន្ធ

- ពន្ធ ៥% លើ ១៨ បន្ទាត់ពន្ធរួមមានផលិតផលដូចជា ម៉ាប និងកករថ្មកំបោរ ឧស្ម័នធ្យូងថ្ម ឧស្ម័នទឹក និងឧស្ម័នផ្សេងទៀតលើកលែងតែឧស្ម័នតេលៈសិលា និងឧស្ម័នអ៊ីដ្រូកាបៀផ្សេងទៀត។

• ពន្ធលើបន្ទាត់ពន្ធទាំងអស់លើកលែងបន្ទាត់ពន្ធ ១ នឹងត្រូវលុបនៅពេល EIF ចំណែកពន្ធដែលនៅសល់នឹងត្រូវលុបក្នុងឆ្នាំ ២០២០។

### ណូវ៉ែលហ្សេឡង់

បន្ទាត់ពន្ធភាគច្រើនមិនជាប់ពន្ធទេសម្រាប់ណូវ៉ែលហ្សេឡង់ លើកលែងបន្ទាត់ពន្ធចំនួន ៩ ត្រូវជាប់ពន្ធក្នុងចន្លោះ ៥-៧% (រួមមាន ប្រេងយន្តហោះ ប្រេងកាត ប្រេងសាំងក្រអូប ប្រេងវ៉ាសឺលីន ខ្លាញ់គោ និងប្រេងរឹង)។

• ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (១៨៥ បន្ទាត់ពន្ធ)
  - ពន្ធ 0% លើ ១៧៦ បន្ទាត់ពន្ធ
  - ពន្ធ ៥% លើ ១ បន្ទាត់ពន្ធ (ប្រេងវ៉ាសឺលីន)
  - ពន្ធ ៦.៥% លើ ៣ បន្ទាត់ពន្ធ (ខ្លាញ់គោ ប្រេងរឹង និងប្រេងផ្សេងទៀត និងប្រភេទខ្លះនៃម៉ាបប្រើសម្រាប់ចាក់បេតុង )
  - ពន្ធ ៧% លើ ៥ បន្ទាត់ពន្ធ (រួមមាន ប្រេងយន្តហោះ ប្រេងកាត និងប្រេងសាំងក្រអូប)

• ពន្ធនាំចូលលើបន្ទាត់ពន្ធទាំងអស់លើកលែងបន្ទាត់ពន្ធ ១ នឹងត្រូវលុបនៅពេល EIF ចំណែកពន្ធដែលនៅសល់នឹងត្រូវលុបក្នុងឆ្នាំ ២០២០។

**១៣. ឈើ និងផលិតផលឈើ (HS 44)**

### អូស្ត្រាលី

ផលិតផលភាគច្រើននៅក្នុងក្រុមផលិតផលនេះជាប់ពន្ធ ៥% នៅអូស្ត្រាលី

• ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (១០២ បន្ទាត់ពន្ធ)
  - ពន្ធ 0% លើ ២៦ បន្ទាត់ពន្ធ
  - ពន្ធ ៥% លើ ៧៦ បន្ទាត់ពន្ធ

• ពន្ធទាំងអស់នឹងត្រូវលុបក្នុងឆ្នាំ ២០១០ លើកលែងបន្ទាត់ពន្ធ ១

- បន្ទាត់ពន្ធ ១ នោះ (រួមមាន ប្រភេទខ្លះនៃក្តារធ្វើពីសរសៃឈើ ឬធាតុឈើផ្សេងទៀត ) នឹងត្រូវរក្សានៅអត្រាពន្ធ ៥% រហូតដល់ឆ្នាំ ២០១៩ មុននឹងត្រូវលុបក្នុងឆ្នាំ ២០២០។

**ណូវ៉ែលហ្សេឡង់**

បណ្តាផលិតផលទាំងឡាយដែលនៅក្នុងក្រុមនេះជាទូទៅ ជាប់ពន្ធ ៥%-៧% នៅណូវ៉ែលហ្សេឡង់

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (១៣៩ បន្ទាត់ពន្ធ)
  - ពន្ធ ០% លើ ៦៩ បន្ទាត់ពន្ធ
  - ពន្ធ ៥% លើ ២៩ បន្ទាត់ពន្ធ
  - ពន្ធ ៦.៥%-៧% លើ ៤១ បន្ទាត់ពន្ធ

- ពន្ធទាំងអស់នេះនឹងត្រូវលុបក្នុងឆ្នាំ ២០២០ លើកលែង ២៨ បន្ទាត់ពន្ធដែលនឹងត្រូវលុបក្នុងឆ្នាំ ២០១២ ២០១៧ និង ២០២០ :
  - ក្នុងឆ្នាំ ២០១២ :
    - ១២ បន្ទាត់ពន្ធជាប់ពន្ធ ៥% និង ៥ បន្ទាត់ពន្ធជាប់ពន្ធ ៧% ដែលអត្រាពន្ធទាំងពីរនេះនឹងត្រូវកាត់បន្ថយជាបណ្តើរៗមក ០% (រួមមាន ប្រភេទខ្លះនៃក្តារធ្វើពីសរសៃឈើ ឬធាតុឈើផ្សេងទៀត ទោះផ្គុំដោយជ័រ ឬសរីរាង្គផ្សេងទៀត និងប្រភេទខ្លះនៃក្តារបន្ទះធ្វើពីកម្ទេច និងក្តារបន្ទះប្រហាក់ប្រហែលធ្វើពីឈើ (ឧទាហរណ៍ ក្តារធ្វើពីកម្ទេចឈើរាបស្មើ ឬមានផ្នុង)
  - ក្នុងឆ្នាំ ២០១៧ :
    - ពន្ធ ៥% ដាក់លើ ២បន្ទាត់ពន្ធ នឹងត្រូវលុប (រួមមាន ក្តារបន្ទះធ្វើពីឈើ ត្រូពិច)
  - ក្នុងឆ្នាំ ២០២០ :
    - បន្ទាត់ពន្ធចំនួន ៩ ជាប់ពន្ធ ៥%, ៦.៥% និង ៧% ដែលអត្រាទាំងនេះនឹងត្រូវកាត់បន្ថយជាបណ្តើរៗមក ០% (រួមមាន ប្រភេទខ្លះនៃក្តារបន្ទះ ក្តារពាសរនៀរ និងក្តារបន្ទះប្រហាក់ប្រហែល ទ្វារ គ្រោងទ្វារ ឈើចាក់ពុម្ព និងប្រភេទខ្លះនៃ ឈើលំអ និងឈើដែលមានឆ្លាក់ ហឹបតូច ប្រអប់ និងស្រោមសម្រាប់គ្រឿងអលង្ការ និងផលិតផលធ្វើពីមាស និងផលិតផលប្រហាក់ប្រហែលធ្វើពីឈើ រូបចម្លាក់ និងផលិតផលផ្សេងទៀតសម្រាប់លំអធ្វើពីឈើ)។

**១៤. ដែក និងដែកថែប (HS 72-73)**

**អូស្ត្រាលី**

បន្ទាត់ពន្ធភាគច្រើន (ជាង ៨០%) នៅក្នុងក្រុមផលិតផលនេះ ជាប់ពន្ធ ៥%

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (៣០៥ បន្ទាត់ពន្ធ)
  - ពន្ធ 0% លើ ៥៥ បន្ទាត់ពន្ធ
  - ពន្ធ ៥% លើ ២៤៣ បន្ទាត់ពន្ធ
  - ពន្ធ ១០% លើ ៧ បន្ទាត់ពន្ធ
- ពន្ធលើគ្រប់បន្ទាត់ពន្ធទាំងអស់ត្រូវលុបនៅពេល EIF លើកលែង ៣ បន្ទាត់ពន្ធដែលនៅបន្ត ជាប់ពន្ធ ៥% ដែលអត្រាពន្ធនេះនឹងត្រូវបន្ថយមក 0% ក្នុងឆ្នាំ ២០២០។
  - បន្ទាត់ពន្ធទាំងនោះរួមមាន ទុយោប្រេងឥន្ធនៈ/ហ្គាស ទុយោ ទុយោដែក/ដែកថែបដទៃទៀត និងទុយោ ទុយោ និងដែកប្រហោងផ្សេងទៀតធ្វើពីដែក ឬដែកថែបៈ

| | |
|---|---|
| 7304.10.00 | -ទុយោប្រភេទប្រើសម្រាប់ប្រេងឥន្ធនៈ ឬហ្គាស |
| 7305 | ទុយោ និងទុយោដទៃទៀត "ឧទា. ផ្សារ មឺន ឬភ្ជាប់តាមវិធីប្រហាក់ប្រហែល" ដែលមានមុខកាត់ខាងក្នុង និងខាងក្រៅរាងមូលដែលមានវិជ្ជមាត្រខាងក្រៅ លើសពី ៤០៦,៤ ម.ម ធ្វើពីដែក ឬដែកថែប។ |
| 7305.12.00 | --ផ្សេងៗ ផ្សាតាមបណ្ដោយ |
| 7306 | ទុយោ ទុយោ និងដែកប្រហោងដទៃៗទៀត "ឧទា. ភ្ជាប់គ្នាតាមគែមជ្រួញ ផ្សារ ភ្ជាប់ មឺន ឬភ្ជាប់តាមវិធីប្រហាក់ប្រហែល" ធ្វើពីដែក ឬដែកថែប។ |
| 7306.60.00 | --ផ្សេងទៀត ផ្សារ ដែលមានមុខកាត់មិនមូល |

## ណូវ៉ែលហ្សេឡង់

បន្ទាត់ពន្ធភាគច្រើននៅក្នុងក្រុមផលិតផលនេះជាប់ពន្ធពី ៥-៧% និងបន្ទាត់ពន្ធមួយចំនួនតូចជាប់ពន្ធ ១០% និង ១៧.៥%។

- ពន្ធមូលដ្ឋាន ឆ្នាំ ២០០៥ (៤៤៥ បន្ទាត់ពន្ធ)
  - 0% លើ ២០១ បន្ទាត់ពន្ធ
  - ៥% លើ ១២២ បន្ទាត់ពន្ធ
  - ៦.៥%-៧% លើ ១១៦ បន្ទាត់ពន្ធ
  - ១៧.៥% លើ ៣ បន្ទាត់ពន្ធ

- ពន្ធលើ ២០៤ បន្ទាត់ពន្ធកំណត់ ០% ឬត្រូវលុបនៅពេល EIF និងពន្ធដែលនៅសល់ត្រូវកាត់បន្ថយជាបណ្តើរៗមក ០% ក្នុងឆ្នាំ ២០១៨:

  - ពន្ធ ០% និង ១០% កំណត់ ០% ឬត្រូវលុបនៅពេល EIF

  - ពន្ធ ១៧.៥% ត្រូវបន្ថយជាបណ្តើរៗមក ០% ក្នុងឆ្នាំ ២០២០ លើបណ្តាផលិតផលដូចជា:

| | |
|---|---|
| 73.20 | រឺស័រ និង ឡាមរឺស័រធ្វើពីដែក ឬដែកថែប |
| 7320.10 | -រឺស័របន្ទះ និងបន្ទះ |
| | --ដែកចន្ទាស (មិនរាប់បញ្ចូលច្រវាក់): |
| | ---សម្រាប់ប្រើប្រាស់ក្នុងការតម្លើងរថយន្តដូចបានកំណត់ដោយរដ្ឋមន្ត្រី អនុលោមតាមផ្នែកទី ១៤ នៃច្បាប់នេះ |
| 7320.10.02 | ---សម្រាប់រថយន្តអ្នកធ្វើដំណើរនៃទីតាំង ៨៧.០៣ និងរថយន្តដទៃទៀតនៃទីតាំង ៨៧.០៤ ដែលមានទម្ងន់រថយន្តសរុបមិនលើស ៣.៥០០ គីឡូ |

| | |
|---|---|
| 7320.20 | -រឺស័រវង្វង់: |
| | --បូបរឺស័រ និងកៅអីរឺស័រ: |
| | ---សម្រាប់ប្រើប្រាស់ក្នុងការតម្លើងរថយន្តដូចបានកំណត់ដោយរដ្ឋមន្ត្រី អនុលោមតាមផ្នែកទី ១៤ នៃច្បាប់នេះ |
| 7320.20.02 | --- សម្រាប់រថយន្តអ្នកធ្វើដំណើរនៃទីតាំង ៨៧.០៣ និងរថយន្តដទៃទៀតនៃទីតាំង ៨៧.០៤ ដែលមានទម្ងន់រថយន្តសរុបមិនលើស ៣.៥០០ គីឡូ |

| | |
|---|---|
| 7320.90 | -ផ្សេងៗ |
| | --បូបរឺស័រ និងកៅអីរឺស័រ: |
| 7320.90.02 | ---សម្រាប់រថយន្តអ្នកធ្វើដំណើរនៃទីតាំង ៨៧.០៣ និងរថយន្តដទៃទៀតនៃទីតាំង ៨៧.០៤ ដែលមានទម្ងន់រថយន្តសរុបមិនលើស ៣.៥០០ គីឡូ |

- បន្ទាត់ពន្ធដែលជាប់ពន្ធ ៦.៥% នឹងត្រូវកាត់បន្ថយជាបណ្តើរៗមក ០% ក្នុងឆ្នាំ ២០១២
  - ឧទាហរណ៍ដូចជាផលិតផលកិនសំប៉ែតនៃដែកជ្រលក់ ពាស ឬស្រោបជាមួយសំណប៉ាហាំង ដែលពន្ធលើផលិតផល ទាំងអស់នេះត្រូវកាត់បន្ថយមក ៥% ក្នុងឆ្នាំ ២០១០ ៣% ក្នុងឆ្នាំ ២០១១ និង ០% ក្នុងឆ្នាំ ២០១២។
- បន្ទាត់ពន្ធដែលជាប់ពន្ធ ៧% ត្រូវកាត់បន្ថយជាបណ្តើរៗមក ០% ក្នុងឆ្នាំ ២០១២

- រួមមានបណ្តាប្រភេទផលិតផលដែកដូចជា បង្គោលគ្រឹះ ទុយោប្រើសម្រាប់ប្រេងឥន្ធនៈ និងហ្គាស ទុយោ ទុយោទីបផ្សា។

- ពន្ធ ៥% លើបន្ទាត់ពន្ធទាំងអស់នឹងត្រូវកាត់បន្ថយមក ០% ក្នុងឆ្នាំ ២០២០
  - បន្ទាត់មួយចំនួននឹងត្រូវកាត់បន្ថយជាបណ្តើរៗមក ០% ក្នុងឆ្នាំ ២០១២ (ផលិតផលកិនសំប៉ែតពីដែក ឬដែកថែបសុទ្ធ រាងមុំ រូបរាង និងសណ្ឋានចម្រុះដែលធ្វើពីដែក ឬដែកថែបសុទ្ធៈ ទុយោ ទុយោទីប និងប្រភេទខ្លះនៃទុយោកំដៅ។
  - បន្ទាត់ខ្លះទៀតនឹងត្រូវបន្តជាប់ពន្ធ ៥% រហូតដល់ឆ្នាំ ២០១៣ (ប្រភេទខ្លះនៃ ដើមនិងសរសៃដែក កិនក្តៅរុំជាដុំរូឡូពីដែក និងដែកថែបសុទ្ធ)។

## ឱកាសក្នុងការធ្វើពាណិជ្ជកម្មសេវាកម្ម

តាមរយៈកិច្ចព្រមព្រៀង AANZFTA នេះ អូស្ត្រាលី និងណូវ៉ែលហ្សេឡង់បានឯកភាពលើបណ្តាការសន្យាថ្មីៗ ឬការសន្យាដែលបានពិនិត្យឡើងវិញ ក្នុងការធ្វើពាណិជ្ជកម្មសេវាដែលនឹងបង្កើតឱកាសជាច្រើនដែលសមាជិក WTO ដទៃទៀតមិនអាចទទួលលើកលែងអ្នកនាំចេញអាស៊ាន។ បណ្តាវិស័យដែលអូស្ត្រាលី និងណូវ៉ែលហ្សេឡង់បានព្រមព្រៀងហួសពីអ្វីដែលខ្លួនបានសន្យានៅក្នុង GATS មានរៀបរាប់ដូចខាងក្រោមនេះ។

## សេចក្តីសង្ខេបអំពីការសន្យាទាក់ទងសេវារបស់អូស្ត្រាលីនៅក្នុង AANZFTA (លើសពី GATS)

## ការសន្យាតាមវិស័យ

### ១- សេវាអាជីវកម្ម

- សេវាច្បាប់
  - សេវាប្រឹក្សាច្បាប់ និងតំណាង នៅក្នុងច្បាប់ក្នុងស្រុក (ប្រទេសទទួល) :
    - ការសន្យាថ្មីមួយត្រូវបានបន្ថែមជាមួយការសន្យាពេញលេញរបស់អូស្ត្រាលីតាមម៉ូដ ១ ២ និង៣
  - សេវាប្រឹក្សាច្បាប់ក្នុងច្បាប់បរទេស និងច្បាប់អន្តរជាតិ
    - នៅក្នុងការសន្យា AANZFTA បុគ្គលដែលអនុវត្តច្បាប់អាចចូលរួមជាមួយក្រុមហ៊ុនច្បាប់ក្នុងស្រុកក្នុងឋានៈជាទីប្រឹក្សាប៉ុណ្ណោះ ប៉ុន្តែមិនអាចធ្វើជាដៃគូជាមួយអ្នកច្បាប់ក្នុងស្រុក ឬជួលអ្នកច្បាប់ក្នុងស្រុកមកបម្រើការបានឡើយនៅ

ក្នុងរដ្ឋ South Australia។ នៅក្នុង GATS ការដាក់កម្រិតនេះត្រូវបានយកមកអនុវត្តទូទាំងអូស្ត្រាលីតែម្តង ដែលផ្ទុយពីការកំណត់យករដ្ឋ South Australia។

- នៅក្នុង GATS នេះផងដែរ សេវាកម្មប្រឹក្សាច្បាប់ត្រូវមានដៃគូស្មើភាព យ៉ាងតិចមួយម្នាក់ដែលតាំងទីលំនៅអចិន្ត្រៃយ៍ (ក្នុងរដ្ឋ Victoria និងNew South Wale) ឬតាំងទីលំនៅអចិន្ត្រៃយ៍យ៉ាងហោចណាស់ ១៨០ថ្ងៃ នៃឆ្នាំប្រតិទិន (ក្នុងរដ្ឋ Queensland)។ ការដាក់កម្រិតប្រព្រឹត្តិកម្មជាតិនេះមិនត្រូវបានយកមកអនុវត្តនៅក្នុង AANZFTA ទេ។

- គិលានុបដ្ឋាយិកា និង ឆ្មប

- សេវាកម្មនេះត្រូវបានដាក់ជាអនុវិស័យថ្មីមួយនៅក្នុង AANZFTA ប៉ុន្តែជាការសន្យាមិនត្រូវបានចងសម្រាប់ ម៉ូដ ១ ២ និង៣ នៅក្នុងការបើកច្រកទីផ្សារ និងការដាក់កម្រិតប្រព្រឹត្តិកម្មជាតិ។ ការសន្យាថ្មីនេះធានា បាននូវការគ្របដណ្តប់លើមុខរបរវិជ្ជាជីវៈទាំងអស់នេះក្រោមការសន្យាស្តីពីការចល័តបណ្តោះអាសន្ននៃរូបវន្តបុគ្គលរបស់អូស្ត្រាលី

- សេវារ៉ែ

- ឧទាហរណ៍ការប្រឹក្សាលើកម្រៃ/កិច្ចសន្យា ទាក់ទងរ៉ែ និងការអភិវឌ្ឍទីតាំងប្រេង នៅក្នុង CPC 5115 ក្រោម AANZFTA ជំនួសឲ្យ CPC 883 ក្រោម GATS។

**២. គមនាគមន៍**

- អូស្ត្រាលីបានដកចេញនូវការដាក់កម្រិត ដែលហួសសម័យជាច្រើនដែលមាននៅក្នុងកម្មវិធី GATS និងបានបង្កើនកម្រិតអតិបរមានូវកម្មសិទ្ធិបរទេសសរុប ដែលដាក់កម្រិតចំពោះក្រុមហ៊ុនដឹកជញ្ជូនរបស់រដ្ឋពីមុនមក។

- ពុំមានការដាក់កម្រិតលើការបើកច្រកទីផ្សារ ឬប្រព្រឹត្តិកម្មជាតិ ទាំងនៅក្នុងការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន និងការប្រើប្រាស់ក្រៅប្រទេស នៅក្នុងអនុវិស័យទូរគមនាគមន៍របស់អូស្ត្រាលី។
- ទោះជាយ៉ាងណាក៏ដោយ នៅមានបណ្តាលក្ខខណ្ឌតម្រូវទាក់ទងវត្តមានស្ថាប័នពាណិជ្ជកម្មដូចខាងក្រោមនេះ:
  - ស្ថាប័នមួយដែលមានអាជ្ញាប័ណ្ណដឹកជញ្ជូនថ្មីត្រូវជាស្ថាប័នសាធារណៈ ឬជាសាជីវកម្មស្របច្បាប់ស្ថិតក្រោមច្បាប់អូស្ត្រាលី ឬដៃគូដែលភាគីនីមួយៗ ជាស្ថាប័នស្របច្បាប់ស្ថិតក្រោមច្បាប់អូស្ត្រាលី
  - កម្មសិទ្ធិបរទេសសរុបអតិបរមានៅក្នុងក្រុមហ៊ុន Telstra ត្រូវបានអនុញ្ញាតតែ ៣៥% ប៉ុណ្ណោះ ចំពោះបុគ្គលបរទេសមានកម្មសិទ្ធិអតិបរមា ៥%។

  - ○ ប្រធាន និងនាយកភាគច្រើនក្នុងក្រុមហ៊ុន Telstra ត្រូវតែមានសញ្ជាតិអូស្ត្រាលី។ ក្រុមហ៊ុន Telstra ត្រូវរក្សាការិយាល័យកណ្តាល មូលដ្ឋានប្រតិបត្តិការសំខាន់ និងទីកន្លែងសាជីវកម្ម របស់ខ្លួនក្នុងអូស្ត្រាលី។

### ៣. សេវាអប់រំ

- បណ្តាប្រភេទសេវាអប់រំមួយចំនួនត្រូវបានដាក់បញ្ចូលក្រោមការសន្យា AANZFTA ។ សេវាទាំងនោះរួមមាន ការបង្រៀន និងការប្រឡង ជាភាសាអង់គ្លេស និងភាសាដទៃទៀត ការបង្រៀនអំពីរបៀបធ្វើម្ហូប និងវិធីព្យាបាលរោគបែបបុរាណ (រួមមាន ម៉ាស្សា និងចាក់ម្ជុលវិទ្យាសាស្ត្រ) តន្ត្រី របាំ និងក្បាច់គុណ។

### ៤. សេវាបរិដ្ឋាន

- បណ្តាអនុវិស័យថ្មីៗត្រូវបានដាក់បញ្ចូល ក្រោម AANZFTA :

- ការការពារខ្យល់ និងបរិយាកាស
  - ○ រួមមានសេវាកម្មកម្ចាត់ខ្យល់កខ្វក់នៅក្នុងស្ថានីយថាមពល ឬតំបន់ឧស្សាហកម្ម សេវាត្រួតពិនិត្យឧស្ម័នបញ្ចេញចោលរបស់យានយន្ត និងការអនុវត្តប្រព័ន្ធត្រួតពិនិត្យ ឬកម្មវិធីកាត់បន្ថយ។
- ការបំបាត់ធាតុអាក្រក់ និងសំអាតដី និងទឹក
  - ○ រួមមាន ប្រព័ន្ធសំអាតនៅនឹងកន្លែង ឬចល័ត សង្គ្រោះបន្ទាន់ សំអាត និងការធ្វើឲ្យថយ ចុះក្នុងរយៈពេលវែងនូវការធ្លាក់ចេញ និងគ្រោះធម្មជាតិ និងកម្មវិធីស្តារ (ដូចជាការបើកឡើងវិញការដ្ឋានរ៉ែ) រួមទាំងការត្រួតពិនិត្យ។
- ការកាត់បន្ថយសំឡេង និងរំញ័រ
  - ○ រួមមានកម្មវិធីត្រួតពិនិត្យ និងការតម្លើងនូវអេក្រង់ និងប្រព័ន្ធកាត់បន្ថយសំឡេង។
- ការការពារ ជីវចម្រុះ និងទេសភាព
  - ○ រួមមាន ការការពារអេកូឡូស៊ី និងទីជម្រក និងជំរុញការដាំដុះព្រៃឈើប្រកបដោយនិរន្តរភាព
- និង សេវាកម្មផ្សេងទៀតរួមបញ្ចូលទាំងសេវាកម្មវាយតម្លៃផលប៉ះពាល់បរិស្ថាន
- បណ្តាអនុវិស័យដែលត្រូវបន្ថែមចូលថ្មីៗទាំងអស់នេះ (ពីមុនមកពុំមាននៅក្នុង GATS) ពុំមានប្រឈមការដាក់កម្រិតលើការបើកច្រកទីផ្សារ ឬលើប្រព្រឹត្តិកម្មជាតិសម្រាប់ម៉ូដផ្គត់ផ្គង់ ១ ២ និង៣។

- មានការផ្លាស់ប្តូរមួយចំនួនទាក់ទងនឹងប្រព្រឹត្តិកម្ម

- នៅក្នុងសេវាកម្មគ្រប់គ្រងកាកសំណល់ និងសំណល់រាវ ក្រោម AANZFTA ការផ្គត់ផ្គង់ ឆ្លងកាត់ព្រំដែន ពុំប្រឈមនឹងការដាក់កម្រិតក្នុងការបើកច្រកទីផ្សារ ឬប្រព្រឹត្តិកម្មជាតិ (នៅក្នុង GATS វាមិនត្រូវបានចងដោយសារពុំមានលទ្ធភាពបច្ចេកទេស)។

### ៥. សេវាហិរញ្ញវត្ថុ

- សម្រាប់សេវាធនាគារ និងសេវាហិរញ្ញវត្ថុផ្សេងទៀត មាននិយាយអំពីការបញ្ជាក់បន្ថែមស្តីពីការសន្យារបស់អូស្ត្រាលីលើមជ្ឈមណ្ឌលផ្ទេរប្រាក់ និងសេវារបស់មជ្ឈមណ្ឌលផ្ទេរប្រាក់។

### ៦. ការដឹកជញ្ជូន

- ធ្វើឲ្យប្រសើរឡើងបណ្តាការសន្យានៅក្នុងសេវាដូចជា សេវាកម្មតាមផ្លូវសមុទ្រ ការលើកដាក់ទំនិញ ការជួលរថយន្តអាជីវកម្ម សេវាឃ្លាំង និងសេវាភ្នាក់ងារដឹកជញ្ជូន។
  - មានការសន្យាថ្មីៗត្រូវបានបន្ថែមនៅក្នុងសេវាកម្មដឹកជញ្ជូនតាមសមុទ្រ ដែលមានភ្ជាប់ជាមួយបណ្តាលក្ខខណ្ឌសមហេតុផល និងមិនមានការរើសអើងចំពោះអ្នកដឹកជញ្ជូនផ្លូវសមុទ្រអន្តរជាតិដែលប្រើប្រាស់សេវាកម្មដូចខាងក្រោមនេះ :
    - សេវាជួយបញ្ជា អូស និងទាញ
    - ផ្គត់ផ្គង់ម្ហូមអាហារ ចាក់ប្រេង និងស្រោចទឹក
    - ប្រមូលសំរាម និងកាកសំណល់កូនសណ្តូន
    - សេវាមេបញ្ជាកំពង់ផែ
    - ជំនួយនាវាចរណ៍ (សេវាប្រតិបត្តិការលើច្រាំងដែលមានសារៈសំខាន់ចំពោះការបញ្ជាកប៉ាល់ រួមទាំង ទំនាក់ទំនងលើទឹក និងការផ្គត់ផ្គង់អគ្គិសនី បរិក្ខារជួសជុលបន្ទាន់ ការបោះយុថ្កា និងសេវាកម្មចត និងផ្តល់ទីកន្លែងចតនាវា។
- សេវាដឹកជញ្ជូនផ្លូវដែកត្រូវបានបញ្ចូលជាអនុវិស័យថ្មីមួយក្នុង AANZFTA។ អនុវិស័យថ្មីនេះគ្របដណ្តប់លើ ការដឹកជញ្ជូនដឹកទំនិញ សេវាទាញ និងសណ្តោង និងបណ្តាសេវា គាំទ្រដល់សេវាដឹកជញ្ជូនផ្លូវដែក។
  - រាល់ម៉ូដនៃការផ្គត់ផ្គង់នៅក្នុងវិស័យនេះមិនប្រឈមការដាក់កម្រិតលើការបើកច្រកទីផ្សារ ឬប្រព្រឹត្តិកម្មជាតិ
    - យ៉ាងណាក៏ដោយ សម្រាប់ below track បើទោះបីជាមិនមានការដាក់កម្រិតលើសិទ្ធិក្នុងការបង្កើត បណ្តាញថ្មីក៏ដោយ ការប្រើប្រាស់ដីធ្លីសាធារណៈក៏ពុំមានការធានាដែរ

- ចំពោះ above track (សេវាកម្មដឹកជញ្ជូនផ្លូវដែកដូចជារថភ្លើង) បើកសេរី លើកលែងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក ត្រូវបានរក្សាទុកក្រោមគោលការណ៍គាំទ្រការប្រកួតប្រជែងសម្រាប់សុវត្ថិភាព ប្រសិទ្ធភាព និងផលប្រយោជន៍រយៈពេលវែងរបស់អ្នកប្រើប្រាស់។

- សេវាជួលរថយន្តអាជីវកម្មដែលមានប្រតិបត្តិករ ជាការសន្យាថ្មីមួយទៀតដែលត្រូវបានបន្ថែម ដែលជាការសន្យាពេញលេញនៅក្នុងម៉ូដ ១ ២ និង ៣
  - សេវាលើកដាក់ទំនិញដឹកជញ្ជូនតាមផ្លូវដែក ផ្លូវថ្នល់ និងផ្លូវអាកាសត្រូវបានរាប់បញ្ចូលជាការសន្យាថ្មីមួយដែលជាការសន្យាពេញលេញនៅក្នុងម៉ូដ ២ និង ៣ (និងកំណត់សម្គាល់លើបច្ចេកទេសដែលមិនអាចអនុវត្តបាន ក្នុងម៉ូដ ១)

**សេចក្តីសង្ខេបអំពីការសន្យាពាណិជ្ជកម្មសេវារបស់ណូវ៉ែលហ្សេឡង់នៅក្នុង AANZFTA (ហួសពី GATS)**

**១. អាជីវកម្មសេវា**

- សេវាច្បាប់
  - នៅក្រោមការសន្យាសេវាច្បាប់ ការសន្យាសេវាច្បាប់បរទេសត្រូវបានបញ្ចូលដែលនៅក្នុងនោះ ម៉ូដ ១ ២ ៣ មិនប្រឈមការដាក់កម្រិតលើច្រកចូលទីផ្សារ ឬប្រព្រឹត្តិកម្មជាតិ
- សេវាវិស្វកម្ម
  - ការដាក់កម្រិតទាក់ទងនឹងការចុះបញ្ជី និងការតម្រូវលិខិតបញ្ជាក់ត្រូវបានដកចេញ។ នៅ ក្នុង GATS សម្រាប់ម៉ូដ ១ ៣ & ៤ មានការដាក់កម្រិតលើច្រកចូលទីផ្សារ និងប្រព្រឹត្តិកម្មជាតិ តាមរយៈការបញ្ជាក់ការងារជាក់លាក់មួយចំនួនពាក់ព័ន្ធសុខភាព និងសុវត្ថិភាពដែលត្រូវបានកម្រិតចំពោះវិស្វករដែលត្រូវបានចុះបញ្ជី ត្រូវមានដើមកំណើតនៅណូវ៉ែលហ្សេឡង់។ នោក្នុង AANZFTA ការដាក់កម្រិតនេះត្រូវបានលើកលែង។
- សេវាបសុពេទ្យ
  - សេវានេះ (មិនត្រូវចងភ្ជាប់ដោយសារគ្មានលទ្ធភាពបច្ចេកទេស) គឺសម្រាប់ការផ្គត់ផ្គង់ឆ្លងដែន ទាំងនៅក្នុងការបើកច្រកទីផ្សារ និងប្រព្រឹត្តិកម្មជាតិក្នុង GATS ប៉ុន្តែសេវានេះ ត្រូវបានបើកសេរីក្នុងការសន្យា AANZFTA ។
- បណ្តាអនុវិស័យថ្មីត្រូវបានបន្ថែមនៅក្នុងអាជីវកម្មសេវារួមមាន៖ សេវាថតរូប សេវាសន្និបាត សេវារាយការណ៍ឥណទាន សេវាភ្នាក់ងារប្រមូល សេវាថ្មៃម៉ូដផ្ទៃខាងក្នុង សេវា

ឆ្លើយតាមទូរស័ព្ទ សេវាចម្លង និងអាជីវកម្មសេវាផ្សេងទៀតមានដូចជា សេវាអាជីវកម្ម ឈ្មួញកណ្តាល សេវាវាយតម្លៃ សេវាលេខាធិការ សេវាតាំងបង្ហាញ/ពិព័រណ៍ជាដើម។ល។

- អនុវិស័យទាំងអស់ដែលរៀបរាប់ខាងលើមិនប្រឈមការដាក់កម្រិតលើការបើកច្រកទីផ្សារ និងប្រព្រឹត្តិកម្មជាតិសម្រាប់ម៉ូដ ១ ២ ៣។
- ការសន្យាថ្មីៗត្រូវបានបន្ថែមនៅក្នុងសេវារាយការណ៍ឥណទានដែលតម្រូវឲ្យប្រព្រឹត្តិកម្ម នៃព័ត៌មានផ្ទាល់ខ្លួនត្រូវអនុលោមតាម ច្បាប់ឯកជន ឆ្នាំ ១៩៩៣ ( ក្របខណ្ឌបទប្បញ្ញត្តិរបស់ណូវែលហ្សេឡង់សម្រាប់ប្រព្រឹត្តិកម្មនៃព័ត៌មានផ្ទាល់ខ្លួន អនុលោមតាមអនុសាសន៍របស់ក្រុមប្រឹក្សា OECD ពាក់ព័ន្ធសេចក្តីណែនាំគ្រប់គ្រងការការពារភាពឯកជន និងលំហូរឆ្លងដែននៃទិន្នន័យផ្ទាល់ខ្លួន។

## ២. សំណង់ និង សេវាទាក់ទងវិស្វកម្ម

- សំណង់ និងសេវាកម្មទាក់ទងវិស្វកម្មរួមមាន ការងារសំណង់ទូទៅសម្រាប់ការសាងសង់វិស្វកម្មស៊ីវិល ការងារតម្លើង ការងារបញ្ចប់ និងការបញ្ចប់ការសាងសង់ ក៏ដូចជាសេវាដទៃទៀត (ការរៀបចំទីតាំង ថែរក្សា និងជួសជុលរចនាសម្ព័ន្ធនឹងថ្កល់ និងសេវាជួលបរិក្ខារ។

- ក្រោម GATS រាល់ការផ្គត់ផ្គង់ឆ្លងដែននូវបណ្តាអនុវិស័យទាំងអស់នេះ នៅក្នុងផ្នែកនេះ មិនត្រូវបានចងភ្ជាប់ដោយសារកង្វះខាតលទ្ធភាពបច្ចេកទេស (ទាំងការបើកច្រកទីផ្សារ និងប្រព្រឹត្តិកម្មជាតិ) ក៏ប៉ុន្តែនៅក្នុង AANZFTA ត្រូវបានបើកសេរីសម្រាប់សេវាប្រឹក្សា មានន័យថាការផ្តល់សេវាប្រឹក្សាឆ្លងដែនសម្រាប់បណ្តាអនុវិស័យដែលរៀបរាប់ខាងលើនេះ មិនប្រឈមការដាក់កម្រិតលើការបើកច្រកទីផ្សារ និង ប្រព្រឹត្តិកម្មជាតិ។

- សេវាជួលបរិក្ខារបម្រើឲ្យការសាងសង់ត្រូវបានបញ្ចូលបន្ថែមនៅក្នុង AANZFTA នៅក្នុងម៉ូដ ១ ២ និង៣ ដែលមិនត្រូវប្រឈមការដាក់កម្រិតលើការបើកច្រកទីផ្សារ ឬប្រព្រឹត្តិកម្មជាតិ។

## ៣. សេវាសិក្សាអប់រំ

- បណ្តាសេវាអប់រំផ្សេងទៀតត្រូវបានបន្ថែមនៅក្នុង AANZFTA។ ការបន្ថែមទាំងនោះរួមមាន ការបណ្តុះបណ្តាលភាសាផ្តល់ដោយស្ថាប័នឯកទេសភាសា និងការសិក្សាលើមុខវិជ្ជាដែលត្រូវបង្រៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សានៅក្នុងស្ថាប័នឯកទេសដែលមានប្រតិបត្តិការក្រៅប្រព័ន្ធអប់រំសិក្សាចាំបាច់របស់ណូវែលហ្សេឡង់។

### ៤. សេវាបរិស្ថាន

អ្វីដែលថ្មីនៅក្នុង AANZFTA គឺការផ្តល់សេវាប្រឹក្សា ដែលគ្របដណ្តប់លើបណ្តាសេវាពាក់ព័ន្ធបរិស្ថានទាំងអស់ រួមមានដូចជា:

- សំណល់ទឹក និងសេវាគ្រប់គ្រងកាកសំណល់
- ការការពារ ខ្យល់ និងបរិយាកាសជុំវិញ ការបំបាត់ធាតុអាក្រក់ និងសំអាត ដី និងទឹក ការបន្ថយសំឡេង និងរំញ័រ ការការពារជីវៈចម្រុះ និងទេសភាព និងបណ្តាសេវាបរិស្ថានផ្សេងទៀត។ រាល់សេវាទាំងអស់នេះគឺសម្រាប់តែការប្រឹក្សាប៉ុណ្ណោះ។
- សេវាខាងលើនេះមិនប្រឈមការដាក់កម្រិតលើការបើកច្រកទីផ្សារ ឬប្រព្រឹត្តិកម្មជាតិនៅក្នុងម៉ូដផ្គត់ផ្គង់ ១ ២ និង ៣។

### ៥.សេវាហិរញ្ញវត្ថុ

- នៅក្នុងសេវាធានារ៉ាប់រងមិនមែនអាយុជីវិត (ធានារ៉ាប់រងទូទៅ) ការដាក់កម្រិតទាក់ទងក្រុមប្រឹក្សា Apple & Marketing ត្រូវបានដកចេញ។ នៅក្នុង GATS ក្រោមច្បាប់ Apple & Pear Marketing ក្រុមប្រឹក្សា Marketing មានអំណាចក្នុងការរៀបចំធានារ៉ាប់រងកាតព្វកិច្ចជំនួសឲ្យអ្នកដាំដុះ និងតម្រូវឲ្យអ្នកដាំដុះទាំងអស់នោះបង់ពន្ធដើម្បីទូទាត់សងការចំណាយលើបុព្វលាភធានារ៉ាប់រងនេះ។
- នៅក្នុងអនុវិស័យអន្តរការីធានារ៉ាប់រង លក្ខខណ្ឌតម្រូវថ្មីមួយត្រូវបានបន្ថែមទាក់ទងពន្ធលើអ្នកដាំស្រូវសាលី។ លក្ខខណ្ឌនេះចែងថា United Wheat Growers NZ Ltd មានសិទ្ធិអំណាចក្នុងការរៀបចំធ្វើការធានារ៉ាប់រងមហន្តរាយកាតព្វកិច្ចជំនួសឲ្យអ្នកដាំដុះ និងតម្រូវឲ្យពួកគេបង់ពន្ធដើម្បីទូទាត់សងការចំណាយលើបុព្វលាភធានារ៉ាប់រង។

**Notes on Accompanying CD**

This CD-ROM contains the following:

Part A: Text and schedules of the Agreement Establishing the ASEAN-Australia-New Zealand Free Trade Area (AANZFTA). It also includes the text of the Understanding on Article 1 (Reduction and Elimination of Customs Duties) of Chapter 2 (Trade in Goods Chapter) of the AANZFTA and the Implementing Arrangement for ASEAN-Australia-New Zealand Free Trade Area Economic Co-operation Work Programme Pursuant to Chapter 12 (Economic Cooperation) of the AANZFTA.

Part B: Product Specific Rules (PSR), Certificate of Origin (CO) Form, Exporter's Declaration Form, and Guidelines for Completing the CO Form of the AANZFTA ROO. For tariff reduction schedules for Trade in Goods, please refer to Part A above. Note that tariff reduction schedules as annexed are in HS 2002. Readers/users are advised to refer to the www.asean.org at entry into force of AANZFTA for the HS 2007 version of the tariff reduction schedules.

Utmost care has been done in the preparation/compilation of the files in the CD, should there be any discrepancies, the original legal text, including the schedules of the AANZFTA signed by the Parties shall prevail.



This translation was certified
by Ministry of Economy and Finance of Cambodia